# ប្រវត្តិ និង ពុទ្ធស្ថាន

## នៅប្រទេសស្រីលង្កា

Lc 294 YOR

រៀបរៀងដោយ

ភិក្ខុ **យ៉ន់ យឹម សន្តត្ថេរ**

ព្រះរាជាណាចក្រកម្ពុជា
13026/11
3/5
បណ្ណាល័យជាតិ

សម្រាប់ចែកជាធម្មទាន

បោះពុម្ពលើកទី១ ចំនួន ១០០០ ក្បាល

MP Printing House
រោងពុម្ព ម៉ៅ ផុន (ពុយ)
MAO PHON (PUY) PRINTING HOUSE

Tel : 077 777 800 / 088 8888 908 / 023 63 63 524
E-mail : info@phonmao.com / Website: www.phonmao.com

ព.ស. ២៥៥៤ គ.ស. ២០១០

National Library of Cambodia
00021304

www.elibraryofcambodia.org

| | |
|---|---|
| ឈ្មោះសៀវភៅ | ប្រវត្តិ និងពុទ្ធស្ថាននៅប្រទេសស្រីលង្កា |
| រៀបរៀងដោយ | ភិក្ខុ យ៉ង់ យឹម សន្តត្ថេរ |
| ផ្ទៀងផ្ទាត់ដោយ | ភិក្ខុ ខាត់ ប៊ុនថាយ |
| | លោកគ្រូ ធម្មាចារ្យ អៀ សៅ |
| អ្នកចាត់ការទូទៅ | ភិក្ខុ ផុន សាបាន |
| សហការីកុំព្យូទ័រ | ភិក្ខុ វ៉ាន់ ស្រៀង |
| | ភិក្ខុ យ៉ត សុវណ្ណវ័ត្ត |
| ធម្មទានដោយ | ពុទ្ធបរិស័ទនៅក្នុងនិងក្រៅប្រទេស |
| កាលបរិច្ឆេទធ្វើ | ថ្ងៃទី ០៦ ខែ វិច្ឆិកា ២០០៩ |
| ស្ថានទីធ្វើ | ទីក្រុងកូឡំបូ ប្រទេសស្រីលង្កា |

www.elibraryofcambodia.org

## អាសយដ្ឋានទំនាក់ទំនង

Yang Yim (Santathera)

Sanchi Viharaya Temple, Nawagampora Stage 02,

Orugudawatta, Colombo, **Sri Lanka**

Tell: (+94) 774 535 187

E-mail: yangyim4u2006@yahoo.com

## អាសយដ្ឋានទំនាក់ទំនងនៅស្រុកខ្មែរ

វត្តក្រាំងល្វា ភូមិក្រាំងល្វា ឃុំក្រាំងល្វា

ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ : ០៩២ ៩៣៩១៧៥. ០២៦ ៦៩០០ ២៥០


www.elibraryofcambodia.org

# មាតិការឿង

**អត្ថបទ** **ទំព័រ**


-អារម្ភកថា ........................................................ក

-ឧទ្ទិសកថា ........................................................ង

I- ពត៌មានទូទៅនៅប្រទេសស្រីលង្កានាបច្ចុប្បន្ន ....................១

II- ប្រវត្តិដើមនៃប្រជាជនសីហឡៈ ឬ ស្រីលង្កា .................... ៧

III-ការឡើងគ្រងរាជ្យរបស់វិជ័យកុមារ ............................១៧

IV-រឿងពាណិជបុរស ..................................................៣០

V- ការយាងមកកាន់កោះលង្ការបស់ព្រះសម្មាសម្ពុទ្ធ .............៣៣

១.មហិយង្គណៈ .................................................... ៣៨

២.នាគទីបៈ ......................................................... ៤១

៣.កល្យាណី ......................................................... ៤៤

VI-ព្រះបាទទេវានម្បិយតិស្សៈ ..................................... ៤៧

VII-ក្រុងអនុរាធបុរី .................................................. ៥១

១. ដើមមហាពោធិព្រឹក្ស ..........................................៥៥


www.elibraryofcambodia.org

២. ទីស្ថានដាំដើមមហាពោធិព្រឹក្ស ............................ ៥៧
៣. ថូបារាម ............................................................ ៦០
៤. ចតុត្ថសង្គាយនា ..................................................៦២
៥. ព្រះបាទទុដ្ឋគាមិនីអភ័យ ...................................... ៦៤
៦. សុវណ្ណមាលិកចេតិយ ............................................ ៧០
៧. ព្រះបាទទុដ្ឋគាមិនីអភ័យប្រគេនចង្ហាន់បិណ្ឌបាតព្រះសង្ឃ...៧២
៨. លោហៈប្រាសាទ .................................................... ៧៦
៩. អភយគិរីចេតិយ .................................................... ៧៧
១០.ព្រះបាទមហាសេន ................................................ ៧៩
១១.ជេតវនចេតិយ ......................................................៨៣
១២.មិរិស្សវាយចេតិយ ..................................................៨៤
១៣.វត្តឥសុរុមុនី ........................................................ ៨៥
១៤.ព្រះពុទ្ធអនុខណៈ ....................................................៨៦
១៥.ព្រះបាទធាតុសេន .................................................. ៨៧

VIII-ភ្នំមហិន្ទលេ ...................................................... ៩០

www.elibraryofcambodia.org

១.ធម្មទូតមកកាន់នគរកោះលង្កា ........................................ ៩២
២.មន្ទីរពេទ្យ ........................................................................ ៩៥
៣.សាលាឆាន់ ........................................................................ ៩៦
៤.អម្បថលៈចេតិយ ................................................................ ៩៨
៥.គុហាព្រះមហិន្ទត្ថេរ ............................................................ ៩៩
៦.មហាសាយចេតិយ .............................................................. ១០០
៧.អារាធនាកាលៈ ................................................................. ១០១
៨.វស្សាទី១ នៃព្រះមហិន្ទត្ថេរនៅក្នុងកោះលង្កា ......................... ១០៧
៩.វត្តតម្បូលៈ ....................................................................... ១១៤
១០.ភ្នំសីគិរី ......................................................................... ១១៦
១១.វត្តអាលុវិហារ ................................................................ ១២១
១២.ព្រះពុទ្ធឃោសាចារ្យ ......................................................... ១២៣
១៣.រឿងព្រះពុទ្ធឃោសាចារ្យនៅកំពង់ផែនាកោះលង្កា ...... ១២៧
១៤.ស្នាមព្រះហស្តព្រះពុទ្ធឃោសាចារ្យ ........................... ១៣១

IX-ទីក្រុងខេនឌី ...................................................................... ១៣៥

www.elibraryofcambodia.org

១.វត្តតម្កល់ព្រះទន្តធាតុ ........................................ ១៣៦

២.ភ្នំសុមនកូដ ........................................ ១៤៣

៣.វត្តគង្គារាម ........................................ ១៤៦

៤.វត្តប៉ែលឡាវិលៈ ........................................ ១៤៨

៥.ព្រះកែវមរកត ........................................ ១៥០

X-កំណាព្យ

១.ធម្មយាត្រាទៅកាន់ប្រទេសស្រីលង្កា ........................................ ១៥៥

២.ស្តាយណាស់ ........................................ ១៥៨

៣.ធម្មនិយាម ៣០ របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ........................................ ១៦០

៤.បទសរភញ្ញ ........................................ ១៦៥

៥.បទលើកទង់ព្រះពុទ្ធសាសនា ........................................ ១៧០

៦.បទដាក់ទង់ព្រះពុទ្ធសាសនា ........................................ ១៧១

ឯកសារយោង ........................................ ១៧៣

នាមសប្បុរសជន ........................................ ១៧៥

www.elibraryofcambodia.org

# អារម្ភកថា

ខ្ញុំព្រះករុណាអាត្មាភាព បានសង្កេតឃើញមានពុទ្ធសាសនិកខ្មែរយើង ទាំងបព្វជិតទាំងគ្រហស្ថជាច្រើន ក្នុងមួយឆ្នាំៗ បាននិមន្តនិងអញ្ជើញមកប្រទេសស្រីលង្កានេះ ដើម្បីមកទស្សនានិងនមស្សការ គោរពបូជាទីពុទ្ធស្ថានទាំងឡាយ ដែលមាននៅក្នុងប្រទេសនេះ។ រាល់ពេលដែលខ្ញុំព្រះករុណា អាត្មាភាព បានជួបក្រុមពុទ្ធសាសនិកទាំងនោះ ខ្ញុំព្រះករុណាអាត្មាភាព តែងតែសាកសួរពីនេះពីនោះ ជាពិសេសអំពី ទីពុទ្ធស្ថាននានាដែលពួកគេបានធ្វើដំណើរទៅដល់ ដើម្បីចង់ដឹងពីការយល់ដឹង និងការចេះចាំអំពីពុទ្ធស្ថានទាំងនោះ។ រាល់ការសាកសួររបស់ ខ្ញុំព្រះករុណាអាត្មាភាព ចំពោះពុទ្ធសាសនិកទាំងនោះ ជាលទ្ធផលឃើញថា មានពុទ្ធសាសនិកតិចតួចណាស់ ដែលចេះចាំបានអំពីឈ្មោះនៃពុទ្ធស្ថាននានានិងរឿងរ៉ាវដែលទាក់ទងទៅនឹងទីកន្លែងនីមួយៗ។ ពុទ្ធសាសនិកនៃគណៈធម្មយាត្រាភាគច្រើន ជាមនុស្សដែលមានវ័យចំណាស់ ហើយមិនសូវមានការចងចាំនូវរឿងរ៉ាវទាំងអស់នោះបាន ទោះបីពួកគាត់ទាំងនោះមានការកត់ត្រាខ្លះៗក៏ដោយ តែការកត់ត្រាទាំងនោះ មិនអាចសរសេរឱ្យអស់នូវសេចក្តីសព្វគ្រប់បានឡើយ។ ម្យ៉ាងវិញទៀត បើទោះបីមាន

www.elibraryofcambodia.org

ការណែនាំ និងពិពណ៌នាខ្លះៗអំពីមគ្គុទ្ទេសក៍ ដែលដឹកនាំក៏ដោយ ក៏មិនអាចរៀបរាប់ឱ្យអស់សេចក្ដីអំពីប្រវត្តិរឿងរ៉ាវប្រទេសស្រីលង្កានេះបានអស់ឡើយ នោះក៏ព្រោះតែពេលវេលានៃការធ្វើដំណើរនេះមានរយៈពេលខ្លីពេក។ ហេតុផលខាងលើនេះហើយ ទើបជំរុញឱ្យខ្ញុំព្រះករុណាអាត្មាភាព ចាប់ផ្ដើមរៀបរៀងចងក្រងធ្វើជាសៀវភៅនេះឡើង ដើម្បីជាជំនួយដល់គណៈធម្មយាត្រា ដែលធ្វើដំណើរទៅកាន់ប្រទេសស្រីលង្កា។

សៀវភៅនេះមានចំណងជើងថា **"ប្រវត្តិ និង ពុទ្ធស្ថាន នៅប្រទេសស្រីលង្កា"** ។ នៅក្នុងអត្ថបទនៃសៀវភៅនេះ ខ្ញុំព្រះករុណាអាត្មាភាព បានសរសេររៀបរាប់ខ្លះៗ អំពីប្រវត្តិសង្ខេបរបស់ប្រជាជនស្រីលង្កា និងប្រវត្តិនៃទីពុទ្ធស្ថាននីមួយៗ ដើម្បីងាយដល់គណៈធម្មយាត្រាបានយល់ និងចេះចាំ។ មានពាក្យពេចន៍មួយចំនួន នៅក្នុងសៀវភៅនេះពិតជាមានការពិបាកអានបន្តិច ដូចជាឈ្មោះទីកន្លែង និងឈ្មោះរបស់មនុស្សជាដើម។ ម្យ៉ាងវិញទៀត នៅក្នុងអត្ថបទនៃសៀវភៅនេះប្រាកដជាមានឃ្លាប្រយោគ និងអត្ថន័យខ្លះៗ មានការពិបាកនឹងយល់ ព្រោះថាអត្ថន័យទាំងនេះ ខ្ញុំព្រះករុណាអាត្មាភាព បានសរសេរបកប្រែទៅតាមភាសាសីហឡៈ ភាសាអង់គ្លេស និងបាលីឡាតាំង ហើយកំហុសខុសឆ្គងខ្លះៗ ប្រាកដជាមានជាក់ជាមិនខាន។

www.elibraryofcambodia.org

ខ្ញុំព្រះករុណា អាត្មាភាពសង្ឃឹមថា សៀវភៅនេះនឹងបានជាប្រយោជន៍ដ៏ធំមួយ ដល់អស់លោកអ្នកដែលបានអាន ហើយនឹងបានមកទស្សនានៅប្រទេសស្រីលង្កានេះ។ ខ្ញុំព្រះករុណាអាត្មាភាព សូមអភ័យទោសរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមាននៅក្នុងសៀវភៅនេះ។ ខ្ញុំព្រះករុណា អាត្មាភាព នឹងរង់ចាំទទួលនូវមតិរិះគន់ស្ថាបនាអំពីសំណាក់អស់លោកអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់។

ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងអំណរគុណចំពោះ ព្រះទេវសត្ថា ពឿយ មេត្តា, លោកគ្រូ ធម្មាចារ្យ អឿ សៅ ,ព្រះករុណាគ្រប់ ព្រះអង្គ និងអស់លោកអ្នក ដែលបានជួយឱ្យជាមតិយោបល់ និងបច្ចេកទេសក្នុងការជួយជ្រោមជ្រែងរៀបចំឱ្យកើតចេញជាសៀវភៅនេះ។ ម្យ៉ាងវិញទៀត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះពុទ្ធបរិស័ទទាំងអស់ ដែលបានជួយឧបត្ថម្ភដល់ការសិក្សារបស់ខ្ញុំព្រះករុណា អាត្មាភាព ដូចមាននាមខាងក្រោម:

ព្រះទេវសត្ថា ពឿយ មេត្តា

ឧបាសិកា ម៉ែន-អុន

ឧបាសិកា អ៊ុក-ធូរេត ព្រមទាំងក្រុមគ្រួសារ

www.elibraryofcambodia.org

ឧបាសិកា យឹម-ម៉ាស៊ី

ឧបាសិកា អៀប ឆែតឹម និង ឧបាសក ឡូ ប៊ុនឡេង

ឧបាសិកា ឈាង-ឈុន

ឧបាសិកា ភន ស៊ាងហៃ ព្រមទាំងបុត្រ

ឧបាសិកា សៀង ជា និងក្រុមគ្រួសារ

សូមប្រសិទ្ធិពរជ័យ ប្រគេននិងជូនដល់ ព្រះករុណាគ្រប់ព្រះអង្គ និង ញាតិញោមពុទ្ធបរិស័ទទាំងអស់ សូមឱ្យបានជួបប្រទះនូវពុទ្ធពរទាំងឡាយ៤ ប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ និង សូមឱ្យបានសម្រេចនូវធម៌ជាន់ខ្ពស់ និងបានរួចចាក់ទុក្ខទាំងពួង កុំបីខានឡើយ ។

**អ្នករៀបរៀង**

**ភិក្ខុ យ៉ង់ យឹម សន្តោរ**

**ស្រីលង្កា.ថ្ងៃទី ០៦ ខែ វិច្ឆិកា** **ព.ស.២៥៥៣**
**គ.ស.២០០៩**

www.elibraryofcambodia.org

# ឧទ្ទិសកថា

ខ្ញុំព្រះករុណា អាត្មាភាព សូមផ្សាយនូវមហាកុសលជាធម្មទាននេះ ជូនចំពោះ បុព្វការីជន មានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ និង ញាតិកាទាំងប្រាំពីរសន្តាន ទាំងអ្នករស់នៅ និងអ្នកដែលបានចែកឋានទៅហើយ សូមឱ្យបាននូវចំណែកនៃកុសលនេះគ្រប់គ្នា ។

ម្យ៉ាងវិញទៀត សូមថ្វាយ និងជូននូវមហាកុសលនេះចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ, ញាតិញោមពុទ្ធបរិស័ទទាំងអស់ ក្នុងនិងក្រៅប្រទេស មួយអន្លើដោយសព្វសត្វទាំងអស់ក្នុងសង្សារវដ្ត សូមទ្រង់ត្រេកអរ និង ត្រេកអរ អនុមោទនាយកចំណែកនៃបុណ្យ ដែលកើតឡើងពីការរៀបរៀងសៀវភៅនេះ ដើម្បីបានជាឧបនិស្ស័យក្នុងការត្រាស់ដឹងនូវអរិយសច្ចធម៌ កុំបីខានឡើយ ។

**សូមអនុមោទនា !**



www.elibraryofcambodia.org

www.elibraryofcambodia.org

# ពត៌មានទូទៅនៅប្រទេសស្រីលង្កា

ប្រទេសស្រីលង្កា គឺជាកោះមួយដែលស្ថិតនៅក្នុងមហាសមុទ្រឥណ្ឌាភាគខាងត្បូង ដែលមានចំងាយប្រមាណ២០ម៉ៃ (៣២.១៨គីឡូម៉ែត្រ) ពីប្រទេសឥណ្ឌា ត្រង់ផ្នែកតូចខាងលើ។ ប្រទេសស្រីលង្កានេះមានឈ្មោះជាច្រើន ដែលបានប្រើកាលតាំងពីសម័យបុរាណកាលដូចជា: សីហឡទ្វីប រតនទ្វីប លង្កាទ្វីប ធម្មទ្វីប តម្ពបណ្ណិទ្វីបជាដើម។ ប្រទេសនេះមានទីក្រុងសំខាន់ៗចំនួន ៤ គឺ : ក្រុងអនុរាធបុរី ក្រុងប៉ុឡូណារុវៈ ក្រុងខេនឌី និងរដ្ឋធានីបច្ចុប្បន្នឈ្មោះ កូឡុំបូ។

ប្រទេសនេះកាលពីសម័យដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ ព្រះអង្គទ្រង់ធ្លាប់បានយាងមក ៣ ដងគឺ មហិយង្គណៈ, នាគទីបៈ និង កល្យាណី។ នៅកន្លែងនីមួយៗ គេបានកសាងព្រះចេតិយទុកសម្រាប់ធ្វើសក្ការបូជាផងដែរ។ នៅក្នុង ព.ស ២៣៥ ព្រះមហិន្ទត្ថេរបាននិមន្តមកផ្សព្វផ្សាយព្រះពុទ្ធសាសនានៅកោះលង្កា។ ក្រោយមកកោះនេះ បានក្លាយទៅជាមជ្ឈមណ្ឌលផ្សព្វផ្សាយព្រះពុទ្ធសាសនាយ៉ាងសំខាន់ជាងទីណាៗទាំងអស់។ ប្រទេសស្រីលង្កា គឺជាប្រទេសមួយដែលមានលម្អទៅដោយឆ្នេរសមុទ្រ និងជួរភ្នំដែលមានព្រៃព្រឹក្សាលតាវល្លិ


www.elibraryofcambodia.org

ទន្លេ បឹងបួរ ដែលគួរឱ្យគយគន់នៃមនុស្សផងទាំងឡាយ។ ប្រទេសនេះមានផ្ទៃដីប្រមាណ ៦៥៦១០ គីឡូម៉ែត្រក្រឡា។ ពីជើងទៅត្បូងមានប្រវែង ៤៣៥ គីឡូម៉ែត្រ. ពីកើតទៅលិច មានប្រវែង ២២៥គីឡូម៉ែត្រ កោះនេះចែកចេញជា ៣ តំបន់គឺ: ១ តំបន់ដីសណ្ត, ២ តំបន់ខ្ពង់រាប, ៣ តំបន់ភ្នំ។

## ភ្នំ

ភ្នំដែលខ្ពស់ៗនៅក្នុងប្រទេសស្រីលង្កានេះ មាន ៥ គឺ:
១-ភ្នំបិណ្ឌុរុតលគលៈ (Pidurutalagala) ដែលស្ថិតនៅក្នុងតំបន់ភូមិភាគកណ្តាល ហើយភ្នំនេះមានកំពស់ ៨២៨១ហ្វីត (២៥២៤ ម៉ែត្រ),
២-ភ្នំកុតបូលៈ(Kotapola) មានកំពស់ ៧៧៤១ហ្វីត (២៣៥៩ ម៉ែត្រ),
៣-ភ្នំសុមនកូដ (Sumanakuda)កំពស់ ៧៣៦០ ហ្វីត (២២៤៣ ម៉ែត្រ),
៤-ភ្នំក្នុកកលៈ (Knuckles)កំពស់ ៦១១២ ហ្វីត (១៨៦២ ម៉ែត្រ),
៥-ភ្នំនមុន្នុកុលៈ (Namunukula)កំពស់ ៦០៧១ហ្វីត (១៨៥០ ម៉ែត្រ)។


www.elibraryofcambodia.org

## ស្ទឹង

ស្ទឹងសំខាន់ៗ ដែលមាននៅក្នុងប្រទេសស្រីលង្កាទាំងអស់សុទ្ធតែមានប្រភពចេញមកពីតំបន់ភ្នំនៃភូមិភាគកណ្ដាល។ ស្ទឹងដែលធំហើយវែងជាងគេនៅក្នុងប្រទេសស្រីលង្កានេះឈ្មោះថាមហាវេលិ (Mahaveli) ដែលមានប្រវែង ៣៣៥ គីឡូម៉ែត្រ មានប្រភពទឹកចេញមកពីភ្នំសុមនកូដ ហើយហូរចាក់ចូលទៅសមុទ្រ នៅត្រង់តំបន់ទ្រីនកូណាមាលី (Trinconamalee)។ នៅភូមិភាគខាងកើត មានស្ទឹងកល្យាណី (Kelani Ganga) ប្រវែង ១៤៥ គីឡូម៉ែត្រ, ស្ទឹងវ៉ាឡាវេ (Walave Ganga) មានប្រវែង ១៣៥ គីឡូម៉ែត្រ និងស្ទឹងកាលុ (Kalu Gaga) មានប្រវែង ១២៩ គីឡូម៉ែត្រ។ ស្ទឹងនៅក្នុងប្រទេសស្រីលង្កាទាំងអស់មាន ៣៦ និងអាងទឹកសំខាន់ៗមាន ១០៣។

## ប្រជាជន

ប្រជាជនស្រីលង្កាប្រកបរបរកសិកម្ម ហើយដំណាំដែលសំខាន់ជាងគេនោះមាន៖ស្រូវ តែ កៅស៊ូ និង ដូង។ សព្វថ្ងៃប្រទេសស្រីលង្កាមានប្រជាជនប្រមាណ ២០លាននាក់ ក្នុងនោះប្រជាជនដើមកំណើតសីហឡ: មាន ៧៤ ភាគរយ, ប្រជាជនទមិឡ មាន ១២.៦ ភាគរយ,

www.elibraryofcambodia.org

ប្រជាជនអ៊ីស្លាម មាន ៥.៥ ភាគរយ, និងប្រជាជនជាតិសាសន៍ផ្សេងៗ មាន៧.១ភាគរយ ។

កាលពីសម័យដើម ប្រជាជនស្រីលង្កាស្ទើរតែទាំងអស់បានកាន់ព្រះពុទ្ធសាសនា ប៉ុន្តែដោយសម័យខាងក្រោយមក មានពួកបរទេសចូលមកធ្វើជំនួញ និងគ្រប់គ្រងនៅក្នុងប្រទេសនេះ ក៏បានធ្វើឱ្យប្រជាជនប្ដូរយកជំនឿ ទៅក្នុងសាសនាផ្សេងៗដូចជា សាសនាហិណ្ឌូ សាសនាគ្រិស្ត សាសនាអ៊ីស្លាម ។ល។ សព្វថ្ងៃប្រជាជនស្រីលង្កាមានចំនួនប្រមាណ ៧២ភាគរយ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា, ១៥.៥ភាគរយ អ្នកកាន់សាសនាហិណ្ឌូ, ៧.៥ភាគរយ អ្នកកាន់សាសនាគ្រិស្ត និង ៧.១ភាគរយ អ្នកកាន់សាសនាអ៊ីស្លាម ។ ចំណែកឯប្រពៃណីក្នុងការរៀបមង្គលការ មានរបៀបខុសអំពីខ្មែរ ព្រោះថានៅប្រទេសនេះគឺស្រីដណ្ដឹងប្រុស ។

## ភាសា

ភាសាជាតិរបស់ប្រជាជនស្រីលង្កាគឺ ភាសាសីហឡៈ ។ ចំណែកឯភាសាធំៗដែលប្រើជាផ្លូវ ការនោះមាន៣ គឺៈ ភាសាសីហឡៈ ភាសាទមិឡ និង ភាសាអង់គ្លេស ។

www.elibraryofcambodia.org

# អាកាសធាតុ

Temperature Chart

| Area | Jan-April | | May-August | | Sept-Dec | |
|---|---|---|---|---|---|---|
| | Max. | Min. | Max. | Min. | Max. | Min. |
| Colombo | 30OC | 22OC | 30OC | 24OC | 29OC | 22OC |
| Kandy | 31OC | 17OC | 29OC | 21OC | 28OC | 18OC |
| Nuwara Eliya | 21OC | 14OC | 18OC | 16OC | 18OC | 15OC |
| Trincomalee | 32OC | 24OC | 33OC | 25OC | 33OC | 23OC |

Sri Lanka has no marked seasons.

ស្រីលង្កាជាប្រទេសមួយ ដែលស្ថិតនៅតំបន់ត្រូពិក ហើយគ្មានឯកសារណាមួយបញ្ជាក់អំពីរដូវភ្លៀងឬរដូវប្រាំងច្បាស់លាស់នោះទេ ។ ចាប់ពីខែឧសភាដល់ខែកញ្ញា ប្រទេសនេះទទួល ទឹកភ្លៀងពីរបបខ្យល់មូសុង ដែលបក់ពីទិសនិរតី នាំទឹកភ្លៀងទៅស្រោចស្រប់នៅតំបន់ភាគខាងលិច ។ ចាប់ពីខែធ្នូ ដល់ខែកុម្ភៈ ទទួលភ្លៀងពីរបបខ្យល់មូសុង ដែលបក់មកអំពីទិសឦសាន ដែលនាំភ្លៀងទៅស្រោចស្រប់នៅតំបន់ភាគខាងកើត ។ នៅតំបន់ផ្សេងៗទៀតមានភ្លៀងធ្លាក់ មិនទៀងទាត់ នោះទេ ។



www.elibraryofcambodia.org





សកម្មភាពរបស់ព្រះសង្ឃដែលកំពុងកសាងពុទ្ធិកបឋមសិក្សា ស្ថិតនៅ

ក្នុងវត្តឧទុម្ពរ ( ក្រាំងល្វា) ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

(២០០៧)

ឧបត្ថម្ភដោយ ឧបាសិកា អៀប ឆៃគីម និង ឧបាសក ឡូប៊ុនឡេង

ក្រោមការដឹកនាំ ដោយព្រះតេជគុណ **សន្តត្ថេរ ឃឹង ឃឹម**

www.elibraryofcambodia.org

# ប្រវត្តិដើមនៃប្រជាជនសីហឡៈ ឬ ស្រីលង្កា

ក្នុងកាលកន្លងទៅ មានព្រះរាជាមួយព្រះអង្គ ដែលគ្រងរាជ្យនៅក្នុងដែនវង្គៈ ព្រះអង្គបានរៀបអភិសេកជាមួយនិងព្រះរាជបុត្រីក្នុងដែនកលិង្គៈ។ ដោយការរួមរស់នៅជាមួយគ្នា ព្រះអង្គទ្រង់បានប្រសូត្រព្រះរាជបុត្រីមួយព្រះអង្គ។ ដោយព្រះរាជបុត្រីមានរូបសម្បត្តិដ៏ស្រស់ស្អាត ព្រះមាតានិងព្រះបិតា ទ្រង់មានសេចក្ដីស្រឡាញ់ចំពោះព្រះនាងយ៉ាងខ្លាំង។ នៅពេលដែលព្រះរាជបុត្រីមានវ័យធំឡើង ព្រះមាតានិងព្រះបិតា បានអញ្ជើញហោរាមកទស្សន៍ទាយអំពីជោគវាសនារបស់ព្រះរាជបុត្រី។ ហោរាបានទស្សន៍ទាយថា ព្រះរាជបុត្រីអង្គនេះ នឹងមានព្រះស្វាមីជាស្ដេចសត្វ។ ព្រះរាជាក្រោយអំពីទ្រង់បានជ្រាបនូវរឿងនេះ ព្រះអង្គក៏មិនបានធ្វើទុក្ខទោសអ្វីដល់ព្រះរាជបុត្រីនោះដែរ តែព្រះអង្គពិបាកព្រះទ័យ និងខ្មាស់ប្រជានុរាស្ត្រយ៉ាងខ្លាំង ចំពោះវាសនាដ៏អាក្រក់នៃព្រះរាជបុត្រីរបស់ព្រះអង្គ។ ព្រះរាជបុត្រីនៅពេលដែលបានជ្រាបនូវរឿងនេះ និងដោយឃើញថា ព្រះមាតានិងបិតាទ្រង់ពិបាកព្រះទ័យដោយសារតែខ្លួនដូច្នោះ ព្រះនាងក៏បានរៀបចំតុបតែងបន្លំខ្លួនធ្វើជាអ្នកជំនួញ លួចរត់ចេញពីព្រះបរមរាជវាំងតែមួយព្រះអង្គឯង រួចទៅ

www.elibraryofcambodia.org

ចូលរួមដំណើរជាមួយនិងអ្នកជំនួញឯទៀត ដែលកំពុងតែធ្វើដំណើរទៅកាន់ដែនមគធៈ។ ការធ្វើដំណើររបស់ក្រុមពួកអ្នកជំនួញទាំងនេះត្រូវឆ្លងកាត់ដែនឡាលៈ ទីនេះគឺសម្បូរទៅដោយព្រៃព្រឹក្សា ដែលជាទីជម្រករបស់ពពួកសត្វព្រៃសាហាវៗ និងក៏ជាទីជម្រកនៃស្តេចសត្វផង។ នៅពេលដែលពួកអ្នកជំនួញទាំងនោះ បានមកដល់ដែនឡាលៈ ពពួកសត្វសាហាវទាំងឡាយ ក៏បានចេញមកយាយី ចាប់មនុស្សនិងគោក្របីស៊ីធ្វើជាអាហារ។ មនុស្សម្នាទាំងឡាយ នៅពេលដែលបានឃើញគ្រោះអាសន្នកើតមានដល់ខ្លួនដូច្នោះ ក៏បាននាំគ្នារត់ទៅកាន់ទីផ្សេងៗអស់ទៅ។ ចំណែកឯព្រះនាងនោះវិញ បានរត់គេចទៅតាមផ្លូវមួយដែលស្តេចសត្វបានមក។ ក្រោយពេលដែលស្តេចសត្វសីហៈ ចាប់មនុស្សម្នា និងគោក្របីស៊ីជាចំណីអាហាររួច ស្តេចសត្វក៏បានចាកចេញអំពីទីនោះ ហើយត្រឡប់ទៅកាន់ទីកន្លែងរបស់ខ្លួនវិញ។ ពេលនោះស្តេចសត្វបានត្រឡប់ទៅតាមផ្លូវដែលខ្លួនបានមក ហើយបានមើលឃើញព្រះនាងអំពីចម្ងាយក៏កើតនូវសេចក្តីប្រតិព័ទ្ធចំពោះព្រះនាងភ្លាម ស្តេចសត្វបានដើរឆ្ពោះទៅរកព្រះនាង ទាំងមានកន្ទុយ និងត្រចៀកបក់រវិចៗ ក្នុងន័យបញ្ជាក់នូវសេចក្តីស្នេហាចំពោះព្រះនាង។ នៅពេលដែលព្រះនាងបានក្រឡេក


www.elibraryofcambodia.org

មើលខាងក្រោយ ឃើញស្ដេចសត្វកំពុងតែដើរតម្រង់មករកខ្លួនយ៉ាង ដូច្នោះ ព្រះនាងបាននឹកឃើញទៅដល់ពាក្យទំនាយរបស់ហោរាពេលនោះ ព្រះនាងពុំមានសេចក្ដីតក់ស្លុតអ្វីឡើយ ។ ពេលដែលស្ដេចសត្វដើរមក ដល់ ព្រះនាងក៏បានយកដៃដ៏ស្រលូនរបស់នាងទៅស្ទាបអង្អែលលើខ្លួន ស្ដេចសត្វ។ ស្ដេចសត្វកើតនូវតម្រេកតណ្ហាយ៉ាងខ្លាំង ខ្លួនក៏បានបន្ទាប ខ្នងឱ្យព្រះនាងឡើងជិះ រួចនាំទៅកាន់គុហា ដែលជាទីលំនៅរបស់ខ្លួន ដោយល្បឿនយ៉ាងលឿន។ ដោយការរួមរស់ជាមួយគ្នារវាងស្ដេចសត្វ និងព្រះនាង, ព្រះនាងបានប្រសូត្រព្រះរាជបុត្រភ្លោះ គឺប្រុសមួយអង្គ ស្រីមួយអង្គ។ ព្រះរាជបុត្រាច្បង ដែលមានដៃនិងជើងដូចជាស្ដេច សត្វសីហ: ព្រះមាតាបានដាក់ព្រះនាមថាសីហពាហុ ហើយដាក់ព្រះនាម ឱ្យព្រះរាជបុត្រីថា សីហសីវលី ។ នៅពេលដែលពួកគេទាំងពីរមានវ័យ ១៦ឆ្នាំ ព្រះរាជបុត្រាកើតមាននូវចម្ងល់ ហើយក៏បានទូលសួរ ព្រះមាតាថា តើយើងមកអំពីទីណា? ហេតុអ្វីបានជាព្រះមាតា និង ព្រះបិតាមានភាពខុសគ្នាយ៉ាងដូច្នេះ? ដោយការជជីកសួរជាច្រើនដង ពេក ព្រះមាតាក៏បានរៀបរាប់ប្រាប់នូវរឿងរ៉ាវទាំងអស់ដល់បុត្រទាំង ពីរ ។ ព្រះរាជបុត្របានទូលសួរតទៅទៀតថា ចុះហេតុអ្វីបានជាពួក

www.elibraryofcambodia.org

យើងមិនរត់ចេញអំពីទីនេះ? ព្រះមាតាក៏បានប្រាប់ថា បុត្រដឹងទេ ព្រះបិតារបស់បុត្រ នៅពេលដែលគាត់ចេញទៅរកចំណីអាហារម្តងៗ គាត់តែងតែយកដុំថ្មមកបិទច្រកគុហា មិនឱ្យមាតាចេញទៅណាបានឡើយ។ ពេលនោះសីហពាហុ ដែលជាបុត្រនិងជាអ្នកមានកំលាំងខ្លាំង បានបើកនូវថ្មដែលបិទគុហានោះដោយផ្ទាល់ដៃរបស់ខ្លួន ហើយក៏លើកព្រះមាតាដាក់នៅលើស្មាខាងស្តាំ និងព្រះរាជកនិដ្ឋា (ប្អូនស្រី) ដាក់នៅលើស្មាខាងឆ្វេង ហើយនាំរត់ចេញអំពីទីនោះ ដោយល្បឿន ៥០យោជន៍ ក្នុងមួយថ្ងៃ រហូតបានមកដល់ជនបទមួយក្នុងដែនវង្គៈ។ ពួកគេទាំងបីនាក់នេះ បានយកស្លឹកឈើធ្វើជាសំលៀកបំពាក់ដើម្បីបិទបាំងរាងកាយរបស់ពួកគេ។ នៅក្នុងជនបទនោះ កាលណោះមានមេទ័ពម្នាក់ ដែលជាកូនរបស់ព្រះបិតុលា (ឪពុកធំ)របស់ព្រះរាជា ជាអ្នកការពារនៅទីនោះ។ ពេលនោះឯង មេទ័ពកំពុងតែអង្គុយនៅក្រោមដើមឈើ បានឃើញមនុស្សចម្លែកទាំងបីនាក់ ដើរចូលមករកគាត់ ទើបសាកសួរពួកគេថា តើពួកអ្នកឯងជានរណា? ពួកគេក៏បានឆ្លើយថា ពួកយើងគឺជាមនុស្សព្រៃ។ នៅពេលដែលមេទ័ពបានឮដូច្នោះ ក៏មានចិត្តអាណិតអាសូរ ហើយបានទៅសុំឱ្យប្រជាជនដែលរស់នៅទីនោះ ជួយផ្តល់នូវ


www.elibraryofcambodia.org

សំលៀកបំពាក់ដល់ពួកគេទាំងបី។ នៅពេលដែលពួកគេទាំងបីបានយក សំលៀកបំពាក់ ដែលអ្នកស្រុកបានឱ្យនោះមកពាក់ សំលៀកបំពាក់ទាំងនោះ ក៏បានក្លាយទៅជាសំលៀកបំពាក់ដ៏ប្រណីត។ បន្ទាប់មក មេទ័ព បានឱ្យគេរៀបចំម្ហូបអាហារដាក់នៅលើស្លឹកឈើ ហើយឱ្យអ្នកទាំងបីបរិភោគ។ ដោយបុណ្យបារមីរបស់ពួកគេ ស្លឹកឈើដែលដាក់អាហារនោះ ក៏បានក្លាយទៅជាចានមាស និងអាហារដ៏ប្រណីត។ មេទ័ព និងអ្នកស្រុក បានឃើញនូវហេតុដ៏អស្ចារ្យនោះ ក៏សួរទៅអ្នកទាំងបីថា តើអ្នកឯងទាំងបីជាអ្វី? ពេលនោះ ព្រះនាងដែលជាព្រះមាតាបានប្រាប់ទៅមហាជននិងមេទ័ព អំពីឈ្មោះនិងវង្សត្រកូលរបស់ខ្លួន ដើម្បីឱ្យមនុស្សម្នាទាំងអស់បានជ្រាប។ មេទ័ពបានឮដូច្នោះ ក៏មានការរន្ធត់ចិត្តយ៉ាងខ្លាំង ហើយបាននាំអ្នកទាំងបីទៅកាន់ដែនវង្គៈ ដើម្បីគាល់ព្រះរាជា។ ក្រោយមកមេទ័ពបានសុំព្រះរាជានុញ្ញាត ដើម្បីរៀបការជាមួយព្រះនាងនាពេលនោះទៅ។

ថ្លែងអំពីស្ដេចសត្វនោះវិញម្ដង នៅពេលដែលត្រឡប់មកពីរកចំណីវិញ មិនបានឃើញភរិយា និងកូនជាទីស្រឡាញ់ ក៏កើតទុក្ខរីងរៃយ៉ាងខ្លាំង សូម្បីតែទឹកមិនផឹកចំណីក៏មិនស៊ី។ ពីមួយថ្ងៃទៅមួយថ្ងៃ


www.elibraryofcambodia.org

ស្តេចសត្វបានដើរស្វែងរកភរិយានិងកូនគ្រប់ទិសទី និងគ្រប់និគមជនបទ ដែលស្តេចសត្វបានទៅដល់ តែងតែធ្វើទីនោះឱ្យដល់នូវក្តីវិនាសទាំងផ្ទះសម្បែងនិងអាយុជីវិតមនុស្សសត្វជាច្រើន នៅគ្រប់ស្រុកនិគមនោះៗ។ ពួកមនុស្ស ដែលបានរងនូវគ្រោះអាសន្ន ដែលបង្កឡើងដោយស្តេចសត្វ បាននាំគ្នាមីម្នាទៅទូលថ្វាយព្រះរាជា ដើម្បីឱ្យព្រះអង្គជួយបង្ក្រាបស្តេចសត្វនោះ។ ព្រះរាជាពុំអាចចេញទៅបង្ក្រាបស្តេចសត្វសីហៈដោយខ្លួនព្រះអង្គផ្ទាល់បាន ព្រះអង្គបានប្រកាសរកអ្នកក្លាហាន ដើម្បីចេញទៅបង្ក្រាបស្តេចសត្វដែលតែងដើររាតត្បាតភូមិស្រុកថា បើសិនជានរណាមានសមត្ថភាពអាចសម្លាប់ស្តេចសត្វនោះបាន យើងនឹងប្រទានរង្វាន់ ១000កហាបណៈ។ ប៉ុន្តែពេលនោះ ពុំមាននរណាម្នាក់ហ៊ានស្ម័គ្រចិត្តទៅសម្លាប់ស្តេចសត្វនោះឡើយ។

ព្រះរាជាទ្រង់បានធ្វើនូវសេចក្តីប្រកាសជាលើកទីពីរទៀតថា: បើសិនជានរណាអាចសម្លាប់ស្តេចសត្វនោះបាន យើងនឹងប្រទានរង្វាន់ ២000កហាបណៈ។ សីហពាហុ ពេលដែលបានឮសេចក្តីប្រកាសដូច្នោះ បានសុំការអនុញ្ញាតពីព្រះមាតា ដើម្បីចេញទៅសម្លាប់ស្តេចសត្វដែលត្រូវជាព្រះបិតា ប៉ុន្តែត្រូវបានព្រះមាតាហាមឃាត់ទាំងពីរលើក។ ជា


www.elibraryofcambodia.org

លើកទីបី ព្រះរាជាបានធ្វើសេចក្ដីប្រកាសទៀតថា បើសិនជានរណាអាចចេញទៅសម្លាប់ស្ដេចសត្វនោះបាន យើងនឹងប្រទានមាស ៣០០០ ដំឡឹង ។ ដោយបានឮសេចក្ដីប្រកាសនេះម្ដងហើយម្ដងទៀត សីហពាហុ បានសម្រេចចិត្តចេញទៅទទួលយកមាស ៣០០០ដំឡឹង ដោយពុំបានទៅសុំការអនុញ្ញាតអំពីព្រះមាតាខ្លួនទៀតឡើយ ។ ពួកមន្ត្រីទាំងឡាយបានឃើញនូវសេចក្ដីក្លាហានរបស់បុរសវ័យក្មេង (សីហពាហុ) ក៏បាននាំចូលទៅគាល់ព្រះរាជា ។ ព្រះរាជាមានបន្ទូលទៅកាន់សីហពាហុនាពេលនោះថា: បើសិនជាអ្នកអាចសម្លាប់ស្ដេចសត្វនោះបានមែន យើងនឹងប្រទានរាជសម្បត្តិព្រមទាំងនគររបស់យើងទាំងមូលឱ្យទៅអ្នក ។

សីហពាហុ នៅពេលដែលបានឮបន្ទូលរបស់ព្រះរាជាដូច្នោះ ក៏មានចិត្តរីករាយយ៉ាងខ្លាំង ហើយក៏ថ្វាយបង្គំលាព្រះរាជា ដើម្បីធ្វើដំណើរទៅសម្លាប់ស្ដេចសត្វថ្វាយព្រះអង្គ ។ សីហពាហុបានធ្វើដំណើរទៅកាន់គុហា ដែលស្ដេចសត្វបានអាស្រ័យនៅ ស្ដេចសត្វក្រឡេកឃើញកូនអំពីចម្ងាយ ដោយសេចក្ដីនឹករលឹកចំពោះកូនផងនោះ បានរត់សំដៅមករកកូនយ៉ាងលឿន ។ ពេលនោះសីហពាហុ បានឃើញស្ដេចសត្វមិនមានការប្រុងប្រយ័ត្ន បានលើកធ្នូបាញ់សំដៅទៅស្ដេចសត្វដែលជា


www.elibraryofcambodia.org

បិតា ព្រួញក៏បានរត់ទៅចំក្បាលរបស់ស្តេចសត្វ។ ក៏បានខំប្រឹងននៀល មករកកូនទៀត ប៉ុន្តែត្រូវសីហពាហុលើកធ្នូបាញ់ហើយបាញ់ទៀត រហូតស្តេចសត្វមកដួលស្លាប់ នៅទៀបជើងរបស់ខ្លួន។ សីហពាហុបានកាត់ក្បាលស្តេច សត្វដែលជាឪពុកយកទៅថ្វាយដល់ព្រះរាជា។ នៅពេលដែលសីហពាហុ ត្រឡប់មកដល់នគរវិញ ព្រះរាជាបានចូលទិវង្គតអស់រយៈពេលប្រាំពីរថ្ងៃទៅហើយ។ ដោយគ្រានោះ ព្រះរាជាពុំមានរាជបុត្រស្នងរាជបន្ត ប្រជានុរាស្ត្រនិងក្រុមមន្ត្រីទាំងឡាយ ពេញចិត្តនឹងចរិតលក្ខណៈរបស់សីហពាហុ ក៏បាននាំគ្នាតែងតាំងព្រះរាជកុមារអង្គនេះ ឱ្យគ្រងរាជ្យធ្វើជាស្តេចបន្តអំពីព្រះរាជាអង្គមុន។ សីហពាហុបានទទួលព្រមធ្វើជាស្តេចគ្រងរាជ្យ តែក្រោយមកព្រះអង្គក៏បានប្រគល់រាជ្យសម្បត្តិឱ្យទៅព្រះមាតា និងព្រះបិតាចុងរបស់ខ្លួន គ្រងរាជ្យជំនួសវិញ។ ចំណែកឯសីហពាហុបានធ្វើដំណើរជាមួយនិងសីហសីវលី ដែលជាប្អូនស្រីទៅកាន់ដែនឡាលៈ ដែលជាទីកំណើតរបស់ខ្លួន ហើយក៏បានបង្កើតនគរមួយនៅទីនោះ ដោយដាក់ឈ្មោះថា សីហបុរៈ។ ក្រោយពីបានបង្កើតនគររួចហើយ សីហពាហុបានរៀបអភិសេកជាមួយ សីហសីវលីដែលជាប្អូនស្រី ឱ្យធ្វើជាអគ្គមហេសី។ ដោយការរួមរស់ជាមួយគ្នា អស់


www.elibraryofcambodia.org

រយៈពេលដ៏យូរ សីហពាហុ និងសីហសីវលី បានប្រសូត្របុត្រភ្លោះចំនួន ១៦ ដង (៣២ នាក់)។ បុត្រច្បងព្រះនាមវិជ័យកុមារ និងបុត្របន្ទាប់ព្រះនាមសុមិត្តា។ ព្រះបាទសីហពាហុ បានអភិសេកព្រះរាជបុត្រវិជ័យឱ្យធ្វើជារាជទាយាទ ដើម្បីស្នងរាជសម្បត្តិបន្តអំពីព្រះអង្គ។ វិជ័យកុមារ និងបរិវារទាំង ៧០០នាក់ គឺជាមនុស្សអសីលធម៌ និងតែងតែប្រព្រឹត្តធ្វើនូវអំពើទុច្ចរិតផ្សេងៗ ព្រមទាំងបង្កឱ្យមានអំពើហឹង្សារនិងចលាចលនៅក្នុងនគរ ក៏បានបណ្តាលធ្វើឱ្យប្រជានុរាស្ត្រខឹងសម្បាយ៉ាងខ្លាំង។ ក្រោយមកប្រជានុរាស្ត្រ បានយកបញ្ហានេះទៅទូលថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់បានជ្រាបនូវរឿងនេះហើយ ព្រះអង្គក៏បានទូន្មានវិជ័យកុមារ និងបរិវារមិនឱ្យប្រព្រឹត្តិធ្វើនូវអំពើអាក្រក់ផ្សេងៗ និងឱ្យមកប្រព្រឹត្តិធ្វើនូវអំពើល្អវិញ ប៉ុន្តែពួកគេមិនព្រមធ្វើតាមព្រះអង្គឡើយ។ លើកទីពីរ និងលើកទីបី ប្រជានុរាស្ត្របាននាំគ្នាទៅទូលថ្វាយព្រះរាជា អំពីទង្វើអាក្រក់ដែលវិជ័យកុមារនិងបរិវារបង្កឡើងទៀត។ ពេលនោះឯង ប្រជានុរាស្ត្របាននាំគ្នាសុំឱ្យព្រះរាជាសម្លាប់ព្រះរាជបុត្រ និងបរិវារនោះចោល។ ពេលនោះព្រះរាជាទ្រង់ខ្វាល់យ៉ាងខ្លាំង ព្រះអង្គក៏បានស្តីបន្ទោស ហើយនិងបានបញ្ជាឱ្យគេចាប់វិជ័យកុមារ និងបរិវារ ទាំង ៧០០នាក់ មកកោរសក់


www.elibraryofcambodia.org

មួយចំហៀងក្បាល ហើយនិរទេសពួកគេ និងប្រពន្ធកូនទាំងអស់ទៅតាមសំពៅផ្សេងៗគ្នា។ ពួកគេទាំងនោះបានទៅដល់កោះលង្កា នៅទីកន្លែងផ្សេងៗគ្នា។ ទីកន្លែងដែលសំពៅក្មេងៗទៅដល់ឈ្មោះនាគទីប. កន្លែងដែលពួកស្ត្រីជាម្តាយបានទៅដល់ឈ្មោះ មហិឡាទិបក។ ក៏ប៉ុន្តែសំពៅរបស់វិជ័យ និងបរិវារបានទៅដល់កំពង់ផែមួយឈ្មោះ សុប្បរិកនៅភាគខាងជើងនៃទីក្រុងបុមបៃ។ ប៉ុន្តែមនុស្សម្នានៅទីនោះ មិនពេញចិត្តនឹងទង្វើរបស់វិជ័យព្រមទាំងបរិវារ ដូច្នោះពួកគេមិនអាចស្នាក់នៅទីនោះបានឡើយ។ ពួកគេក៏បានចាកចេញអំពីទីនោះ ហើយបានទៅដល់កោះលង្កា នៅតំបន់មួយឈ្មោះតម្ពបណ្ណៈ គឺនៅក្នុងថ្ងៃដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ចូលបរិនិព្វាន។

ជួនសុរិយាបំភ្លឺនៅពេលថ្ងៃ
ចន្ទពេញបូណ៌មីបំភ្លឺពេលយប់
ព្រះធម៌ល្អណាស់ភ្លឺខ្លាំងលើសលប់
ទាំងថ្ងៃទាំងយប់កម្ចាត់មោហា ។


www.elibraryofcambodia.org

# ការឡើងគ្រងរាជ្យរបស់វិជ័យកុមារ

នៅមុនពេលដែលព្រះសម្មាសម្ពុទ្ធចូលបរិនិព្វាន សក្កទេវរាជ និងពពួកទេវតាគ្រប់ឋាន បានមកប្រជុំគ្នាដើម្បីធ្វើសក្ការៈគោរពបូជាចំពោះព្រះសាស្ដាជាចុងក្រោយ ។ គ្រានោះព្រះសម្មាសម្ពុទ្ធទ្រង់បានទូលសួរទៅសក្កទេវរាជ ដែលឈរនៅជិតនឹងព្រះអង្គថា: មហារាជ! ពេលនេះតើមាននរណាបានទៅដល់កោះលង្កាហើយឬនៅ? សក្កទេវរាជបានក្រាបទូលថ្វាយព្រះសម្មាសម្ពុទ្ធថា: បពិត្រព្រះអង្គដ៏ចម្រើន! ពេលនេះ វិជ័យកុមារដែលជាបុត្ររបស់ព្រះបាទសីហពាហុ នៃដែនឡាលៈព្រមទាំងបរិវារ ៧០០នាក់ បានទៅដល់កោះលង្កានោះហើយ ។ មហារាជ! បើអញ្ចឹង សូមមហារាជជួយមើលថែរពួកគេឱ្យបានល្អផង ព្រោះថាសាសនារបស់តថាគតនឹងទៅតាំងមាំ និងយូរអង្វែងនៅកោះលង្កានោះឯង ។ នៅពេលដែលបានឮនូវព្រះបន្ទូលរបស់ព្រះសម្មាសម្ពុទ្ធដូច្នោះ សក្កទេវរាជបានលើកដៃប្រណម្យ ហើយចាត់តាំងឱ្យទេវតាមួយអង្គដែលមានពណ៌ដូចជាផ្កាឈូក ទៅមើលថែររក្សាវិជ័យកុមារ និងពួកបរិវារ នៅនាកោះលង្កានោះភ្លាម ។ ទេវតាអង្គនោះ ក្រោយពីបានទទួលការចាត់តាំងអំពីសក្កទេវរាជហើយ ក៏បានធ្វើដំណើរមកកាន់កោះ

www.elibraryofcambodia.org

លង្កាយ៉ាងប្រញាប់ ហើយក្រឡាខ្លួនធ្វើជាសមណៈមួយអង្គ គង់នៅក្រោមដើមឈើដ៏ធំមួយ។ វិជ័យកុមារនិងបរិវារ នៅពេលដែលបានឃើញនូវសមណៈនោះ ក៏បានចូលទៅរកហើយទូលសួរថាៈ បពិត្រលោកម្ចាស់ដ៏ចម្រើន តើកោះនេះឈ្មោះអ្វី? សមណៈក៏បានប្រាប់ថា កោះនេះឈ្មោះលង្កាទ្វីប។ បពិត្រលោកម្ចាស់ដ៏ចម្រើន តើទីនេះមានមនុស្សរស់នៅដែរឬទេ? អូ! ព្រះរាជកុមារ ទីនេះពុំមានមនុស្សរស់នៅទេ។ ចុះបើអញ្ចឹង តើទីនេះនឹងមានគ្រោះថ្នាក់អ្វីដល់ពួកខ្ញុំម្ចាស់ទាំងឡាយដែរឬទេ? សមណៈប្រាប់ថា ទីនេះពុំមានគ្រោះអាសន្នអ្វីនឹងកើតមានចំពោះពួកអ្នកនោះឡើយ។ នៅពេលដែលសមណៈបានប្រាប់ទៅដល់វិជ័យកុមារ និងបរិវាររួចហើយ ព្រះអង្គក៏បានយកទឹកមន្តទៅស្រោចលើខ្លួន និងយកអំបោះមកចងនៅលើដៃរបស់ពួកគេគ្រប់ៗគ្នា រួចព្រះអង្គក៏បានហោះឡើងទៅឰដ៏អាកាសបាត់ទៅ។ រំពេចនោះដែរ ស្ត្រីម្នាក់ដែលជាបម្រើរបស់នាងយក្ខិនីឈ្មោះកុវណ្ណា ក៏បានប្រាកដខ្លួនឡើង។ នៅពេលដែលបានឃើញស្ត្រីនោះហើយ ពួកបរិវាររបស់វិជ័យកុមារ ក៏បានដើរតាមនាងដើម្បីចង់ដឹងថា តើទីនេះមានភូមិរបស់អ្នកស្រុករស់នៅឬអត់។ នៅពេលដែលដើរទៅបានឆ្ងាយបន្តិច នាង


www.elibraryofcambodia.org

យក្ខិនីក៏បានក្រឡាខ្លួនធ្វើជាតាបសិនី (ស្ត្រីដែលបួសជាឥសី) ហើយទៅអង្គុយក្រោមដើមឈើក្បែរស្រះទឹក ដែលមានដើមឈូកដុះជាច្រើន។ នៅពេលដែលពួកបុរសដើរមកដល់ ហើយឃើញស្រះទឹកមានទឹកថ្លាល្អដូច្នោះ ក៏បានចូលទៅផឹក និងងូតទឹកនៅក្នុងស្រះនោះ ហើយដកក្រឡឹឈូកធ្វើជាអាហារ។ ពេលនោះ នាងតបសិនី ដែលជាយក្ខិនី បានស្រែកឡើងថា: នៅឱ្យស្ងៀម យើងនឹងចាប់ពួកអ្នកឯង ស៊ីជាចំណីក្នុងពេលឥឡូវនេះហើយ។ ដោយសារវេទមន្តរបស់នាងយក្ខិនី ពួកបុរសទាំងនោះ ក៏បានតាំងនូវស្ងៀមដូចគេចង តែនាងយក្ខិនីមិនអាចធ្វើអ្វីដល់ពួកមនុស្សទាំងនេះបាន ព្រោះពួកគេមានអំបោះវេទមន្តនៃទេវតា ដែលចង់ជាប់នៅនឹងខ្លួនរបស់ពួកគេ។ ឃើញដូច្នេះ នាងយក្ខិនី ខឹងសម្បាយ៉ាងខ្លាំង ក៏ស្ទុះទៅចាប់ពួកបុរសទាំងនោះ គ្រវែងចូលទៅក្នុងជ្រោះយ៉ាងជ្រៅ រហូតដល់អស់មនុស្សទាំង ៧០០នាក់នោះ។ វិជ័យកុមារ នៅពេលដែលបាត់បរិវារ មិនឃើញត្រឡប់មកវិញ កើតមានសេចក្តីភិតភ័យ និងព្រួយបារម្ភដល់ពួកគេទាំងនោះ ហើយក៏បានចេញទៅតាមរកដោយមានដៃកាន់អាវុធ។ នៅពេលដែលវិជ័យកុមារ បានដើរទៅដល់ស្រះទឹក បានពិនិត្យមើលនៅទីជុំវិញនៃស្រះទឹកនោះ ក៏បានឃើញតែស្នាមជើង

www.elibraryofcambodia.org

មនុស្សចុះ តែពុំឃើញមានស្នាមជើងឡើងមកវិញ ឃើញតែនាងតាបសិនីដែលជាយក្ខិនី។ វិជ័យកុមារគិតថា នាងនេះប្រាកដជាអ្នកចាប់បរិវាររបស់អញ ព្រះរាជកុមារក៏បានសួរទៅនាងយក្ខិនីនោះថា: តើនាងបាន ឃើញបរិវាររបស់ខ្ញុំមកទីនេះដែរឬទេ? នាងយក្ខិនីឆ្លើយថា: បពិត្រព្រះរាជកុមារ តើព្រះអង្គរកបរិវារទាំងនោះមកធ្វើអ្វី? ព្រះអង្គដឹងទេពួកគេបានលួចផឹក និងងូតទឹកព្រមទាំងដកក្រអូឈូក របស់ខ្ញុំឥឡូវនេះខ្ញុំបានចាប់ពួកគេបោះចូលទៅក្នុងជ្រោះជ្រៅនោះអស់ទៅហើយ។ ពេលនេះ វិជ័យកុមារដឹងច្បាស់ថា នាងតាបសិនីនេះ ប្រាកដជាយក្ខិនី ព្រោះថានាងអាចដឹងអំពីឈ្មោះ និងត្រកូលរបស់អញ។ ពេលនោះព្រះរាជកុមារបានលើកធ្នូតម្រង់ទៅនាង ហើយស្រែកគម្រាមថា: យើងនឹងសម្លាប់នាង ប្រសិនបើនាងមិនព្រមប្រគល់បរិវារមកឱ្យយើងវិញទេនោះ។ នាងយក្ខិនី ដោយសេចក្តីភ័យខ្លាចការគម្រាម និងការធ្វើទារុណកម្ម ក៏បានសូមអង្វរព្រះរាជកុមារ ដោយពោលពាក្យថា: សូមលោកម្ចាស់ទុកជីវិតរបស់ខ្ញុំ ខ្ញុំនឹងប្រគល់កោះលង្កាទាំងមូលដល់លោកម្ចាស់ ចំណែកខ្លួនខ្ញុំម្ចាស់សុខចិត្តធ្វើជាស្រីបម្រើដល់លោកម្ចាស់។ ព្រះរាជកុមារ មិនបានសម្លាប់នាងយក្ខិនីនោះទេ តែព្រះអង្គគម្រាមធ្វើឱ្យនាង

www.elibraryofcambodia.org

ភិតភ័យ និងធ្វើនូវសម្បថចំពោះមុខព្រះអង្គ។ បន្ទាប់មកព្រះរាជកុមារ បានបញ្ជាឱ្យនាងទៅនាំបរិវារទាំង ៧០០នាក់នោះត្រលប់មកវិញ នាងក៏បានទៅនាំពួកគេទាំងអស់នោះមកវិញដោយសុវត្ថិភាព។ បន្ទាប់មកទៀត វិជ័យកុមារ បានបញ្ជាឱ្យនាងទៅស្វែងរកចំណីអាហារសម្រាប់ខ្លួន និងបរិវារបរិភោគ ដោយពោលពាក្យថា ឥឡូវនេះយើងឃ្លានណាស់ ចូរនាងទៅរកអាហារឱ្យពួកយើងក្នុងពេលឥឡូវនេះភ្លាម!។ នាងយក្ខិនីក៏បានទៅនាំយកអាហារដ៏ប្រណីត និងគ្រឿងទេសផ្សេងៗអំពីសំពៅនៃពួកអ្នកជំនួញ ដែលពួកខ្លួនបានចាប់ស៊ីជាចំណីមកឱ្យពួកគេបរិភោគ។ នាងយក្ខិនី នៅពេលដែលឃើញ ព្រះរាជបុត្របានរៀបចំចំណីអាហារដែលជាចំណែករបស់ខ្លួន ឱ្យនាងដោយផ្ទាល់ដៃដូច្នោះ ក៏មានចិត្តរីករាយយ៉ាងខ្លាំង។ ភ្លាមនោះ នាងក៏បានក្រឡាខ្លួនធ្វើជាស្រីក្រមុំក្នុងវ័យ១៦ឆ្នាំ ហើយប្រដាប់នូវគ្រឿងអលង្ការដ៏ប្រណីត ហើយដើរទៅរកវិជ័យកុមារ ដែលកំពុងអង្គុយនៅក្រោមដើមឈើ។ បន្ទាប់មក នាងបាននិម្មិតធ្វើជាប្រាសាទដ៏ល្អប្រណីត នៅទៀបគល់ឈើនោះ។ នៅក្នុងទីជុំវិញនៃប្រាសាទនោះ នាងក៏បាននិម្មិតធ្វើជាប្រាសាទតូចៗសម្រាប់ពួកបរិវារទាំង៧០០នាក់ ស្នាក់នៅផងដែរ។ វិជ័យកុមារ


www.elibraryofcambodia.org

ឃើញហេតុអស្ចារ្យដូច្នោះ ក៏បានយកនាងយក្ខិនីនោះ ធ្វើជាប្រពន្ធ ហើយរួមរស់នៅជាមួយគ្នា ក្នុងប្រាសាទដ៏ប្រណីតនោះយ៉ាងសុខសាន្ត។ នៅរាត្រីនោះព្រះរាជកុមារបានឮសម្លេងតន្ត្រី និងចម្រៀងផ្សេងៗ ព្រះអង្គបានសួរទៅនាងយក្ខិនីដែលកំពុងដេកនៅក្បែរព្រះអង្គថា: នែ៎នាង! តើសម្លេងនោះ ជាសម្លេងអ្វី? នាងយក្ខិនីបានគិតថា: នេះជាឱកាសល្អសម្រាប់អញ នឹងសម្លាប់ពពួកយក្សនៅក្នុងកោះលង្កា ដើម្បីដណ្ដើមយកនគរនេះមកថ្វាយព្រះរាជបុត្រ ដែលជាព្រះស្វាមីរបស់អញ បើមិនដូច្នេះទេ ពួកយក្សទាំងអស់គេប្រាកដជាសម្លាប់អញវិញមិនខាន ដូច្នេះអញត្រូវតែដណ្ដើមយកកោះនេះមកថ្វាយ ព្រះរាជកុមារគ្រងរាជ្យវិញម្ដង។ គិតដូច្នោះហើយ នាងក៏បានទូលថ្វាយទៅព្រះរាជបុត្រថា: ទីនេះគឺជានគររបស់ពពួកយក្សឈ្មោះសិរីសវត្ថុ។ ថ្ងៃនេះគឺជាថ្ងៃមង្គលការកូនក្រមុំរបស់ស្ដេចយក្សនេះ ហើយក៏ជាពេលជួបជុំនៃពពួកយក្សដែលមានឋានៈធំៗផងដែរ។ មង្គលការនេះ មានភាពអធិកអធ័មណាស់ ហើយនឹងប្រព្រឹត្តទៅក្នុងរយៈពេលប្រាំពីរថ្ងៃ ដូច្នេះហើយទើបបានជាមានសម្លេងនេះឡើង។ បពិត្រព្រះស្វាមី! តើព្រះអង្គចង់កំចាត់ពពួកយក្សទាំងនេះ ដើម្បីកុំឱ្យមានគ្រោះនាពេលអនាគតដែរឬទេ?


www.elibraryofcambodia.org

វិជ័យកុមារក៏បានឆ្លើយថា តើឱ្យខ្ញុំកំចាត់ពពួកយក្សទាំងនេះដូចម្ដេចទៅ បើយក្សទាំងអស់សុទ្ធតែចេះបំបាំងខ្លួន ខ្ញុំមើលមិនឃើញផងនុ៎ះ។ នាងយក្ខិនី ក៏បានប្រាប់ថា: ព្រះអង្គប្រាកដជាអាច! ព្រោះថាវេទមន្តនៃការស្រែករបស់ខ្ញុំព្រះអង្គ សម្លេងនៃពពួកយក្សនឹងអាចឮយ៉ាងច្បាស់ ពេលនោះសូមព្រះអង្គលើកធ្នូបាញ់តម្រង់ទៅតាមសម្លេងនោះ ព្រួញប្រាកដជានឹងទៅទម្លុះខ្លួនពពួកយក្សទាំងនោះមិនខានឡើយ។ នៅពេលដែលបានស្ដាប់ពាក្យណែនាំរបស់នាងយក្ខិនី វិជ័យកុមារបានធ្វើតាមហើយបានសម្លាប់ពពួកយក្សអស់នាពេលនោះទៅ។

ក្រោយពីការស្នាក់នៅក្នុងនគរសិរីសវត្ថុរបស់យក្សមួយរយៈពេលមក វិជ័យកុមារ និងបរិវារ បានធ្វើដំណើរចាកចេញមកកាន់តំបន់តម្ពបណ្ណិ។ ដោយពួកគេអស់កំលាំងខ្លាំង ក៏បានអង្គុយសំរាកនៅមាត់ទឹកក្បែរសំពៅ ហើយបានយកដៃច្រត់ទៅលើដី ពេលនោះធ្វើឱ្យដៃរបស់ពួកគេទាំងអស់មានពណ៌ក្រហម។ ដូច្នេះគេក៏ឱ្យឈ្មោះកោះនេះថា: តម្ពបណ្ណិទ្វីប មានន័យថា ទ្វីបនៃជនអ្នកមានបាតដៃក្រហម។ វិជ័យកុមារ និងបរិវារក៏បានបង្កើតនគរនៅទីនេះ ហើយឱ្យឈ្មោះថា: តម្ពបណ្ណិទ្វីប។ វិជ័យកុមារ បានរស់នៅទីនេះជាមួយនឹងនាងយក្ខិនី ព្រមទាំង


www.elibraryofcambodia.org

បរិវារយ៉ាងសុខសាន្តតរៀងរហូតមក។ ព្រះបាទសីហពាហុ ចាប់តាំងពីពេលដែលទ្រង់បានសម្លាប់ស្តេចសត្វសីហៈដែលជាបិតាមក គេក៏បានហៅព្រះអង្គថាៈ សីហឡៈ ។ ដោយហេតុតែ វិជ័យកុមារជាព្រះរាជបុត្ររបស់សីហពាហុ គេក៏បានហៅព្រះអង្គថាសីហឡៈ ដូចព្រះបិតារបស់ព្រះអង្គដែរ ហើយការហៅនេះតរហូតមកដល់បច្ចុប្បន្ននេះ។

ចាប់តាំងពីបង្កើតតម្ពបណ្ណិទ្វីបនេះមក បរិវាររបស់វិជ័យកុមារម្នាក់ៗបានបង្កើតស្រុកមួយផ្សេងៗគ្នា ហើយដាក់ឈ្មោះទៅតាមឈ្មោះរបស់ពួកគេរៀងៗខ្លួន ដូចជាមន្ត្រីឈ្មោះអនុរុទ្ធៈ បានបង្កើតស្រុកមួយដោយដាក់ឈ្មោះអនុរុទ្ធគ្រាម ឧបរាជម្នាក់ឈ្មោះឧបតិស្ស បានបង្កើតស្រុកមួយឈ្មោះ ឧបតិស្សគ្រាម និងមានមន្ត្រីផ្សេងៗទៀត ក៏បានបង្កើតនូវស្រុកផ្សេងៗគ្នា ហើយបានដាក់ឈ្មោះស្រុកទាំងនោះទៅតាមឈ្មោះរបស់ពួកគេរៀងៗខ្លួនផងដែរ។ នៅពេលដែលពួកគេទាំងអស់បានកសាងស្រុកភូមិ និងមានទីជំរកសមរម្យហើយ ពួកបរិវារទាំងអស់ក៏បានមកជួបជុំគ្នានៅទីចំពោះមុខវិជ័យកុមារ ហើយនិយាយនឹងព្រះរាជកុមារថាៈ សូមព្រះអង្គទ្រង់ព្រះតម្រិះទទួលយកនូវការអភិសេកធ្វើជាស្តេចដើម្បីគ្រងរាជ្យនៅក្នុងនគរកោះលង្កានេះផងចុះ។ វិជ័យកុមារ


www.elibraryofcambodia.org

បានបដិសេធន៍នឹងការគ្រងរាជ្យ ដោយមានបន្ទូលថា ដរាបណាពុំមាន ព្រះរាជបុត្រី អំពីសក្យត្រកូលមកអភិសេកធ្វើជាអគ្គមហេសីយើងទេ នោះ យើងនឹងមិនអភិសេកគ្រងរាជ្យឡើយ។ ពួកមន្ត្រីទាំងអស់ដែល មានបំណងចង់ឱ្យព្រះរាជកុមារឡើងគ្រងរាជ្យ ក៏បានរៀបចាត់ចែងនូវ គ្រឿងបណ្ណាការ និងវត្ថុមានតម្លៃផ្សេងៗ ដើម្បីចូលទៅស្ដីដណ្ដឹងព្រះ រាជបុត្រីរបស់ព្រះបាទបិណ្ឌុ ដែលគ្រងរាជ្យនៅក្នុងដែនមធុរៈ ដើម្បីមក ធ្វើជាអគ្គមហេសីនៃព្រះរាជកុមារ។ ពួកមន្ត្រីទាំងអស់ បានរៀបចំនូវ គ្រឿងបណ្ណាការផ្សេងៗ ដើម្បីចូលទៅស្ដីដណ្ដឹងកូនក្រមុំរបស់ពួកមន្ត្រី ក្នុងដែនមធុរៈ មកធ្វើជាភរិយារបស់ពួកគេផងដែរ។

នៅពេលដែលគ្រឿងបណ្ណាការទាំងនោះ បាននាំមកដល់ដែនមធុរៈ ហើយគេក៏បានយកដំណឹង និងគ្រឿងបណ្ណាការទាំងនោះទៅទូលថ្វាយ ដល់ព្រះចៅក្រុងមធុរៈ។ ព្រះអង្គក៏បានពិភាក្សាអំពីបញ្ហានេះជាមួយ និងពួកមន្ត្រី រួចក៏សម្រេចព្រះទ័យបញ្ជូនព្រះរាជបុត្រី និងកូនក្រមុំរបស់ មន្ត្រី ប្រមាណ ១០០នាក់ ដែលបានស្ម័គ្រចិត្តទៅកាន់កោះលង្កា។ ព្រះរាជាបានចាត់ចែងនូវគ្រឿងអលង្ការ និងវត្ថុមានតម្លៃផ្សេងៗជាច្រើន


www.elibraryofcambodia.org

និងបញ្ជូននូវស្រីអ្នកបម្រើប្រមាណ ១០០នាក់ និងក្រុមគ្រួសារអំពីត្រកូល និងវណ្ណៈផ្សេងៗ ចំនួន១០០០គ្រួសារទៅជាមួយផងដែរ ។

វិជ័យកុមារ ដោយការរួមរស់ជាមួយនឹងនាងយក្ខិនី មានកូនពីរនាក់គឺប្រុសម្នាក់ និងស្រីម្នាក់ ។ នៅពេលដែលព្រះអង្គបានទទួលដំណឹងថា ព្រះរាជបុត្រីនៃក្រុងដែនមធុរៈ នឹងមកដល់កោះលង្កាក្នុងពេលដ៏ខ្លីខាងមុខហើយនោះ ព្រះអង្គក៏បានប្រាប់ទៅនាងយក្ខិនីថា នែ៎នាង! ចូរនាងចាកចេញអំពីទីនេះទៅ ចំណែកឯកូនទាំងពីរទុកនៅទីនេះចុះ ។ នៅពេលដែលនាងយក្ខិនីឮនូវការបណ្ដេញ នាងក៏សូមអង្វរដោយពាក្យអង្វរផ្សេងៗដល់ព្រះរាជកុមារសូមឱ្យអនុគ្រោះ ដើម្បីឱ្យនាងបានស្នាក់នៅជិតក្បែរនឹងព្រះអង្គ ។ ក៏ប៉ុន្តែព្រះរាជកុមារ មិនព្រមស្ដាប់នូវពាក្យអង្វររបស់នាងយក្ខិនីនេះទេ ព្រះអង្គបានប្រាប់ទៀតថា បើសិនជានាងមិនព្រមចេញអំពីទីនេះទេ យើងនឹងសម្លាប់នាងឯងនៅពេលឥឡូវនេះ ។ ដោយមានការភ័យខ្លាចផង និងដោយការសូមអង្វរព្រះរាជកុមារមិនបានសម្រេចផងនោះ នាងយក្ខិនីក៏បាននាំកូនទាំងពីរ ហើយធ្វើដំណើរទៅកាន់តំបន់ដែលយក្សគ្រប់គ្រងឈ្មោះលង្កាបុរៈ ។


www.elibraryofcambodia.org

នៅពេលដែលនាងធ្វើដំណើរមកដល់ច្រកទ្វារក្រុងរបស់ពពួកយក្ស និងដោយសេចក្តីភ័យក្លាចផងនោះ នាងក៏បានទុកកូនទាំងពីរនៅខាងក្រៅទ្វារក្រុង រួចនាងក៏ដើរចូលទៅក្នុងក្រុងតែម្នាក់ឯង។ នៅពេលដែលពួកយក្សឃើញនាងយក្ខិនីនេះចូលមកក្រុងតែម្នាក់ឯងយ៉ាងដូច្នេះ ក៏មានការព្រួយបារម្ភ និងខ្លាចនាងចូលមកយកការណ៍សម្ងាត់ផ្សេងៗផង ពេលនោះឯងមានយក្សដ៏ធំមួយ ក្នុងចំណោមយក្សទាំងឡាយបានចងនូវកំហឹងចំពោះនាង ក៏ចេញមកសម្លាប់នាងយក្ខិនីនោះនាពេលនោះទៅ។ នៅពេលយក្សដែលត្រូវជាឪពុកមានៃនាងយក្ខិនី បានចេញមកខាងក្រៅក្រុង បានឃើញកូនយក្សទាំងពីរក៏សួរថា តើអ្នកឯងទាំងពីរជាកូននរណា? ក្មេងទាំងពីរប្រាប់ទៅវិញថា ខ្ញុំទាំងពីរនាក់ជាកូនរបស់នាងកុវណ្ណាយក្ខិនី។ នៅពេលដែលយក្សជាឪពុកមាបានឮហើយក៏ប្រាប់ទៅក្មេងទាំងពីរនោះថា ម្តាយរបស់ក្មួយឯងទាំងពីរត្រូវបានគេសម្លាប់ហើយ ហើយបើសិនជាពួកគេទាំងនោះឃើញអ្នកឯងទាំងពីរនៅទីនេះ ពួកគេប្រាកដជាសម្លាប់ពួកឯងទៀតមិនខាន ដូច្នេះចូរអ្នករត់ចេញអំពីទីនេះឱ្យបានឆាប់ទៅ។ ពួកគេទាំងពីរក៏បានរត់ចេញអំពីទីនោះឆ្ពោះទៅកាន់ភ្នំសុមនកូដ ហើយពួកគេទាំងពីរបានតាំងទីលំនៅ


www.elibraryofcambodia.org

ក្នុងទីនោះរហូតដល់ពួកគេពេញវ័យធំឡើង ។ ពួកគេទាំងពីរបានយកគ្នាជាប្តីប្រពន្ធ និងបានបង្កើតកូនពូនជាចៅនៅក្នុងតំបន់នោះ រហូតដល់បានបង្កើតជាកុលសម្ពន្ធមួយឈ្មោះបុលីនដា ។

បេសកជនរបស់ព្រះបាទបិណ្ឌុនៃដែនមធុរៈ បាននាំយករាជសារ និងគ្រឿងបណ្ណាការ ព្រមទាំងកូនស្រីរបស់ពួកមន្ត្រី ដែលមានព្រះរាជបុត្រីជាប្រធាន មកថ្វាយដល់ព្រះរាជកុមារនាពេលនោះផងដែរ ។ វិជ័យកុមារនិងពួកមន្ត្រី ក៏បាននាំគ្នាមកទទួលស្វាគមន៍បេសកជន ដែលមានព្រះរាជបុត្រីជាប្រធាន និងធ្វើសេចក្តីគោរពទៅតាមប្រពៃណី និងឋានៈរបស់ពួកគេយ៉ាងសប្បាយរីករាយ ។ ពួកមន្ត្រីទាំងអស់ក៏បានរៀបចំអភិសេកវិជ័យកុមារ និងព្រះរាជបុត្រីយ៉ាងអធិកអធ៍ម ទៅតាមប្រពៃណីទំនៀមទំលាប់នាពេលនោះឯង ។ ចាប់តាំងពីពេលដែលវិជ័យកុមារ បានអភិសេកជាមួយនិងព្រះរាជបុត្រីរបស់ព្រះបាទបិណ្ឌុធ្វើជាអគ្គមហេសី ព្រះអង្គតែងតែមានចិត្តកតញ្ញូចំពោះព្រះបិតាក្មេក ជារៀងរាល់ឆ្នាំ ព្រះអង្គតែងបញ្ជូននូវវត្ថុដ៏មានតម្លៃយ៉ាងច្រើន ដើម្បីថ្វាយដល់ព្រះអង្គ ។ ថ្វីត្បិតតែវិជ័យកុមារ កាលនៅពីកុមារភាព ព្រះអង្គមានលក្ខណៈអត្តចរិតមិនសូវល្អពិតមែន តែនៅពេលដែលព្រះអង្គបានឡើង


www.elibraryofcambodia.org

គ្រងរាជ្យនៅក្នុងនគរកោះលង្កានេះ ព្រះអង្គគឺជាស្តេចដ៏ល្អ និងបានដឹកនាំនគរកោះលង្កានេះ ឱ្យឋិតនៅក្នុងសុខសន្តិភាព និងភាពរីកចម្រើនគ្រប់វិស័យ។ ព្រះបាទវិជ័យ គ្រងរាជ្យបាន៣៨ឆ្នាំ ព្រះអង្គគឺជាស្តេចទីមួយដែលបានគ្រងរាជ្យនៅក្នុងនគរកោះលង្កានេះ។ ប៉ុន្តែព្រះអង្គពុំមានបុត្រស្នងរាជសម្បត្តិបន្តឡើយ ទើបនៅពេលដែលព្រះអង្គមានវ័យចាស់ជរាហើយ ព្រះអង្គទ្រង់បានយាងព្រះអនុជ ព្រះនាមសុមិត្តា ឱ្យមកកាន់នគរកោះលង្កា ប៉ុន្តែព្រះអនុជអង្គនេះ ក៏មានវ័យចាស់ជរាណាស់ទៅហើយដែរ។ ដូច្នេះហើយទើបព្រះអង្គបញ្ជូនព្រះរាជបុត្រពៅរបស់ព្រះអង្គព្រះនាមបិណ្ឌុវាសុទេវៈ ដែលត្រូវជាក្មួយរបស់ព្រះបាទវិជ័យ ដើម្បីមកគ្រងរាជ្យបន្ត។



www.elibraryofcambodia.org

# រឿងពាណិជបុរស

(ទោសនៃការជាប់ជំពាក់ក្នុងកាម)

កាលពីអតីត ក្នុងលង្កាទ្វីបមាននគរយក្សមួយឈ្មោះសិរីសវត្ថុ។ យក្ខិនីទាំងឡាយក្នុងនគរនោះ តែងឱ្យនូវបបរនិងបាយជាដើមដល់ពួកពាណិជ ដែលមានសំពៅបែកហើយមកក្នុងទីនោះ ទើបសួរថា អ្នកទាំងឡាយមកក្នុងទីនេះ តើដោយកម្មដូចម្តេច? សំពៅយើងបែកកណ្តាលសមុទ្រ ទើបមកក្នុងទីនេះ។ យក្ខិនីទាំងនោះពោលថា ប្រពៃហើយអ្នកទាំងឡាយ ស្វាមីនៃយើងទាំងឡាយទៅជួញអស់រយៈពេលបីឆ្នាំមិនឃើញមកសោះ ប្រហែលជាស្លាប់បាត់ហើយមើលទៅ. អ្នកទាំងឡាយសុទ្ធតែជាពាណិជ. យើងទាំងឡាយនឹងបានគ្នាជាគូរកំសត់ទៅ ហើយប្រលោមនាយពាណិជទាំងនោះ ដោយអាការៈផ្សេងៗ ទើបនាំទៅនគរយក្ស។ ឯមនុស្សទាំងឡាយដែលវាចាប់បានមុនៗ វាចងដោយចំណងហើយរុញបញ្ចូលទៅក្នុងផ្ទះសម្រាប់ធ្វើការ និងយកមនុស្សដែលចាប់បានក្រោយធ្វើជាស្វាមីទៀត បើចាប់មនុស្សទាំងឡាយមិនបានក្នុងលំនៅវាៗ ត្រាច់ទៅក្នុងឆ្នេរសមុទ្រ គឺខាងនាយនគរឈ្មោះកល្យាណី ខាង

www.elibraryofcambodia.org

អាយទ្វីបរបស់នាគ។ សេចក្ដីដែលបានបរិយាយមកក្នុងខាងលើទាំងប៉ុន្មាននេះ ជាប្រវេណីរបស់យក្ខិនីទាំងឡាយនោះទេ។

ថ្ងៃមួយមានពាណិជ៥០០នាក់បែកសំពៅត្រង់ទីជិតនគរយក្ខិនី។ ពួកយក្ខិនីទាំងឡាយនោះ ក៏ប្រលោមល្បួងលួងលោមនាយពាណិជទាំងឡាយនោះ តាមរបៀបអ្នកលម្បួង (អ្នកធ្ងន់ក្នុងកាម) ហើយនាំមកនគរខ្លួន ទើបចងមនុស្សដែលចាប់បានមុន១ នោះរុញបញ្ចូលទៅក្នុងផ្ទះសម្រាប់ធ្វើការ។ យក្ខិនីច្បងយកនាយពាណិជជាច្បងធ្វើប្ដី ឯយក្ខិនីដទៃទៀត ក៏យកនាយពាណិជជាលំដាប់ៗធ្វើប្ដីដែរ លុះនាយពាណិជទាំងឡាយនោះ ចុះសិប់កាន់និទ្រានារាត្រីកាល វាក៏ក្រោកសន្សឹមៗទៅស៊ីមនុស្សក្នុងផ្ទះសម្រាប់ធ្វើការ ហើយត្រឡប់មកវិញ។ ពាណិជច្បងបានឃ្លាំមើលដឹងថា ប្រពន្ធជាយក្ខិនី ទើបប្រាប់សេចក្ដីនោះដល់ពាណិជទាំងអស់ ហើយទើបបបួលថា មកយើងរត់ទៅ។ បណ្ដាពាណិជ៥០០នោះ, ពាណិជ ២៥០នាក់ពោលតបថា ទេយើងមិនអាចរត់ចោលស្ត្រីទាំងនេះ ដែលមានសម្ផស្សទន់ភ្លន់ត្រជាក់ដល់ចិត្តថ្លើមយើងបានឡើយ ណ្ហើយអញ្ជើញចុះ យើងមិនបានទៅទេ។ ពាណិជច្បងក៏នាំពាណិជ ២៥០នាក់ ដែលធ្វើតាមពាក្យរបស់ខ្លួនរត់ទៅ។ គ្រានោះ

www.elibraryofcambodia.org

ព្រះពោធិសត្វរបស់យើង ទ្រង់សោយព្រះជាតិជាស្តេចសេះវលាហកៈ មានសពាំង្គកាយ សត្រសុះ មានឫទ្ធិអស្ចារ្យអាចហោះហើរ ដើរដោយអាកាសវេហាស៍បានតាមចិន្តាចង់ ហោះមកពីព្រៃហេមពាន្តមកកាន់លង្កាទ្វីប ទំពារស៊ីស្រូវសាលីដែលដុះឯងកើតឯង ហើយហោះត្រឡប់ទៅវិញ បានឃើញពួកទាំងពាណិជទាំងនោះ ក៏ស្រែកសួរដោយសេចក្តីករុណាអស់វារៈបីដងថា មានអ្នកណាចង់ទៅកាន់ជនបទដែរឬទេ? ពាណិជទាំងនោះបានឮនូវសម្រែកស្តេចសេះ ក៏ផ្គងអញ្ជលីពោលថា យើងទាំងឡាយនឹងទៅ។ ស្តេចសេះក៏បន្ទាបខ្នងមក ហើយពោលថា បើដូច្នោះចូរឡើងជិះលើខ្នងខ្ញុំមកចុះ។ លំដាប់នោះពាណិជមួយពួក ឡើងជិះលើខ្នង មួយពួកទៀតកាន់នូវកន្ទុយ មួយពួកទៀតឈរផ្គងអញ្ជលី។ កាលហោះទៅ ស្តេចសេះអាចនាំនូវពាណិជ ដែលឈរផ្គងអញ្ជលីដោយអានុភាពរបស់ខ្លួនទៅកាន់លំនៅរៀង១ខ្លួនបាន ទើបហោះត្រឡប់ទៅឋានខ្លួនវិញ។ ឯពាណិជ ២៥០នាក់ដែលជាប់ចិត្តស្រឡាញ់ក្នុងរូប, ក្លិន, រស និងសម្ផស្ស ដ៏ទន់ភ្លន់ត្រជាក់របស់យក្ខិនីទាំងឡាយនោះ ក៏បានជាចំណីរបស់យក្ខិនីទាំងនោះទៅ។


www.elibraryofcambodia.org

# ការយាងមកកាន់កោះលង្ការរបស់ព្រះសម្មាសម្ពុទ្ធ

សុមេធៈ តាបសក្រោយពីបានឃើញ និងបានធ្វើសក្ការគោរពបូជាចំពោះព្រះពុទ្ធព្រះនាមទីបង្ករ, និងបានទទួលការព្យាករណ៍អំពីព្រះសម្មាសម្ពុទ្ធទីបង្ករថា : សុមេធតាបសនេះនឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធព្រះនាមសមណគោតម ជាអ្នកជួយចម្លងនូវសត្វលោកឱ្យរួចចាកសេចក្តីទុក្ខទាំងពួងនាពេលអនាគត ។ សុមេធតាបសបានទទួលការព្យាករណ៍ ពីសំណាក់ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញ, មង្គល... រហូតមកដល់ព្រះពុទ្ធព្រះនាមកស្សប ព្រះសម្មាសម្ពុទ្ធទាំង ២៤ ព្រះអង្គទ្រង់បានព្យាករណ៍ដូចៗគ្នា។ ក្រោយពីបានទទួលនូវការព្យាករណ៍អំពីសំណាក់ព្រះពុទ្ធគ្រប់ៗព្រះអង្គដូច្នេះហើយ សុមេធតាបស បានធ្វើទានរក្សាសីល និងបំពេញនូវបារមីដើម្បីឱ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

ព្រះបរមពោធិសត្វតែមួយអង្គឯង ទ្រង់បាននិមន្តទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេស ហើយទ្រង់គង់នៅក្រោមដើមជ្រៃមួយឈ្មោះអជបាលនិគ្រោធ ។ នៅទីនោះនាងសុជាតា ជាកូនស្រីរបស់សេនកុដុម្ពីក៏ ដែលមានផ្ទះនៅមិនឆ្ងាយអំពីទីនោះ នាងបានបន់ស្រន់ទេវតារក្សាដើមជ្រៃនោះថាៈ សុំឱ្យនាងខ្ញុំមានស្វាមីជាបុរសមានចិត្តប្រកប

www.elibraryofcambodia.org

ដោយធម៌ និងសុំឱ្យមានបុត្រប្រុសជាដំបូង ហើយបុត្រនោះសូមឱ្យលុះក្នុងដំបូន្មានមាតាបិតា បើបំណងនេះបានសម្រេច នាងខ្ញុំនឹងថ្វាយនូវមធុបាយាស ដាក់ដោយភាជន៍មាស ។ លុះបំណងរបស់នាងបានសម្រេចហើយ នាងសុជាតាបានចាត់ចែងនូវដង្វាយនាំយកទៅថ្វាយទេវតា ដែលរក្សាដើមជ្រៃដែលនាងបានបន់ស្រន់នោះ ។ ពេលដែលនាងបានទៅដល់ដើមជ្រៃ បានឃើញព្រះពោធិសត្វគង់នៅទៀបគល់អជបាលនិគ្រោធនោះ នាងបានថ្វាយបង្គំព្រះអង្គ រួចថ្វាយមធុបាយាសព្រមទាំងភាជន៍មាស រួចក៏ជៀសចេញអំពីទីនោះទៅ ។ ព្រះពោធិសត្វបានទទួលយកមធុបាយាស ហើយពូតបាន ៤៩ ពំនូត ប៉ុនៗគ្រាប់ត្នោត ។ រួចហើយទើបទ្រង់យាងចេញអំពីទីនោះ ឆ្ពោះទៅកាន់មាត់ស្ទឹងនេរញ្ជរា ព្រះអង្គបានយាងចុះទៅស្រង់ទឹកស្ទឹង ដើម្បីលាងព្រះកាយ រួចហើយទើបឆាន់មធុបាយាស ។ ពេលដែលព្រះអង្គឆាន់រួចហើយ ទ្រង់បានយកភាជន៍មាសនោះទៅបណ្តែតក្នុងស្ទឹង ហើយទ្រង់អធិដ្ឋានថា: បើអាត្មាអញបានត្រាស់ដឹងជាព្រះពុទ្ធក្នុងថ្ងៃនេះពិតប្រាកដមែន សូមឱ្យភាជន៍នេះអណ្តែតបញ្ច្រាសទឹកកុំខានឡើយ ។ អស្ចារ្យណាស់ ភាជន៍មាសពេលនោះក៏បានអណ្តែតបញ្ច្រាសទឹកស្ទឹងបាន ៨០ហត្ថ ហើយក៏លិចចុះទៅក្នុងទឹកបាត់


www.elibraryofcambodia.org

ទៅ។ ព្រះពោធិសត្វទ្រង់បានយាងចាកចេញអំពីទីនោះ ហើយទ្រង់យាងឆ្ពោះទៅកាន់កន្លែងដើមមហាពោធិព្រឹក្ស។ នៅតាមផ្លូវ ព្រះអង្គទ្រង់បានជួបសោត្ថិយព្រាហ្មណ៍ កំពុងច្រូតស្បូវភ្លាំង. ព្រាហ្មណ៍បានថ្វាយស្មៅភ្លាំងដល់ព្រះពោធិសត្វចំនួន៨ក្តាប់។ ព្រះអង្គទ្រង់បានកាន់យកនូវស្បូវភ្លាំងនោះ ទៅក្រាលទៀបគល់ពោធិព្រឹក្ស ហើយទ្រង់គង់នៅលើកម្រាលស្បូវ។ ពេលនោះស្រាប់តែរតនបល្ល័ង្កមានកំពស់១៤ហត្ថ បានផុសឡើងទ្រព្រះអង្គ។ ព្រះសមណគោតម ព្រះអង្គទ្រង់បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ នៅថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា វេលាទៀបភ្លឺ នៅទៀបគល់ដើមពោធិព្រឹក្សក្នុងឧរុវេលនិគម (ពុទ្ធគយា)។ បន្ទាប់ពីបានត្រាស់ដឹង ព្រះអង្គទ្រង់បានគង់សោយនូវវិមុត្តិសុខអស់៤៩ថ្ងៃ (ប្រាំពីរសប្តាហ៍) ។ ព្រះអង្គទ្រង់ជ្រាបនូវកាលដ៏សមគួរ ដើម្បីសំដែងនូវព្រះធម៌ប្រោសសត្វលោក ពេលនោះព្រះអង្គទ្រង់បរិវិតក្កៈទៅដល់តាបសទាំងពីរ ដែលធ្លាប់មានឧបការគុណចំពោះព្រះអង្គក្នុងកាលដែលទ្រង់បានស្វែងរកនូវមោក្ខធម៌ ប៉ុន្តែតាបសទាំងពីរនោះបានអនិច្ចកម្មផុតទៅហើយ។ បន្ទាប់មកព្រះអង្គទ្រង់ប្រមើលមើលទៅដល់បញ្ចវគ្គិយ៍ទាំងប្រាំ ដែលធ្លាប់បំរើព្រះអង្គកន្លងមក។ ពេលនោះទ្រង់


www.elibraryofcambodia.org

ជ្រាបថា ពួកបញ្ចវគ្គិយ៍កំពុងគង់នៅព្រៃឥសីបតនមិគទាយវន័ ជិតក្រុងពារាណសី ទើបទ្រង់យាងទៅកាន់ទីនោះដោយព្រះបាទតែមួយព្រះអង្គឯង ដើម្បីប្រោសបញ្ចវគ្គិយ៍. ដោយបានសំដែងនូវធម៌ឈ្មោះថា ធម្មចក្កប្បវត្តនសូត្រ និងអនត្តលក្ខណសូត្រ ដរាបបានសម្រេចធម៌ទាំងអស់អង្គតាមនិស្ស័យរៀង១ខ្លួន។ ក្នុងរយៈពេលបីខែ (១វស្សា) នៅទីនោះព្រះអង្គក៏បានបំបួសជាឯហិភិក្ខុដល់សាវ័កចំនួន ៦០អង្គ ដែលសុទ្ធតែជាព្រះអរហន្តខីណាស្រព។ នៅពេលបវរណាចេញព្រះវស្សាហើយ ព្រះអង្គក៏បានបញ្ជូនសាវ័កទាំង៦០អង្គ ទៅកាន់ទីផ្សេង១ ដើម្បីសម្តែងនូវព្រះធម៌ដល់ពុទ្ធបរិស័ទតាមនិគមជនបទ និងរាជធានី ដោយមិនឱ្យនិមន្តទៅតាមផ្លូវមួយមានគ្នាពីរអង្គឡើយ។ ចំណែកឯព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់បានយាងទៅកាន់ឧរុវេលនិគម ដើម្បីបំបាក់នូវទិដ្ឋិមានះរបស់ជដិលបីនាក់ ជាបងប្អូននឹងគ្នាគឺ ឧរុវេលកស្សប ១, នទីកស្សប ១, និងគយាកស្សប ១។ ឧរុវេលកស្សប មានសិស្ស៥០០នាក់, នទីកស្សប មានសិស្ស ៣០០នាក់ និងគយាកស្សប មានសិស្ស ២០០ នាក់។ ព្រះអង្គទ្រង់បានផ្ចាញ់ពួកជដិលទាំងបីនាក់ និងសិស្សទាំងអស់ ឱ្យជ្រះ

www.elibraryofcambodia.org

ថ្លាក្នុងព្រះពុទ្ធសាសនា ឱ្យលះបង់ចោលនូវទិដ្ឋិ និងលទ្ធិរបស់ខ្លួន រួចហើយព្រះអង្គទ្រង់បានបំបួសជដិល និងសិស្សទាំងអស់នោះជាឯហិភិក្ខុ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានយាងទៅកាន់កោះលង្កាអស់វារៈ៣ដង គឺ: ទី១-ផ្ចាញ់ពពួកយក្ស, ទី២-ផ្ចាញ់ពពួកនាគ, ទី៣-ទទួលភត្ត និងភេសជ្ជ របស់ស្ដេចនាគ នៅក្នុងនគរកល្យាណី។

មើលសត្វកណ្ដៀរ កពូនដី
មើលសត្វបក្សីក្រខសម្បុក
មើលឃ្មុំខារដើមសាងកគីសុខ
ព្យាយាមសម្រុកបានសម្រេច ។
ទឹកស្រក់តក់ៗឧម្លុះថ្ម
រលកគគៗថ្មសឹកដាច់
កាន់ការខារអ្វីត្រូវខម្ពួរផ្ដាច់
ផលល្អសម្រេចព្រោះព្យាយាម ។


www.elibraryofcambodia.org

## មហិយង្គណៈ (Mahiyangana)

ព្រះសម្មាសម្ពុទ្ធ កាលទ្រង់គង់ធរមាននៅឡើយ ព្រះអង្គទ្រង់បានប្រមើលមើលឃើញដោយព្រះចក្ខុញ្ញាណថា ព្រះសាសនារបស់ព្រះអង្គនឹងបានតាំងនៅមាំយូរអង្វែងជាងទីណាៗ គឺនៅក្នុងកោះលង្កានេះឯង។ នៅក្នុងថ្ងៃ១៥កើត ខែបុស្ស ក្រោយពេលដែលទ្រង់បានត្រាស់ដឹង ៩ខែ តាមសៀវភៅមហាវង្សរបស់ស្រីលង្កា (៨ខែ តាមគម្ពីរវិន័យដីការបស់ខ្មែរ) ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានយាងទៅកាន់កោះលង្កា ដើម្បីទូន្មានដល់ពពួកយក្សក្នុងនាគវ៉ន ដែលតែងតែប្រព្រឹត្តធ្វើសេចក្តីអន្តរាយដល់មនុស្សផងទាំងពួង។ នាគវ៉ននេះ កាលពីសម័យនោះ គឺជាតំបន់មួយដែលពោរពេញទៅដោយព្រៃព្រឹក្សាលតាវល្លិ៍ ដែលមានបណ្តោយបីយោជន៍ ទទឹងមួយយោជន៍។ ព្រះសម្មាសម្ពុទ្ធ កាលដែលព្រះអង្គទ្រង់យាងមក ព្រះអង្គបានសម្តែងបាដិហារ្យ ធ្វើឱ្យកក្រើកផែនដី មានសភាពដូចជាកប្បត្រូវវិនាស គឺធ្វើឱ្យផ្ទៃមេឃមានភាពងងឹតឈឹង មានភ្លៀង និងព្យុះខ្យល់បក់ត្រជាក់ឥតសរសៃហាក់បីដូចជានៅឋានសីតន្តរនរក។ ពួកយក្សឃើញដូច្នេះ ក៏កើតមានការភិតភ័យឥតឧបមា ហើយបានចេញមកត្រៀបត្រាក្រាបសំពះប្រណម្យវន្ទា

www.elibraryofcambodia.org

សុំខមាទោសចំពោះព្រះសម្មាសម្ពុទ្ធ ហើយបានសុំថ្វាយទីឋានកោះលង្កានេះទាំងមូលដល់ព្រះសម្មាសម្ពុទ្ធ។ ព្រះអង្គទ្រង់បានសម្ដែងព្រះធម៌ទេសនាដើម្បីប្រោសពពួកយក្ស ហើយមានទេវតាជាច្រើនមកស្ដាប់ព្រះធម៌ (ក្នុងគម្ពីរឥតមាននិយាយដល់មនុស្សឡើយ)។ កាលណោះមានទេវបុត្រមួយព្រះអង្គនាមសុមនៈ ក្រោយពេលបានស្ដាប់ព្រះធម៌ទេសនាចប់ ក៏បានសម្រេចសោតាបត្តិផល ហើយបានក្រាបថ្វាយបង្គំទូលសុំវត្ថុជាទីសរណៈអំពីព្រះអង្គ។ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ច្បូតព្រះកេសាបានមួយក្ដាប់ ហើយប្រទានឱ្យសុមនទេវបុត្រនាកាលណោះ។ សុមនទេវបុត្រ ក្រោយពីបានទទួលព្រះកេសធាតុអំពីព្រះអង្គហើយ ក៏បានយកទៅតម្កល់នៅក្នុងកោដ្ឋមាស ហើយនាំទៅបញ្ចុះនៅក្នុងព្រះចេតិយមហិយង្គណៈ។ មុននឹងព្រះអង្គទ្រង់យាងត្រឡប់មកកាន់ជម្ពូទ្វីបវិញ ដោយព្រះទ័យករុណាចំពោះពពួកយក្ស ព្រះអង្គទ្រង់បានពិចារណារកទីដ៏សមគួរ នៅភ្នំនាកណ្ដាលកោះលង្កា ឱ្យពួកយក្សអាស្រ័យនៅ។ ក្រោយពេលដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ចូលព្រះបរិនិព្វាន ព្រះថេរៈ១អង្គព្រះនាមសរភូ ដែលជាអន្តេវាសិក (សិស្ស) របស់ព្រះសារីបុត្រ បាននិមន្តទៅកាន់ទីកន្លែងបូជាព្រះសពរបស់ព្រះដ៏មានព្រះ


www.elibraryofcambodia.org

ភាគ ហើយក៏បាននាំយកព្រះអក្ខកធាតុ (ឆ្អឹងដងកាំបិត) ដោយឫទ្ធិ ហើយយកទៅបញ្ចុះនៅក្នុងព្រះចេតិយមហិយង្គណនេះដែរ ។



ព្រះអង្គទ្រង់ផ្ចាញ់ពពួកយក្សនៅកោះលង្កា



ព្រះចេតិយ មហិយង្គណៈ



www.elibraryofcambodia.org

## នាគទីបៈ (Nagadipa)

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃមនុស្ស និងទេវតាទាំងឡាយ ព្រះអង្គតែងមានសេចក្តីករុណាចំពោះសត្វលោក ទ្រង់តែងតែប្រមើលមើលដោយចក្ខុញ្ញាណ នូវឧបនិស្ស័យរបស់សត្វដែលទ្រង់គួរប្រោស និងជួយសង្គ្រោះឱ្យបានរួចចាកទុក្ខ។ ព្រះអង្គទ្រង់ប្រមើលមើលផងដែរថា សាសនារបស់ព្រះអង្គនឹងតាំងនៅមាំយូរអង្វែង នៅក្នុងកោះលង្កាជាងទីណាៗទាំងអស់។ ក្រោយពីបានទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណបានប្រាំវស្សា កាលណោះព្រះអង្គទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ដែលអនាថបិណ្ឌិកសេដ្ឋីបានសាងថ្វាយ។ ដោយសំណាញ់ញាណរបស់ព្រះអង្គទ្រង់ជ្រាបថា សង្គ្រាមដណ្តើមរាជសម្បត្តិរវាងនាគអ៊ំ (មហោតរនាគ) និងនាគក្មួយ (ចុឡូតរនាគ) ចូលខិតមកជិតដល់ហើយ ព្រះអង្គទ្រង់បានកាន់យកនូវបាត្រ និងចីវរ ហើយយាងទៅកាន់នាគទីបនៃកោះលង្កា នៅថ្ងៃ ១៥រោច ខែចែត្រ ដើម្បីរម្ងាប់អធិករណ៍នោះ។ សូមបញ្ជាក់ថាៈ ស្តេចនាគបានប្រគល់នូវឫទ្ធិអំណាចក្នុងដែនសមុទ្រប្រមាណ ៥០០ យោជន៍ ដល់មហោតរនាគ មើលថែរក្សាចំណែកឯប្អូនស្រីរបស់ខ្លួន បានរៀបការជាមួយនឹងស្តេចនាគ នៅភ្នំ


www.elibraryofcambodia.org

កណ្ដាលវឌ្ឍមានៈ ហើយមានកូនម្នាក់ឈ្មោះចុឡូតរនាគ។ ស្ដេចនាគមុននឹងចូលទីវង្គត បានប្រគល់រាជសម្បត្តិឱ្យទៅម្ដាយរបស់ចុឡូតរៈ ក្រោយមកនាគជាម្ដាយក៏បានចូលទិវង្គត ដូច្នេះហើយបានជាបណ្ដាលឱ្យកើតនូវជម្លោះដណ្ដើមរាជសម្បត្តិនេះ។

ព្រះសម្មាសម្ពុទ្ធ កាលដែលព្រះអង្គទ្រង់យាងមកដល់ ព្រះអង្គបានសម្ដែងបាដិហារ្យ ធ្វើឱ្យកក្រើកផែនដី មានសភាពដូចជាកប្បត្រូវវិនាស ផ្ទៃមេឃងងឹតឈឹង ខ្យល់ត្រជាក់បក់ឥតសរសៃ ហាក់បីដូចជានៅឋានសីតន្តរនរក។ ពួកនាគឃើញដូច្នេះ ក៏កើតមានការភិតភ័យឥតឧបមា ចេញមកក្រាបសំពះប្រណម្យវន្ទាសូមខមាទោស និងសុំថ្វាយទីឋានកោះលង្កានេះទាំងមូលដល់ព្រះសម្មាសម្ពុទ្ធ។ ព្រះអង្គទ្រង់បានសម្ដែងព្រះធម៌ទេសនា ដោយមានទេវតា និងនាគជាច្រើនមកស្ដាប់ព្រះធម៌ ហើយពួកទេវតានិងនាគទាំងឡាយ ក៏បានតាំងនៅក្នុងត្រៃសរណគមន៍ (ក្នុងគម្ពីរឥតមាននិយាយដល់មនុស្សឡើយ)។

ស្ដេចនាគឈ្មោះមនិអក្ខិកនាគរាជ នៃនគរកល្យាណី ដែលត្រូវជាប្អូនរបស់ម្ដាយមហោតរនាគ ក៏បានទៅកាន់កន្លែងជម្លោះ ដើម្បីជួយដល់មហោតរនាគ។ មនិអក្ខិកនាគរាជ នៅពេលដែលបានស្ដាប់ព្រះធម៌


www.elibraryofcambodia.org

ទេសនារបស់ព្រះសម្មាសម្ពុទ្ធហើយ ក៏បានតាំងនូវក្នុងត្រៃសរណគមន៍ ដូចជានាគ៧ទៀតៗដែរ ហើយក៏បាននិយាយថា បពិត្រព្រះអង្គដ៏ចម្រើន! ពេលនេះប្រសិនបើព្រះអង្គ មិនបាននិមន្តយាងមកទេម្ល៉េះ ពួកយើងទាំងអស់គ្នា នឹងក្លាយទៅជាផេះអស់ទៅហើយ ព្រោះថាជម្លោះនេះមាននាគដែលមានឫទ្ធានុភាពខ្លាំងៗដ៏ច្រើនបានមកចូលរួម ដោយសេចក្តីករុណារបស់ព្រះអង្គចំពោះពួកនាគទាំងអស់ ទើបយើងទាំងអស់គ្នាបានរួចចាកនូវគ្រោះមហន្តរាយនេះ។ ស្តេចនាគអង្គនេះ មានសេចក្តីជ្រះថ្លាចំពោះព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់បានបំភ្លឺឱ្យស្តេចនាគនិងនាគទាំងឡាយបានយល់អំពីធម៌សាមគ្គី ហើយក៏បានសូមអារាធនានិមន្តព្រះអង្គមកនគរកល្យាណីរបស់ខ្លួនផងដែរ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គក៏បានទទួលព្រម តែព្រះអង្គមិននិមន្តយាងទៅកាន់នគរកល្យាណីនៅពេលនោះភ្លាមទេ តែព្រះអង្គទ្រង់រង់ចាំនូវកាលដ៏គួរ ទើបព្រះអង្គយាងទៅ។ បន្ទាប់មកព្រះសម្មាសម្ពុទ្ធព្រះអង្គ ទ្រង់ក៏បានបន្លឺនូវសម្លេងដើម្បីនាំមកនូវសេចក្តីសុខដល់ពពួកនាគទាំងអស់ រួចព្រះអង្គក៏និមន្តត្រឡប់ទៅកាន់ដែនជម្ពូទ្វីបវិញទៅ។

www.elibraryofcambodia.org

# វត្តកល្យាណី

វត្តកល្យាណី គឺជាវត្តមួយដែលមានវ័យចំណាស់ ហើយបានកត់ត្រាទុកនៅក្នុងប្រវត្តិសាស្ត្រនូវទីឋានដ៏ស័ក្តិសិទ្ធិទាំង១៦ សម្រាប់ពុទ្ធបរិស័ទធ្វើសក្ការៈគោរពបូជា។ តាមសៀវភៅមហាវង្ស បានសំដែងមកថាៈ មនិអក្ខិកនាគរាជ បានអារធនាព្រះសម្មាសម្ពុទ្ធ និងងភិក្ខុសង្ឃសាវ័កមកទទួលភត្តនៅនគរកល្យាណី គឺបីឆ្នាំក្រោយពេលដែលព្រះអង្គទ្រង់បានផ្ចាញ់ពពួកនាគនៅដែននាគទីបៈ។ ព្រះអង្គបានយាងមកកាន់នគរកល្យាណីនៃកោះលង្កានេះ គឺជាការយាងមកលើកទីបី ជាមួយនិងភិក្ខុសាវ័កចំនួន ៥០០អង្គ នៅថ្ងៃ១៥កើត ពេញបូណ៌មី ខែពិសាខ ក្រោយពេលដែលព្រះអង្គទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណបាន ៨ឆ្នាំ។

ស្តេចនាគឈ្មោះមនីអក្ខិកនាគរាជ ដែលបានហែហមដោយនាងនាគមាណវិកា បានអារធនានិមន្តព្រះអង្គគង់លើរតនបល្ល័ង្ក រួចហើយក៏បាននាំយកមធុបាយាសនិងភេសជ្ជៈជាទិព្វ មកថ្វាយប្រគេនដល់ព្រះអង្គ និងភិក្ខុសាវ័កទាំង ៥០០អង្គ។ ទីកន្លែងដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់គង់ប្រថាប់នៅលើរតនបល្ល័ង្កណា គឺបល្ល័ង្កនោះហើយដែល


www.elibraryofcambodia.org

បានបញ្ចុះទៅក្នុងព្រះស្តូប ។ នៅពេលដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គសម្តែងនូវព្រះធម៌ទេសនា ដើម្បីប្រោសពួកនាគនៅក្នុងនគរកល្យាណីនេះចប់ ព្រះអង្គទ្រង់បាននិមន្តយាងចេញអំពីទីនោះ រួមជាមួយនិងភិក្ខុសាវ័ក ទៅប្រតិស្ឋានស្នាមព្រះបាទនៅលើកំពូលភ្នំសុមនកូដ ។ អ្នកស្រុកស្រីលង្កា បានហៅទីឋានដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ប្រតិស្ឋានស្នាមព្រះបាទនេះថាស្រីបាទៈ ។ ជារៀងរាល់ឆ្នាំ នៅទីឋានស្រីបាទៈនេះ មានប្រជាជនជនឡើងទៅធ្វើសក្ការៈ គោរពបូជាយ៉ាងច្រើន ។ ក្រោយពេលប្រតិស្ឋានស្នាមព្រះបាទហើយ ព្រះអង្គក៏បានចូលនិរោធសមាបត្តិនៅទីនោះ ជាមួយនិងភិក្ខុសាវ័កអស់រយៈពេលមួយថ្ងៃ បន្ទាប់មកព្រះអង្គក៏បានយាងទៅកាន់តំបន់មួយឈ្មោះទីឃវាបិ. ទីនោះគេក៏បានកសាងព្រះស្តូបនៅត្រង់ទីកន្លែងដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានចូលនិរោធសមាបត្តិនោះផងដែរ ។ ក្រោយមកព្រះអង្គ និងភិក្ខុសាវ័ក បាននិមន្តយាងទៅកាន់ទីកន្លែងផ្សេងៗទៀត ជាច្រើនកន្លែង ហើយទីឋានទាំងនោះ ព្រះអង្គក៏បានទ្រង់ចូលនិរោធសមាបត្តិ ដូចទីកន្លែងឯទៀតៗដែរ. ទីឋានទាំងនោះរួមមាន : សួនមហាមេឃវ័ន កន្លែងដាំមហាពោធិព្រឹក្ស. កន្លែងកសាងសុវណ្ណមាលិកចេតិយ. កន្លែងកសាង


www.elibraryofcambodia.org

ផ្ទុបាភាម ។ល ។

មុនពេលដែលព្រះសម្មាសម្ពុទ្ធយាងចេញអំពីកោះលង្កា ព្រះអង្គ និងភិក្ខុសង្ឃជាសាវ័ក បានធ្វើប្រទក្សិណកោះលង្កាបីជុំ ទើបនិមន្តយាងទៅកាន់ដែនជម្ពូទ្វីបវិញ ។





www.elibraryofcambodia.org

# ព្រះបាទទេវានម្បិយតិស្ស

ក្រោយពីព្រះបាទបិណ្ឌុកអភ័យចូលទិវង្គតទៅ ព្រះរាជបុត្រា របស់ព្រះអង្គព្រះនាមមុត្តសិវៈ ក៏បានឡើងគ្រងរាជ្យបន្ត នៅមុន គ.ស ៣៦៧ឆ្នាំ។ ព្រះបាទមុត្តសិវៈ ក្រោយពេលដែលទ្រង់បានឡើងគ្រងរាជ្យ ព្រះអង្គក៏ទ្រង់បានជ្រើសរើសយកទីឋានដ៏ប្រសើរមួយកន្លែងសម្រាប់ធ្វើជាឧទ្យាន ដែលទីនោះមានលំអទៅដោយដើមឈើមានផ្លែ និងផ្កាចម្រុះពណ៌ជាច្រើន។ នៅពេលដែលព្រះអង្គជ្រើសរើសទីឋានធ្វើឧទ្យាន ពេលនោះផ្ទៃមេឃមានពពកខ្មៅងងឹត និងបានបង្អុរព្រះភិរុណយ៉ាងខ្លាំង ដោយមានហេតុដ៏អស្ចារ្យដូច្នេះ ទើបគេហៅឧទ្យាននោះថាៈ មហាមេឃវ័នឧទ្យាន។ ព្រះបាទមុត្តសិវៈ ព្រះអង្គគ្រងរាជ្យអស់រយៈពេល៦០ឆ្នាំនៅនាក្រុងអនុរាធបុរី។ ព្រះអង្គមានព្រះរាជបុត្រា ១០ ព្រះអង្គ និងព្រះរាជបុត្រី២ព្រះអង្គ សុទ្ធតែមានរូបឆោមស្រស់បវរ។ ព្រះរាជបុត្រាទីពីរ ព្រះនាមទេវានម្បិយតិស្ស ព្រះអង្គមានប្រាជ្ញាវាងវៃជាងព្រះរាជបុត្រឯទៀតៗ ព្រះអង្គគឺជារាជទាយាទ និងជាអ្នកស្នងរាជបន្តអំពីព្រះរាជបិតា។

ព្រះបាទទេវានម្បិយតិស្ស ព្រះអង្គបានឡើងគ្រងរាជ្យ នៅមុន


www.elibraryofcambodia.org

គ.ស ៣០៧-២៦៧ ព្រះអង្គគឺជាស្តេចទី៦ ដែលបានគ្រងរាជ្យនៅក្នុងនគរកោះលង្កានេះ ។ នៅពេលដែលព្រះអង្គអភិសេកឡើងគ្រងរាជ្យ ពេលនោះមានរតនសម្បត្តិ និងគ្រឿងអលង្ការជាច្រើនដែលបានលិចទៅតាមសំពៅ នៅក្នុងមហាសមុទ្របានផុសឡើង ហើយបានអណ្តែតមកកាន់ដីគោកនៅទីកន្លែងផ្សេងៗ មិនតែប៉ុណ្ណោះ នៅពេលដែលព្រះអង្គឡើងគ្រងរាជ្យនោះ ក៏មានរតនប្រាំបីប្រការបានកើតឡើងដោយឯងៗ ពូនជាគំនរៗនៅតាមឆ្នេរសមុទ្រ ក៏ត្រូវបានគេនាំមកថ្វាយព្រះអង្គក្នុងសប្តាហ៍នោះផងដែរ ។

ការឡើងគ្រងរាជ្យរបស់ព្រះបាទទេវានម្បិយតិស្ស ជាការបើកនូវទំព័រនៃប្រវត្តិសាស្ត្រថ្មីនៅក្នុងនគរកោះលង្កា ពីព្រោះថានៅក្នុងអំឡុងពេលនៃការគ្រងរាជ្យរបស់ព្រះអង្គ ព្រះពុទ្ធសាសនាក៏ត្រូវបាននាំមកផ្សព្វផ្សាយ ។ ការផ្សព្វផ្សាយនេះ បានចាប់ផ្តើមឡើងនៅពាក់កណ្តាលសតវត្សរ៍ទីពាមុន គ.ស ។ នេះមិនមែនគ្រាន់តែជាការទទួលនូវជំនឿថ្មីប៉ុណ្ណោះទេ ក៏ប៉ុន្តែនេះគឺជាការទទួលយកនូវប្រពៃណីទំនៀមទំលាប់ និងរបៀបនៃការរចនាបទសិល្បៈផ្សេងៗ ព្រមទាំងការដឹកនាំសង្គមទៅតាមបែបនៃព្រះពុទ្ធសាសនាផងដែរ ។


www.elibraryofcambodia.org

ព្រះបាទទេវានម្បិយតិស្ស ព្រះអង្គជាមិត្តសំឡាញ់ដ៏ជិតស្និទ្ធជាមួយនិងព្រះបាទធម្មាសោក ដែលគ្រងរាជ្យនៅដែនបត្តលីបុត្ត ក៏ប៉ុន្តែព្រះរាជាទាំងពីរព្រះអង្គពុំដែលបានជួប ឬឃើញមុខគ្នានោះទេ គឺជាអទិដ្ឋសហាយ សំឡាញ់មិនដែលឃើញមុខគ្នា។ ព្រះអង្គទាំងពីរបានស្គាល់គ្នាត្រឹមតែការបញ្ជូននូវវត្ថុដែលជាបណ្ណាការផ្សេងៗទៅមកតាមរយៈពួកឈ្មួញជួញដូរតាមសំពៅតែប៉ុណ្ណោះ។ ព្រះបាទធម្មាសោកព្រះអង្គក៏ធ្លាប់បានផ្ញើប្រដាប់ជាគ្រឿងបណ្ណាការ សំរាប់អភិសេកគ្រងរាជ្យ ព្រមទាំងបានបញ្ជូនមកនូវលិខិតចុតហ្មាយ ថ្វាយព្រះពរសាធុការព្រមទាំងបានភ្ជាប់មកជាមួយនូវក្នុងព្រះរាជសារ ដោយពាក្យថាៈ យើងនៅឯណេះមានរតនសម្បត្តិអស្ចារ្យ ជាទីពឹងហើយ សូមឱ្យសម្លាញ់ទទួលបាននូវរតនសម្បត្តិ ដូចយើងសម្រាប់ជាទីពឹងទីរលឹកផងចុះ។ ព្រះបាទធម្មាសោក ព្រះអង្គទ្រង់បានជួយទំនុកបំរុងនិងបានជួយផ្សព្វផ្សាយព្រះពុទ្ធសាសនានៅពាសពេញប្រទេសឥណ្ឌា និងប្រទេសជិតខាង។

នៅក្នុងរជ្ជកាលនៃការគ្រងរាជ្យរបស់ព្រះបាទទេវានម្បិយតិស្ស ព្រះអង្គមិនត្រឹមតែជួយជ្រោមជ្រែងដល់ព្រះមហិន្ទត្ថេរ ក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ព្រះអង្គថែមទាំងបានកសាងនូវសមិទ្ធផល

www.elibraryofcambodia.org

ផ្សេងៗជាច្រើន ដូចជាកន្លែងធ្វើសក្ការគោរពបូជាមាន វត្ត ព្រះវិហារ ព្រះស្តូប និង ទំនប់ទឹកជាដើម ។

ព្រះបាទទេវានម្បិយតិស្ស ព្រះអង្គគ្រងរាជ្យបាន ៤០ឆ្នាំហើយ ព្រះអង្គបានចូលទិវង្គតទៅ ។ ព្រះរាមរបស់ព្រះអង្គព្រះនាមឧទ្ទិយៈ ក៏បានឡើងគ្រងរាជ្យបន្ត ។

ធ្ងន់ណែននឹងធឹងដូចផែនដី
មិនមានជាប់អ្វីដូចអាកាស
ស្ងប់ស្ងៀមត្រជាក់សែនស្រឡះ
គឺសុខពិតណាស់ចិត្តអរហំ ។

www.elibraryofcambodia.org

# ក្រុងអនុរាធបុរី

តាមសៀវភៅប្រវត្តិសាស្ត្ររបស់ប្រទេសស្រីលង្កា ឈ្មោះមហាវង្ស បានកត់ត្រាទុកថាៈ ព្រះបាទវិជ័យ គឺជាស្តេចទីមួយ ដែលបានមកគ្រងរាជ្យនៅក្នុងដែនតម្ពបណ្ណទ្វីប (កោះលង្កា) នេះមុនគេ។ មន្ត្រីរបស់ព្រះអង្គក៏បានបង្កើតនូវស្រុកផ្សេងៗគ្នា ហើយបានដាក់ឈ្មោះស្រុកទាំងនោះ ទៅតាមឈ្មោះរបស់ពួកគេ ដូចជាមន្ត្រីឈ្មោះអនុរុទ្ធៈ បានបង្កើតស្រុកមួយឈ្មោះ អនុរុទ្ធគ្រាម។ ព្រះបាទវិជ័យបានគ្រងរាជ្យនៅក្នុងនគរកោះលង្កានេះបាន ៣៨ឆ្នាំ ព្រះរាជបុត្ររបស់ព្រះបាទសុមិត្តា ដែលជាព្រះអនុជរបស់ព្រះអង្គព្រះនាមបិណ្ឌុវាសុទេវៈ ដែលបានរៀបអភិសេកជាមួយព្រះនាងភទ្ទកច្ចនាទេវី មកពីដែនជម្ពូទ្វីបគ្រងរាជ្យបន្តអំពីព្រះបាទវិជ័យ។ ព្រះបាទបិណ្ឌុវាសុទេវ និងព្រះនាងភទ្ទកច្ចនាទេវី បានជ្រើសយកស្រុកអនុរុទ្ធគ្រាមធ្វើជាទីក្រុង។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមបិណ្ឌុកភយបានអភិវឌ្ឍន៍ ហើយប្តូរឈ្មោះស្រុកអនុរុទ្ធគ្រាមនេះទៅជាក្រុងអនុរាធបុរៈ ព្រះអង្គបានគ្រងរាជ្យ (៤៥៥-៤០០ មុន គ.ស)។ ព្រះអង្គគឺជាព្រះរាជាទីមួយ ដែលបានកសាងនូវទំនប់ទឹកសម្រាប់ប្រើប្រាស់នៅក្នុងក្រុងអនុរាធបុរៈនេះ។

www.elibraryofcambodia.org

ព្រះពុទ្ធសាសនាថេរវាទ បានផ្សព្វផ្សាយមកកាន់នគរកោះលង្កានេះ ដោយព្រះអរហន្តមហិន្ទត្ថេរ ព្រះថេរៈអង្គនេះ ជាព្រះរាជបុត្ររបស់ព្រះបាទធម្មាសោក។ ព្រះអង្គបាននិមន្តមក នៅក្នុងអំឡុងពេលដែលព្រះបាទទេវានម្បិយតិស្សគ្រងរាជ្យ។ ដោយការផ្សព្វផ្សាយនេះ បានធ្វើឱ្យប្រជាជនសីហឡៈ ទាំងអស់បានកាន់យកជំនឿនៅក្នុងព្រះពុទ្ធសាសនា។ សង្ឃមិត្តាថេរី ដែលជាប្អូនស្រីរបស់ព្រះមហិន្ទត្ថេរ ក៏បាននាំដើមមហាពោធិព្រឹក្សពីដែនជម្ពូទ្វីប ពីទីកន្លែងត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ មកដាំនៅនាក្រុងអនុរាធបុរី ហើយភិក្ខុនីសង្ឃក៏បានបង្កើតនៅក្នុងនគរកោះលង្កា នាពេលនោះផងដែរ។

ពួកទមិឡៈ ឈ្មោះសេនៈ និងគុត្តិកៈ បានចូលលុកលុយក្រុងអនុរាធបុរីនេះលើកទី១ នៅក្នុងសម័យសុរតិស្ស ដែលជាព្រះអនុជរបស់ព្រះបាទទេវានម្បិយតិស្សគ្រងរាជ្យ។ ព្រះបាទទុដ្ឋគាមិនីអភ័យ ព្រះអង្គបានគ្រងរាជ្យនៅក្នុងក្រុងអនុរាធៈបុរី ដែលជាព្រះបិតាជាតិ របស់ប្រជាជននៃនគរកោះលង្កា ព្រះអង្គបានប្រសូត្រនៅភាគខាងត្បូងនៃនគរ។ បំណងប្រាថ្នាដ៏ធំរបស់ព្រះអង្គគឺស្រោចស្រង់នគរកោះលង្កា អំពីពួកចោរទមិឡៈ និងធ្វើជាអ្នកឧបត្ថម្ភដល់ព្រះពុទ្ធសាសនា។ នៅក្នុងសម័យ

www.elibraryofcambodia.org

កាលព្រះបាទវដ្ដគាមិនីអភ័យ ព្រះអង្គក៏បានកំចាត់ពពួកចោរទមិឡ ហើយឡើងគ្រងរាជ្យនៅក្នុងក្រុងអនុរាធបុរី នៃនគរកោះលង្កា។ នៅក្នុងសម័យកាលដែលព្រះអង្គបានគ្រប់គ្រង មានហេតុសំខាន់ៗ ដែលគួរឱ្យកត់សំគាល់ ២ យ៉ាងគឺ:

១-ការបែកបាក់រវាងព្រះសង្ឃនៅក្នុងនគរកោះលង្កា

២-ការកត់ត្រាជាអក្សរលើកដំបូងនៅក្នុងសស្ត្រាស្លឹករឹត និងការសរសេរជាអដ្ឋកថា នៅក្នុងវត្តអាលុវិហារ។

នៅក្នុងសម័យ ព្រះបាទកិត្តិស្រីមេឃវ័ន (៣២១-៣២៨ ក្រោយ ព.ស) ព្រះទន្តធាតុ (ព្រះចង្កូមកែវ) របស់ព្រះសម្មាសម្ពុទ្ធ ត្រូវបាននាំមកកាន់នគរកោះលង្កា។ ក្រុងអនុរាធបុរៈត្រូវបានគេបោះបង់ចោលនៅក្នុងសតវត្សរ៍ទី៩ និងទី១០ ក្រោយមកគេបានបង្កើតក្រុងថ្មីនៅឯបុឡុណ្ណរូវៈ។ ក្រោយពីការបោះបង់ចោលក្រុងអនុរាធបុរីមក ទីនេះក៏បានក្លាយទៅជាកន្លែងសម្រាប់អ្នកកាន់ព្រះពុទ្ធសាសនាធ្វើសក្ការៈគោរពបូជា។ ទីកន្លែងដែលសំខាន់ៗ នៅក្រុងអនុរាធបុរីនេះមាន ៨ កន្លែង គឺ:


www.elibraryofcambodia.org

១-ដើមមហាពោធិព្រឹក្ស ២-សុវណ្ណមាលិកចេតិយ ៣-ថូបារាម

៤-លោហប្រាសាទ ៥-អភយគីរីចេតិយ ៦- ជេតវនារាម

៧- មិរិស្សយចេតិយ ៨- លង្ការាមចេតិយ



រុយចូលចិត្តលាមក

មនុស្សគម្រក់សេពអធម៌

ឃ្មុំចូលចិត្តកេសរ

ជាតិមនុស្សល្អចូលចិត្តបុណ្យ ។


www.elibraryofcambodia.org

# ដើមមហាពោធិព្រឹក្ស

ព្រះនាងសង្ឃមិត្តាថេរី បាននាំមកមហាពោធិព្រឹក្សអំពីពុទ្ធគយា ជាទីកន្លែងដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ មកដាំនៅនគរកោះលង្កា ក្នុងរជ្ជកាលព្រះបាទទេវានម្បិយតិស្ស។ ដើមមហាពោធិព្រឹក្សនេះ គឺជាដើមឈើមួយដើមដែលមានវ័យចំណាស់ចាស់ជាងគេក្នុងប្រវត្តិសាស្ត្រនៃពិភពលោក។ ដើមមហាពោធិព្រឹក្ស ត្រូវបាននាំមកកាន់នគរកោះលង្កា ក្រោយអំពីការនិមន្តមកដល់របស់ព្រះអរហន្តមហិន្ទត្ថេរ ប្រមាណពីរ ឬបីខែ។ ការមកដល់នៃដើមមហាពោធិព្រឹក្សនេះ ព្រះរាជាក៏បានប្រារព្ធធ្វើពិធីបុណ្យយ៉ាងមហោឡារិក ដើម្បីដាំនូវមហាពោធិព្រឹក្សនៅក្នុងសួនមហាមេឃវ័ន បានញ៉ាំងមហាជននៅក្នុងនគរទាំងមូល ឱ្យស្ថិតនៅក្នុងភាពសប្បាយរីករាយក្នុងបុណ្យកុសល។ ដើមមហាពោធិព្រឹក្សនេះ ត្រូវបានគេដាំនៅលើទីទួលខ្ពស់អំពីផ្ទៃដីប្រមាណ ២១ហ្វីត (៦.៤ម៉ែត្រ) មានរបងដែកពណ៌មាសព័ទ្ធជុំវិញ។ បច្ចុប្បន្នដើមមហាពោធិព្រឹក្សនេះ ត្រូវបានគេចាត់ជាព្រះធាតុដ៏មានតម្លៃបំផុត សម្រាប់ពុទ្ធសាសនិកនៅក្នុងប្រទេសស្រីលង្កា និងពិភពលោក។ នៅទីជុំវិញដើមមហាពោធិព្រឹក្សនេះ


www.elibraryofcambodia.org

មានដើមពោធិព្រឹក្សផ្សេងៗទៀតដ៏ច្រើន ដែលបានដុះនៅក្បែរៗទីនោះ។ របងដែលធ្វើព័ទ្ធជុំវិញនៅបរិវេណខាងក្រៅ ដែលដាំដើមមហាពោធិព្រឹក្សនោះ មានប្រវែងប្រមាណ ៧០០ហ្វីត (២១៣.៣ ម៉ែត្រ) ដើម្បីការពារសត្វសាហាវ មានដំរីជាដើមដែលចូលមកយាយី ដល់ដើមមហាពោធិព្រឹក្ស ហើយរបងនេះបានកសាងឡើង នៅក្នុងរជ្ជកាលនៃព្រះបាទកិរតិស្រីរជ្ជសិង្ហៈ។



ដើមមហាពោធិព្រឹក្ស នៅប្រទេសស្រីលង្កា


www.elibraryofcambodia.org

# ទីឋានដាំដើមមហាពោធិព្រឹក្ស

ទីឋានដាំដើមមហាពោធិព្រឹក្ស ដែលបាននាំមកអំពីដែនជម្ពូទ្វីប ដោយព្រះនាងសង្ឃមិត្តាថេរី មួយអន្លើដោយភិក្ខុនីសង្ឃ ៥០០អង្គ។ ព្រះនាងបានថ្វាយដើមមហាពោធិ៍ ដល់ព្រះបាទទេវានម្បិយតិស្ស ព្រះអង្គក៏បាននាំយកដើមពោធិព្រឹក្សនេះ មកដាំនៅក្នុងសួនមហាមេឃវ័ន ក្បែរក្រុងអនុរាធបុរី។ ក្រោយអំពីដាំដើមមហាពោធិព្រឹក្សរួចហើយ ព្រះអង្គនិងព្រះមហិន្ទត្ថេរ ក៏បានយាងនិងនិមន្តអំពីទីនោះបានឆ្ងាយបន្តិច ពេលនោះមានអាមាត្យម្នាក់ បានយកផ្កាមកថ្វាយដល់ព្រះរាជាៗ ក៏យកផ្កានោះទៅប្រគេនដល់ព្រះមហិន្ទត្ថេរ។ ព្រះថេរក៏បានយកផ្កានោះទៅបូជានៅលើទីឋានមួយ ពេលនោះស្រាប់តែផែនដីក៏បានញ័ររញ្ជួយឡើង ព្រះរាជាក៏កើតមានការភិតភ័យ ហើយទ្រង់ត្រាស់សួរទៅព្រះមហិន្ទត្ថេរ ព្រះអង្គមានថេរដីកាថា: ទីត្រង់ហ្នឹងទៅអនាគត នឹងបានកើតជាលោហៈប្រាសាទ ក៏ប៉ុន្តែពុំមែនជានិស្ស័យបុណ្យរបស់ព្រះអង្គ ដែលត្រូវកសាងនោះទេ តែជានិស្ស័យចៅរបស់ព្រះអង្គ។ ក្រោយមកទៀតមានអាមាត្យម្នាក់បានយកផ្កាចំប៉ាមកថ្វាយដល់ព្រះរាជា ទ្រង់ក៏បានប្រគេនផ្កានោះទៅព្រះមហិន្ទត្ថេរៗ ក៏បានយកទៅបូជានៅលើទីកន្លែងទទេមួយទៀត ពេល

www.elibraryofcambodia.org

នោះផែនដីក៏បានញ័រឡើងម្តងទៀត ព្រះរាជាក៏ទូលសួរព្រះមហិន្ទត្ថេរៗ មានថេរៈដីកាថា: ទីត្រង់នេះនឹងកើតមហាចេតិយ ។ ពេលឮដូច្នោះ ព្រះរាជាក៏កើតនូវសទ្ធាយ៉ាងខ្លាំង ហើយទូលថា ខ្ញុំព្រះអង្គនិងទទួលរ៉ាប់រងក្នុងការកសាង តែព្រះមហិន្ទត្ថេរមានថេរៈដីកាថា: នេះមិនមែនជានិស្ស័យរបស់ព្រះអង្គកសាងទេ តែជានិស្ស័យចៅរបស់ព្រះអង្គជាអ្នកកសាង ។ ពេលនោះព្រះរាជាទ្រង់មានបន្ទូលថា: បើជាឧប្បនិស្ស័យចៅរបស់ខ្ញុំព្រះករុណាជាអ្នកកសាងនោះ នេះក៏ដូចជារូបខ្ញុំព្រះករុណាកសាងដែរ ។ បន្ទាប់មកព្រះរាជាក៏បានឱ្យជាងធ្វើជាសិលាឆ្លាក់នូវអក្សរជាពាក្យបណ្តាំដល់ចៅរបស់ព្រះអង្គទុកជាស្រេចតាំងពីកាលនោះមក ។

ក្នុងសាសនាព្រះពុទ្ធព្រះនាមកកុសន្ធោ ទីឋានដាំដើមមហាពោធិព្រឹក្សដែលនេះឈ្មោះឧទ្យានមហាទិដ្ឋវ័ន ។ ភិក្ខុនីព្រះនាមរុចិនន្ទាព្រមដោយភិក្ខុនីសង្ឃ៥០០អង្គ បាននាំដើមសិរិសព្រឹក្ស (ដើមច្រេស) អំពីដែនជម្ពូទ្វីបមកដោយឫទ្ធិ ។ កាលសម័យនោះស្តេចខេមរាជ បានថ្វាយដើមមហាសិរិសព្រឹក្សនេះដល់ព្រះបាទអភយរាជ ក្នុងនគរកោះលង្កា ដែលកាលណោះមានឈ្មោះថាឱជទ្វីប ។

www.elibraryofcambodia.org

ក្នុងសាសនាព្រះពុទ្ធព្រះនាមកោនាគមនោ នគរកោះលង្កាកាល ណោះមានឈ្មោះថា វរទ្វីប ទីឋានដាំដើមមហាពោធិព្រឹក្សនេះ មាន ឈ្មោះថាៈ មហានាគវ័ន។ ព្រះរាជាសោឃរាជនៅដែនជម្ពូទ្វីប ព្រះនាម សោករាជ បានបញ្ជូនដើមមហាពោធិព្រឹក្ស គឺជាដើមឧទុម្ពរ (ដើមល្វា) ព្រះចៅនគរកោះលង្កា (វរទ្វីប) ព្រះនាមសមិទ្ធរាជ។ ភិក្ខុនីព្រះនាម កណកទន្តា ព្រមទាំងភិក្ខុនី ៥០០អង្គ បាននាំដើមពោធិព្រឹក្សនេះមក កាន់នគរកោះលង្កាដោយឫទ្ធិ។

ក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបទសពល កោះលង្កានេះ ឈ្មោះមណ្ឌទ្វីប ឧទ្យានត្រង់កន្លែងដាំដើមមហាពោធិព្រឹក្សនេះឈ្មោះ មហាសាលវ័ន។ ព្រះពុទ្ធកស្សបទសពល ព្រះអង្គបានត្រាស់ដឹងនៅ ក្រោមដើមជ្រៃ ឬហៅថា និគ្រោធព្រឹក្ស។ កាលណោះ ព្រះរាជា គ្រងរាជ្យក្នុងដែនជម្ពូទ្វីបព្រះនាមព្រហ្មទត្ត ព្រះអង្គបានប្រគេនដើម និគ្រោធព្រឹក្សដល់ភិក្ខុនីឈ្មោះសុធម្មាថេរី និងមួយអន្លើដោយភិក្ខុនី សង្ឃ៥០០អង្គ នាំយកដើមនិគ្រោធព្រឹក្សដោយឫទ្ធិ មកដាំនៅទីឋាន ដដែល តែកាលណោះមានឈ្មោះថា មហាសាលវ័ន។ កាលណោះ ព្រះរាជាគ្រងរាជ្យនៅក្នុងនគរកោះលង្កានេះព្រះនាមជយន្ត។


www.elibraryofcambodia.org

# ថូបារាម

ព្រះអរហន្តមហិន្ទត្ថេរ និងភិក្ខុសាវ័ក បានទិមន្តបកផ្សព្វផ្សាយព្រះពុទ្ធសាសនាថេរវាទ និងបានណែនាំឱ្យព្រះបាទទេវានម្បិយតិស្ស នៅក្នុងនគរកោះលង្កា ឱ្យកសាងព្រះចេតិយ សំរាប់ធ្វើសក្ការបូជា។ ថូបារាម គឺជាព្រះចេតិយទីមួយ ដែលបានកសាងឡើងនៅក្នុងនគរកោះលង្កា ព្រះចេតិយនេះមានរាងដូចជាពំនូកស្រូវ។ នៅខាងក្នុងព្រះចេតិយនេះ បានបញ្ចុះព្រះអដ្ឋកធាតុ (ឆ្អឹងដងកាំបិតខាងស្តាំ) របស់ព្រះសម្មាសម្ពុទ្ធ ដែលសុមនសាមណេរនាំមកអំពីឋានទេវលោក។

ប៉ុន្តែនៅសម័យកាលខាងក្រោយមក ព្រះចេតិយនេះត្រូវបានគេបំផ្លិចបំផ្លាញស្ទើរតែទាំងអស់ ហើយនៅក្នុងរជ្ជកាលព្រះបាទអគ្គពោធិ ព្រះអង្គបានរៀបចំកសាងជាថ្មីឡើងវិញ។ ព្រះចេតិយដែលនៅសល់នាពេលបច្ចុប្បន្ននេះ គឺបានកសាងឡើងនៅឆ្នាំ១៨៦២ ក្រោយពុទ្ធសករាជ។ បរិវេណនៃផ្ទៃព្រះចេតិយនេះ មានទំហំ ៥៩ ហ្វីត(១៦.១៥៤ម៉ែត្រ) ហើយមានកំពស់ ៦៣ហ្វីត (១៩.២០២ម៉ែត្រ)នៅលើខឿនកំពស់ ១១.២ហ្វីត(៣.៤១៣ម៉ែត្រ)។ ចំណែកឯនៅទីធ្លាជុំវិញ នៃព្រះចេតិយ គេបានក្រាលដោយថ្មក្រានិត ហើយនិងមានសសរថ្មបួនជួរមាន


www.elibraryofcambodia.org

ចំនួន១៧៦ដើម ដែលកាលពីសម័យដើមគេកសាងដំបូលគ្របពីលើព្រះចេតិយហៅថា ថូបឃរ ។



បណ្ឌិត ដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំងដី

គប្បីរក្សាចិត្តនេះ ដូចជាគេរក្សានូវនគរ យ៉ាងនោះឯង

គប្បីច្បាំងជាមួយនឹងមារដោយអាវុធគឺបញ្ញា

គប្បីរក្សានូវជម្នះដែលបានឈ្នះហើយ

តែមិនត្រូវជាប់ជំពាក់ក្នុងជម្នះនោះឡើយ ។

ធម្មបទ ចិត្តវគ្គ

www.elibraryofcambodia.org

# ចតុត្ថសង្គាយនា

នៅក្នុងរជ្ជកាលព្រះបាទទេវានម្បិយតិស្ស កាលណោះព្រះពុទ្ធសាសនាមានការរុងរឿងយ៉ាងខ្លាំងនៅក្នុងតម្ពបណ្ណិទ្វីប គឺប្រទេសស្រីលង្កា។ ព្រះរាជាព្រះអង្គទ្រង់ត្រាស់សួរព្រះមហិន្ទត្ថេរថា: បពិត្រលោកម្ចាស់ដ៏ចម្រើន! តើព្រះពុទ្ធសាសនាឥឡូវនេះបានតាំងនៅមាំក្នុងនគរកោះលង្កាហើយឬនៅ? ព្រះថេរៈថ្វាយព្រះពរថា: អូរ! មហារាជព្រះពុទ្ធសាសនាដែលនឹងបានតាំងនៅមាំទុំ លុះត្រាតែបានលើកតម្កើងព្រះធម៌វិន័យឱ្យបានល្អ ពោលគឺត្រូវធ្វើសង្គាយនា។ ពេលដែលបានឮដូច្នោះ ព្រះរាជាក៏បានចាត់ចែងរៀបចំធ្វើសង្គាយនា ទ្រង់បានអារាធនាព្រះមហិន្ទត្ថេរ ឱ្យជាអ្នកបុច្ឆា និងព្រះអរិដ្ឋមហាថេរ ឱ្យជាអ្នកវិសជ្ជនាប្រារព្ធធ្វើតាមលំនាំនៃរបៀបសង្គាយនាលើកទី៣ ដែលបានប្រារព្ធធ្វើនៅអសោការាម នាដែនបត្តលិបុត្ត។ កាលណោះ មានព្រះសង្ឃក្នុងនគរកោះលង្កាជាច្រើនបានរៀនចេះចាំព្រះពុទ្ធវចនៈ គឺព្រះធម៌វិន័យបានយ៉ាងច្បាស់លាស់ឥតមានសល់ចន្លោះឡើយ ហើយបានក្លាយជាអាចារ្យបង្ហាត់បង្រៀនដល់កុលបុត្រនៅក្នុងនគរកោះលង្កាបានយ៉ាងប្រសើរ ។

ចតុត្ថសង្គាយនានេះ បានធ្វើនៅក្នុងបរិវេណនៃព្រះចេតិយ

www.elibraryofcambodia.org

ថូបារាម នាក្រុងអនុរាធបុរី មានព្រះសង្ឃចូលរួមចំនួន ៦៨០០០អង្គ ។ ព្រះបាទទេវានម្បិយតិស្ស ដែលជាព្រះមហាក្សត្រនៃនគរកោះលង្កា ព្រះអង្គគឺជាសាសនូបត្ថម្ភ ។ ការប្រារព្ធធ្វើចតុត្ថសង្គាយនានេះមានរយៈពេល ១០ខែទើបចប់ ក្នុងរវាងព្រះពុទ្ធសករាជ ២៣៦ ។

របស់បានធរធេ គឺចាស់ជរា
របស់ប្រើឲរកគ្រប់គ្នា គឺគុណតម្លៃនៃជីវិត ។


www.elibraryofcambodia.org

# ព្រះបាទទុដ្ឋគាមិនីអភ័យ

ព្រះបាទទុដ្ឋគាមិនីអភ័យ ព្រះអង្គបានកសាងលោហប្រាសាទដែលមានសណ្ឋានដូចជាវិមានរបស់ទេវតានៃឋានតាវត្តិង្សទេវលោក ។ ប្រាសាទនេះកសាងតាមបែបបទដែលព្រះអរហន្តលោកប្រទានឱ្យ. ខាងលើមាន ៩ជាន់ និងមាន ១ជាន់ចុះទៅខាងក្រោម ហើយទាំងអស់មាន ១០០០ បន្ទប់ ។ សុវណ្ណមាលិកចេតិយ ព្រះអង្គបានបញ្ចុះព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ក្រោមការរៀបចំរបស់ព្រះអរហន្ត មួយព្រះអង្គព្រះនាមឥន្ទគុត្តត្ថេរ ។ ព្រះថេរៈអង្គនេះជាប្រធាន បញ្ចុះនូវបឋមសិលាមហាចេតិយ ។ កាលណោះព្រះអង្គបានចាត់ឱ្យសោនុត្តរសាមណេរ ដែលជាព្រះអរហន្តបដិសម្ភិទាឱ្យទៅអារាធនាព្រះសារីរិកធាតុមកអំពីពិភពនាគ ។ ព្រះសារីរិកធាតុនេះហើយ ដែលជាចំណែកមួយនៃព្រះធាតុទាំង ៨ចំណែក ដែលទោណព្រាហ្មណ៍ចែកទៅ២នាឡិ ឱ្យដល់នគររាមគ្រាម ។ ក្រោយមកនៅក្នុងនគរនេះបានជួបនូវគ្រោះមហន្តរាយ ដោយព្យុះសង្ឃរា និងមានទឹកជោរជន់ ធ្វើឱ្យលិចលង់និងបាក់បែកព្រះចេតិយ ហើយព្រះសារីរិកធាតុដែលតម្កល់នៅក្នុងព្រះចេតិយនេះ ក៏ត្រូវរសាត់អណ្តែត


www.elibraryofcambodia.org

រហូតដល់មហាសមុទ្រ។ ពេលនោះ ស្ដេចនាគឈ្មោះបញ្ញកនាគរាជ បានឃើញព្រះសារីរិកធាតុនេះ ក៏នាំយកទៅតម្កល់ទុកសម្រាប់ធ្វើសក្ការៈគោរពបូជា នៅនាឋានភុជង្គនាគនោះទៅ។

មានរឿងតំណាលថា: ព្រះបាទទុដ្ឋគាមិនីអភ័យ ចុះបើស្រុកទើបតែរួចផុតអំពីសង្គ្រាមនោះ តើព្រះអង្គបានទ្រព្យសម្បត្តិមកពីណាដើម្បីកសាងនូវព្រះចេតិយ និងប្រាសាទដ៏ស្កឹមស្កៃនោះបានទៅ? តាមការព្យាករណ៍របស់ព្រះសម្មាសម្ពុទ្ធថា នៅនគរកោះលង្កា សាសនារបស់ព្រះអង្គបានតាំងនៅមាំ និងយូរអង្វែងជាងទីណាៗទាំងអស់។ ព្រះសម្មាសម្ពុទ្ធកាលព្រះអង្គគង់ធរមាននៅឡើយ ព្រះអង្គបានយាងមកកាន់ដែនដីកោះនេះបីលើក. មិនតែប៉ុណ្ណោះព្រះអង្គទ្រង់បានផ្ដាំផ្ញើ នឹងសក្កទេវរាជដែលជាស្ដេចនៃទេវតាដោយព្រះពុទ្ធដីកាថា: សូមឱ្យមហារាជជួយទំនុកបំរុងផង នៅពេលដែលព្រះមហិន្ទត្ថេរនិមន្តមកផ្សាយសាសនារបស់ព្រះអង្គនៅលើកោះលង្កានេះ។ មានសេចក្ដីតំណាលថា: សក្កទេវរាជបានចាត់ឱ្យវិស្សុកម្មទេវបុត្រមកនិម្មិតជាឥដ្ឋគរទុកនៅកណ្ដាលព្រៃភ្នំ ហើយញុំាំងឱ្យព្រានប្រម៉ាញ់ម្នាក់បានឃើញគំនរឥដ្ឋដូច្នោះ ក៏បាននាំដំណឹងនេះមកថ្វាយដល់ព្រះរាជា។ ព្រះរាជាក្រោយពីទ្រង់បានជ្រាបនូវ


www.elibraryofcambodia.org

រឿងនេះព្រះអង្គមានព្រះទ័យរីករាយយ៉ាងខ្លាំង ហើយក៏បានប្រទានរង្វាន់ជាច្រើនដល់ព្រានព្រៃ និងដើម្បីឱ្យព្រានព្រៃនោះទៅដឹកជញ្ជូនត្បូងនោះមកថ្វាយព្រះអង្គ។ មិនតែប៉ុណ្ណោះ ព្រះអង្គក៏បានទទួលនូវទ្រព្យសម្បត្តិជាច្រើនដូចជាមាស ពេជ្រ កែវ ពិទូរ្យសូរ្យកាន្តផ្សេងៗ ដែលបានផុសអណ្តែតអំពីមហាសមុទ្រមកដល់ច្រាំងយ៉ាងសន្ធឹកសន្ធាប់។ ព្រះអង្គក៏បានឱ្យគេដឹកជញ្ជូនទ្រព្យសម្បត្តិទាំងនោះ មកដាក់ទុកក្នុងឃ្លាំងព្រះរាជទ្រព្យ ដើម្បីទុកជាប្រយោជន៍សម្រាប់នគរ និងទំនុកបំរុងព្រះពុទ្ធសាសនា ព្រមទាំងរៀបចំកសាងព្រះចេតិយ និងទីសក្ការៈគោរពបូជាផ្សេងៗទៀត។ ព្រះបាទទុដ្ឋគាមិនីអភ័យ ព្រះអង្គបានកសាងព្រះមហាចេតិយនេះពុំទាន់បានរួចស្រេចនោះនៅឡើយទេ ពេលនោះព្រះអង្គក៏មានអាពាធជាទម្ងន់។ ថ្វីត្បិតតែព្រះអង្គទ្រង់មានអាពាធដូច្នេះហើយក៏ដោយ ព្រះទ័យព្រះអង្គនៅជាប់ជំពាក់ក្នុងកិច្ចកសាងនេះដោយក្តីអាល័យជាទីបំផុត។ ព្រះរាជាទ្រង់ក៏បានផ្តាំផ្ញើឱ្យព្រះអនុជ ដែលស្នងរាជបន្តអំពីព្រះអង្គជួយបន្តកសាងព្រះចេតិយនេះឱ្យបានរួចរាល់ផង។

ព្រះអនុជរបស់ព្រះអង្គនោះព្រះនាមសទ្ធាតិស្ស បានទទួលចាត់



www.elibraryofcambodia.org

ចែងកសាងនូវមហាចេតិយនេះបន្តតាមការផ្ដាំផ្ញើរបស់ព្រះរាជា ដែលជាបង។ ប៉ុន្តែពេលនោះព្រះអនុជ ក៏បានខិតខំក្នុងការកសាងនេះយ៉ាងខ្លាំង ក៏ពុំអាចធ្វើឱ្យរួចជាស្ថាពរនោះទៅបាន ម្យ៉ាងវិញទៀតប្រឈួនរបស់ព្រះរាជាក៏កាន់តែដុនដាបខ្លាំងណាស់ទៅហើយ ទើបព្រះអង្គឱ្យគេយកក្រណាត់ពណ៌សមកបិទបាំងព្រះចេតិយ និងមានរំលេចក្បាច់រចនាយ៉ាងស្អាត ព្រមទាំងធ្វើស្វេតច្ឆ័ត្របាំងពីខាងលើហាក់បីដូចជាបានកសាងរួចស្រេច។ បន្ទាប់មកព្រះបាទសទ្ធាតិស្ស បានឱ្យគេលើកព្រះរាម (ទុដ្ឋគាមិនីអភ័យ) ទាំងកំពុងមានអាពាធធ្ងន់នោះ ដាក់ឱ្យផ្ទំនៅកន្លែងមួយដែលគេបានរៀបចំនៅចន្លោះមហាចេតិយ និងលោហប្រាសាទ ដើម្បីឱ្យព្រះអង្គបានទតឃើញ និងរំលឹកនូវបុណ្យដែលព្រះអង្គបានប្រារព្ធធ្វើកន្លងមក។ ពេលនោះព្រះបាទទុដ្ឋគាមិនីអភ័យ ទ្រង់ក៏បានក្រឡេកមើលគ្រប់ទិសទី ហើយបានឃើញនូវអ្វីៗទាំងអស់ ក៏ប៉ុន្តែព្រះអង្គពុំបានឃើញមហាមាត្យដែលធ្លាប់តែស្និទ្ធស្នាល និងជួយធ្វើសឹកសង្គ្រាមប្រឆាំងជាមួយនិងពួកទមិឡរហូតធ្វើឱ្យព្រះអង្គបានទទួលជ័យជំនះមិនដឹងទៅទីណា។ សូមបញ្ជាក់ថា: ក្រោយអំពីធ្វើសឹកសង្គ្រាម ហើយមហាមាត្យដែលធ្លាប់តែស្និទ្ធស្នាលនិងព្រះរាជានោះ គាត់ក៏បានចូលសាងព្រះផ្នួស



www.elibraryofcambodia.org

ហើយប្រតិបត្តិធម៌រហូតបានសម្រេចជាព្រះអរហន្ត ។

នៅពេលដែលព្រះរាជាបានរំលឹកឈ្មោះរបស់លោក១ ទ្រង់ជ្រាបហើយ ក៏បាននិមន្តមករកព្រះរាជា ដើម្បីទូន្មានព្រះរាជា ដោយពាក្យដាស់តឿនថា: អាត្មាធ្លាប់បានជួយព្រះអង្គក្នុងការធ្វើសិកសង្គ្រាមរហូតបានទទួលជ័យជំនះហើយក៏ពិតមែន តែឥឡូវនេះអាត្មាពុំអាចជួយព្រះអង្គទៀតទេ ពេលនេះមានតែទ្រង់មួយព្រះអង្គឯងត្រូវប្រយុទ្ធជាមួយមច្ចុរាជហើយ ។ ដូច្នេះការធ្វើសិកសង្គ្រាមជាមួយមច្ចុរាជនេះ ទ្រង់ប្រាកដជាមិនអាចគេចផុតនោះឡើយ ដូច្នេះសូមព្រះអង្គរំពឹងនឹកនូវបុណ្យកុសលដែលទ្រង់បានសាងសន្សំនោះជាទីពឹងចុះ ។

បន្ទាប់មកព្រះបាទទុដ្ឋគាមិនីអភ័យ ទ្រង់ក៏បានឱ្យព្រះថេរៈសូត្ររំលឹកនូវសកម្មភាពនៃបុណ្យ ដែលព្រះអង្គធ្លាប់បានធ្វើពីមុនឱ្យទ្រង់សណ្ដាប់ ។ ព្រះថេរៈក៏បានសូត្ររំលឹកបុណ្យទាំងអស់ នៅពេលដែលមហាមាត្យសូត្រមកដល់ត្រង់កន្លែងដែលព្រះរាជាថ្វាយចង្ហាន់បិណ្ឌបាតដល់ព្រះពោធិយមាណកតិស្សត្ថេរ. ពេលនោះទ្រង់មានបីតិជ្រះថ្លាកើតឡើង ជាអបរាបរចេតនាក្នុងមហាកុសល ដែលទ្រង់បានរំលឹកនឹកឃើញ ។ ពេលនោះ ព្រះរាជាក៏បានត្រាស់ឱ្យមហាមាត្យឈប់សូត្រត្រឹមកន្លែង


www.elibraryofcambodia.org

នេះ ព្រះអង្គក៏បានតាំងព្រះទ័យលើបុណ្យដែលទ្រង់បានធ្វើនោះ សូម្បីការកសាងព្រះមហាចេតិយ និង លោហប្រាសាទយ៉ាងស្កឹមស្កៃរបស់ព្រះអង្គនេះក៏មិនស្មើឡើយ ។ ក្រោយមកព្រះរាជាក៏បានត្រាស់សួរទៅព្រះសង្ឃដែលកំពុងស្វាធ្យាយធម៌ថ្វាយព្រះអង្គសណ្តាប់នាពេលនោះថា: លោកម្ចាស់ដ៏ចម្រើន! តើក្នុងឋានឆកាមាវចរសួគ៌ា ឋានមួយណាដែលគួរគាប់ហ្ន៎? ពេលនោះព្រះសង្ឃលោកក៏បានទូលទៅព្រះរាជាវិញថា: អូ! មហារាជ! មានតែឋានតុសិតទេ ដែលសមគួរជាងគេ, ព្រោះថាព្រះពោធិសត្វគ្រប់ព្រះអង្គតែងទៅបដិសន្ធិនៅឋាននេះ មុនពេលដែលព្រះអង្គបានមកត្រាស់ជាព្រះពុទ្ធ ។ ខណៈនោះ ព្រះរាជាក៏ក្រឡេកទៅមហាចេតិយ បន្ទាប់មកទ្រង់ក៏ក្រឡេកទៅលោហប្រាសាទ ដែលនៅជិតនោះ ហើយក៏បានបិទព្រះនេត្រសោយទិវង្គតនាពេលនោះទៅ ។ រំពេចនោះផងដែរ ព្រះអង្គក៏បានទៅកើតនាឋានតុសិតសួគ៌ានាពេលនោះឯងហោង ។

www.elibraryofcambodia.org

# សុវណ្ណមាលិកចេតិយ

ក្រោយពីបានទទួលជ័យជំនះលើពួកស្តេចទមិឡមក ព្រះបាទទុដ្ឋគាមិនីអភ័យក៏បានឡើងគ្រងរាជ្យ ជាស្តេចនៅក្នុងនគរកោះលង្កា។ ពេលនេះព្រះអង្គក៏មានឱកាសបំពេញនូវបំណងប្រាថ្នារបស់ព្រះអង្គដើម្បីធ្វើជាអ្នកឧបដ្ឋាកចំពោះព្រះពុទ្ធសាសនា ព្រះអង្គក៏បានកសាងនូវព្រះចេតិយ វត្ត ព្រះវិហារជាច្រើន ។ ក្នុងចំណោមនោះព្រះអង្គក៏បានកសាងនូវព្រះចេតិយដ៏ល្បីមួយឈ្មោះសុវណ្ណមាលិកចេតិយ ឬឈ្មោះរូវណ្ណវេលិសយចេតិយ។ ព្រះចេតិយនេះ បានកសាងឡើងដោយមានគ្រឹះដ៏រឹងមាំ នៅខាងក្នុងព្រះចេតិយមានបញ្ចុះនូវវត្ថុដ៏មានតម្លៃជាច្រើន ដូចជា មាស ពេជ្រ និងគ្រឿងអលង្ការផ្សេងៗ ដែលធ្វើអំពីមាសសុទ្ធ ក្នុងនោះក៏មានបញ្ចុះនូវព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ចំនួន២នាឡិផងដែរ។ នៅលើជញ្ជាំងខឿនទាំងបួនទិសមានកសាងរូបដំរីចំនួន១៩០០ដំរី ក្នុងទិសនីមួយៗ មាន៤៧៥ដំរី ដូច្នេះហើយខឿននេះគេឱ្យឈ្មោះថា ខឿនដំរី។ នៅលើទីធ្លា គេបានកសាងព្រះចេតិយតូចៗចំនួន៤ ធ្វើអំពីថ្មតាមលំនាំនៃមហាចេតិយ និង កសាងរូបសំណាកនៃព្រះបាទទុដ្ឋគាមិនីអភ័យ ដែលកំពុងថ្វាយបង្គំចំពោះព្រះចេតិយ។ ចំណែកឯ

www.elibraryofcambodia.org

នៅខាងក្នុងគុហា គេបានកសាងព្រះពុទ្ធរូបទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណបួនព្រះអង្គដែលបានត្រាស់ដឹងនៅក្នុងភទ្ទកប្បនេះ និងព្រះពុទ្ធរូបរបស់ព្រះសិអារ្យមេត្តេយ្យ ដែលត្រាស់នៅពេលអនាគត រីឯកំពូលនៃសុវណ្ណមាលិកចេតិយនេះ មានកំពស់ ២៤ហ្វីត( ៧.៣ ម៉ែត្រ) ។ គ្រឿងលំអដែលធ្វើអំពីត្បូងពេជ្រនៅផ្នែកខាងលើ គឺជាការបរិច្ចាគរបស់ប្រទេសភូមា ដើម្បីថ្វាយចំពោះព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ។ ព្រះចេតិយនេះមានចម្ងាយប្រមាណ២០០ ទៅ ៣០០ម៉ែត្រ អំពីលោហៈប្រាសាទ ។




សុវណ្ណមាលិកចេតិយ



www.elibraryofcambodia.org

## ព្រះបាទទុដ្ឋគាមិនីអភ័យ
## ប្រគេនចង្ហាន់បិណ្ឌបាតព្រះសង្ឃ

ក្នុងកាលដែលព្រះបាទទុដ្ឋគាមិនីអភ័យ ធ្វើចម្បាំងជាមួយនិងពួកទមិឡ គ្រានោះព្រះអង្គបានចាញ់ដៃពួកសត្រូវ ព្រះអង្គក៏បានជិះសេះគេចព្រះកាយចូលទៅកាន់ព្រៃជ្រៅជាមួយនិងមហាតលិកតិស្ស។ ព្រះរាជាទ្រង់បានឈប់សម្រាកនាកណ្ដាលព្រៃ ដោយក្ដីលំបាកនិងហេវហត់យ៉ាងខ្លាំង ក៏បានត្រាស់សួរមហាតលិកថាៈ តើអ្នកបានដាក់នូវអាហារភោជនអ្វីខ្លះដែរឬទេ? មហាតលិកតបថាៈ ទូលបង្គំបានខ្ចប់នូវក្រយាស្ងោយដាក់មកជាមួយបានខ្លះដែរ។ ពេលនោះ មហាតលិកក៏បានយកបង្វិចរបស់ខ្លួន ហើយបានស្រាយយកអាហារនៅក្នុងបង្វិចនោះមកថ្វាយដល់ព្រះរាជា។ ព្រះរាជាក៏បានត្រាស់បង្គាប់មហាតលិក ឱ្យបែងចែកអាហារនោះជាបួនចំណែក។ មហាតលិកឮព្រះរាជាត្រាស់បង្គាបដូច្នោះក៏ទូលសួរព្រះរាជាវិញថា បពិត្រព្រះអង្គដ៏ចម្រើន យើងមានគ្នាតែបីនាក់ទេ តើហេតុអ្វីបានជាព្រះអង្គឱ្យទូលបង្គំបែងជាចំណែកបួនអញ្ចឹង? ព្រះរាជាទ្រង់មានបន្ទូលតបវិញថាៈ ទោះក្នុងស្ថានភាពបែបណាក៏ដោយ ក៏យើងមិនដែលបោះបង់ការថ្វាយទានដល់សមណៈ ហើយយើងក៏មិនដែលសោយ


www.elibraryofcambodia.org

នូវអាហារមុនថ្វាយដល់ព្រះភិក្ខុសង្ឃនោះឡើយ ។ មហាតលិកឆ្លល់ ហើយក៏ទូលសួរព្រះអង្គទៀតថា ចុះនៅកណ្ដាលព្រៃស្ងាត់ជ្រងំអញ្ចឹង តើនឹងមានព្រះសង្ឃមកពីណា? ម្យ៉ាងទៀតទីនេះ មិនមែនជាទីគោចររបស់សមណៈទ្រង់និមន្តបិណ្ឌបាតអ្វីនោះដែរ? ព្រះរាជាត្រាស់តបថាៈ ចូលអ្នកកុំខ្វាយខ្វល់ច្រើនឡើយ អ្នកគ្រាន់តែប្រកាសអំពីភត្តកាល បវរណាចង្ហាន់បិណ្ឌបាតនេះដល់ព្រះសង្ឃទៅបានហើយ ។ ពេលនោះមហាតលិកក៏បានធ្វើតាមបញ្ជារបស់ព្រះអង្គ ក៏បានពោលពាក្យប្រកាសថាៈ បពិត្រលោកម្ចាស់ដ៏ចម្រើន ! ពេលនេះជាពេលសមគួរដល់ភត្តកាលហើយ សូមលោកម្ចាស់និមន្តមកទទួលចង្ហាន់បិណ្ឌបាត ដែលយើងខ្ញុំព្រះករុណាបានចាត់ចែងហើយនេះ ។ ភ្លាមនោះសម្លេងនេះបានផ្សាយទៅដល់សោតវិញ្ញាណនៃព្រះមហាពោធិយមាលកតិស្សត្ថេរ ដែលកំពុងគង់សមាធិនៅឯលោហប្រាសាទនៃវត្តមហាវិហារ ។ ព្រះថេរៈទ្រង់បានជ្រាប ហើយព្រះអង្គក៏និមន្តមកទទួលភត្ត នៅទីចំពោះព្រះភ័ក្ត្ររបស់ព្រះរាជានាកណ្ដាលព្រៃនោះដោយឫទ្ធិ ។ ព្រះរាជាទ្រង់ទតឃើញដូច្នោះព្រះអង្គមានព្រះទ័យរំភើប និងជ្រះថ្លាយ៉ាងក្រៃពេកទ្រង់ក៏បានត្រាស់ទៅមហាតលិកថា ខ្ញុំបានប្រាប់ហើយថាមានសមណៈ ឥឡូវនេះអ្នក


www.elibraryofcambodia.org

បានឃើញច្បាស់ហើយមែនទេ។ ព្រះរាជាដោយព្រះទ័យជ្រះថ្លាខ្លាំងពេក ក៏ភ្លេចអស់នូវការស្រេកឃ្លានរបស់ព្រះអង្គ។ ក៏បានយកចំណែករបស់ព្រះអង្គ ដាក់ចូលទៅក្នុងបាទរបស់ព្រះថេរៈ រីឯមហាតលិកឃើញដូច្នោះ មិនអាចបរិភោគទៅកើតតែម្នាក់ឯង ក៏បានបូជានូវចំណែករបស់ខ្លួនដល់ព្រះថេរៈនាពេលនោះដែរ។ ចំណែកឯសេះវិញ ឃើញព្រះរាជាដែលជាម្ចាស់របស់ខ្លួនធ្វើដូច្នោះ វាក៏បានសម្រេចចិត្តឱ្យព្រះរាជាយកចំណែករបស់វា ដាក់បូជាទៅក្នុងបាត្ររបស់ព្រះថេរៈនោះដែរទៅ។ ព្រះពោធិយមានកតិស្សត្ថេរ ព្រះអង្គក៏បានយកចង្ហាន់បិណ្ឌបាតនោះមកបែងចែកដល់ព្រះសង្ឃទាំងឡាយ ដែលគង់នៅឯវត្តមហាវិហារ។ ដំណាលគ្នានោះដែរ ព្រះរាជាក៏បានដល់នូវសេចក្តីស្រេចឃ្លានជាខ្លាំងទ្រង់បាននឹកតែក្នុងព្រះទ័យថា ប្រសិនបើបានចង្ហាន់បិណ្ឌបាតដែលសេសសល់អំពីព្រះសង្ឃខ្លះ ទោះបីតិចតួចក្តីក៏ជាការគួរដែរហ្ន៎!។ ព្រះពោធិយមានកតិស្សត្ថេរ ពេលនោះព្រះអង្គក៏ទ្រង់បានជ្រាបអំពីបរិវិតក្កគឺសេចក្តីស្រេចឃ្លានរបស់ព្រះរាជា ក្រោយដែលឆាន់រួច ព្រះថេរៈក៏បានដាក់ចង្ហាន់ចូលក្នុងបាត្រ ហើយអធិដ្ឋានឱ្យបាត្រនោះអណ្តែតទៅតាមអាកាស មកឋិតនៅលើព្រះហស្តរបស់ព្រះរាជា។ ព្រះរាជាក្រោយពី


www.elibraryofcambodia.org

បានទទួលចង្ហាន់បិណ្ឌបាតនោះហើយ ទ្រង់ក៏បានចែកឱ្យទៅមហាតលិក និងសេះហើយ ទើបទ្រង់សោយខ្លួនព្រះអង្គឯង។ បន្ទាប់អំពីសោយរួច ព្រះអង្គក៏បានលាងជូតបាត្រនោះ យ៉ាងស្អាតហើយបានដាក់សំពត់ដណ្តប់ចូលទៅក្នុងបាត្រ ឱ្យគ្រាន់តែបានជាទេយ្យទានដើម្បីកុំឱ្យបាត្រទទេ រួចព្រះអង្គអធិដ្ឋានឱ្យបាត្រនោះត្រឡប់ទៅដល់ព្រះថេរៈវិញ។ នេះគឺជាចេតនារលឹកនឹកដល់អំពើល្អណាមួយដែលបណ្តាលឱ្យព្រះអង្គចេះតែកើតមានសេចក្តីជ្រះថ្លាពុំដែលមានភ្លេចម្តងណាឡើយ។

សុខលោកីយ៍ បានអ្វីៗ ត្រឹមមួយគ្រា
សុខធម្មា គ្រប់វេលា រហូតត្រើយ
ចង់គេចទុក្ខ កុំសម្រុក រឿងភៀកភើយ
រៀនធម៌ហើយ កុំព្រងើយ ត្រូវចេះក្រែង។

www.elibraryofcambodia.org

# លោហៈប្រាសាទ

លោហៈប្រាសាទនេះបានកសាងនៅចន្លោះសុវណ្ណមាលិកចេតិយ និងដើមមហាពោធិព្រឹក្ស សំរាប់ព្រះភិក្ខុសង្ឃធ្វើឧបោសថកម្ម និងសង្ឃកម្មផ្សេងៗ។ លោហៈប្រាសាទ ត្រូវបានកសាងឡើងដោយព្រះបាទទុដ្ឋគាមិនីអភ័យ ដែលធ្វើតាមលំនាំប្រាសាទនាឋានតាវត្តឹង្សទេវលោក។ ប្រាសាទនេះមាន៩ជាន់ និងមាន១០០០បន្ទប់ ដែលមានដំបូលប្រក់ក្បឿងធ្វើអំពីស្ពាន់ ដូច្នេះហើយទើបគេឱ្យឈ្មោះប្រាសាទនេះថាលោហៈប្រាសាទ។ ជ្រុងនីមួយៗនៃប្រាសាទ មានប្រវែង៤០០ហ្វីត (១២១.៩២ម៉ែត្រ) និងមានសសរ ៤០ជួរ ក្នុងជួរនីមួយៗមានសសរ ៤០ដើម សរុបទាំងអស់ មានសសរ ១៦០០ដើម ដែលធ្វើអំពីថ្ម។ ការកសាងនេះអស់រយៈពេលប្រាំមួយឆ្នាំទើបរួច។ ប្រាសាទនេះត្រូវបានគេបំផ្លិចបំផ្លាញនៅក្នុងរជ្ជកាលព្រះបាទសទ្ធាតិស្ស។





www.elibraryofcambodia.org

## អភយគិរីចេតិយ

ព្រះបាទវដ្តគាមិនីអភ័យ បានឡើងគ្រងរាជ្យនៅក្នុងនគរកោះលង្កា នៅឆ្នាំ ១០៣ ក្រោយពុទ្ធសករាជ ក្រោយមកព្រះអង្គក៏ត្រូវបានពួកទមិឡដណ្តើមរាជសម្បត្តិ។ នៅពេលដែលព្រះបាទវដ្តគាមិនីអភ័យបានរត់គេចអំពីសង្គ្រាមចេញពីក្រុងអនុរាធបុរី ពេលនោះមាននិគ្រន្ថម្នាក់ឈ្មោះគិរី បានស្រែកចំអកចំពោះព្រះអង្គដោយពាក្យមើលងាយថា អា! ស្តេចខ្មៅចាញ់ហើយ អា! ស្តេចខ្មៅរត់ទៅហើយ។ ក្រោយមកព្រះបាទវដ្តគាមិនីអភ័យក៏បានប្រមូលពលសេនា ហើយបានធ្វើសង្គ្រាមនិងបានសម្លាប់ពួកទមិឡអស់។ ក្រោយទទួលជ័យជំនះអំពីពួកទមិឡព្រះបាទវដ្តគាមិនីអភ័យ ព្រះអង្គបានឡើងគ្រងរាជ្យជាថ្មី។ ពេលនោះព្រះអង្គក៏បានបំផ្លាញចោលវត្តរបស់ពួកនិគ្រន្ថ ហើយបានកសាងវត្តថ្មីមួយនៅកន្លែងនោះវិញ បានដាក់ឈ្មោះវត្តនោះថា អភ័យគិរីវិហារថ្វាយដល់ព្រះថេរៈមួយព្រះអង្គព្រះនាមតិស្ស ដែលបានជួយព្រះរាជាអំពីកាលដែលទ្រង់រត់គេចចេញពីសង្គ្រាម។

ក្រោយមកមិនយូរប៉ុន្មាន ព្រះសង្ឃដែលគង់នៅវត្តមហាវិហារដែលជាអ្នកប្រតិបត្តិតាមព្រះវិន័យក៏បានលើកទោសប្រឆាំងនឹងតិស្ស


www.elibraryofcambodia.org

ភិក្ខុ ដែលគង់នៅក្នុងវត្តអភយគិរី ដែលមិនប្រព្រឹត្តប្រតិបត្តិតាមព្រះវិន័យ។ ក្រោយមកតិស្សភិក្ខុ ក៏បានបង្កើតជានិកាយថ្មីមួយសម្រាប់ខ្លួន និងបរិវារ ដែលមានព្រះរាជាជាអ្នកជួយឧបត្ថម្ភ។ ក្នុងរជ្ជកាលរបស់ព្រះបាទវដ្ដគាមិនីអភ័យនេះ គឺជាបញ្ហាដ៏សំខាន់ទីមួយដែលព្រះសង្ឃក្នុងព្រះពុទ្ធសាសនាបែកបាក់គ្នានៅក្នុងនគរកោះលង្កា។

ក្រោយមកវត្តអភយគិរី មានភិក្ខុបញ្ញវន្តជាច្រើនគង់ស្នាក់នៅទីនេះមានបណ្ណាល័យដ៏ធំ សម្រាប់តម្កល់គម្ពីរក្បួនច្បាប់ដើម្បីសិក្សា។ បណ្ណាល័យនេះត្រូវបានបំផ្លាញចោល និងភិក្ខុសង្ឃដែលប្រព្រឹត្តខុសនឹងព្រះវិន័យត្រូវបានគេបណ្ដេញចេញអំពីវត្តអភយគិរី នៅក្នុងរជ្ជកាលព្រះបាទវោហារកតិស្ស និងគោឋាភយ។ ព្រះចេតិយក្នុងវត្តអភយគិរីនេះត្រូវបានកសាងជាថ្មីនៅក្នុងរជ្ជកាលព្រះបាទបរាក្រមបាហុ ដែលមានកំពស់ ៤០០ហ្វីត (១២១.៩២ម៉ែត្រ)។ ក្នុងព្រះចេតិយនេះមានបញ្ចុះព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ។




www.elibraryofcambodia.org

# ព្រះបាទមហាសេន

ព្រះបាទគោធាភយ (Gothabhaya) ដែលបានស្នងរាជបន្តអំពីព្រះបាទសិរីសង្គពោ ព្រះអង្គមានព្រះរាជបុត្រពីរព្រះអង្គ។ ព្រះរាជបុត្រច្បងព្រះនាមជេដ្ឋាតិស្ស និងព្រះអនុជព្រះនាមមហាសេន។ គោធាភយ (Gothabhaya) បានបញ្ជូនព្រះរាជបុត្រទាំងពីររបស់ព្រះអង្គឱ្យទៅសិក្សាជាមួយនឹងភិក្ខុសង្ឃមួយព្រះអង្គព្រះនាមសង្ឃមិត្តា ដែលបាននិមន្តមកអំពីប្រទេសឥណ្ឌាភាគខាងត្បូង។ ព្រះអង្គសង្ឃមិត្តាបានបួសក្នុងនិកាយវ៉ិត្តល្លិយ ហើយបានគង់នៅក្នុងវត្តអភ័យគិរី ព្រះអង្គក៏ជាអ្នកដែលបានបង្កឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់នៅក្នុងព្រះពុទ្ធសាសនា ហើយជាពិសេសព្រះអង្គបានបង្កឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ចំពោះព្រះសង្ឃដែលគង់នៅក្នុងវត្តមហាវិហារ។

មហាសេនតាំងពីកុមារភាព ព្រះអង្គបានឋិតនៅក្រោមឥទ្ធិពលនៃអាចារ្យបង្ហាត់បង្រៀនរបស់សង្ឃមិត្តាដែលជាអាចារ្យ។ ក្រោយអំពីព្រះបាទជេដ្ឋាតិស្ស ដែលជាអ្នកស្នងរាជអំពីព្រះបិតា ព្រះអង្គបានចូលទីវង្គតទៅ មហាសេនដែលជាព្រះអនុជព្រះអង្គបានឡើងធ្វើជាស្តេចគ្រងរាជ្យបន្ត ព្រះអង្គបានតែងតាំងសង្ឃមិត្តាជាទីប្រឹក្សា និងជាព្រះរាជ


www.elibraryofcambodia.org

ត្រូវរបស់ព្រះអង្គ។ ភិក្ខុសង្ឃមិត្តា ព្រះអង្គបានពន្យល់ និងណែនាំព្រះរាជាថ្មីអង្គនេះ ឱ្យប្រព្រឹត្តធ្វើនូវអំពើមិនគប្បីជាច្រើនប្រឆាំងនឹងព្រះពុទ្ធសាសនា មានការបំផ្លាញនូវកន្លែងសម្រាប់គោរពបូជា ក៏ដូចជាកន្លែងសម្រាប់គោរពបូជារបស់សាសនាព្រហ្មញ្ញ ដែលបានកសាងនៅក្នុងសម័យស្ដេចទមិឡឈ្មោះឥឡារៈនោះផងដែរ។ ព្រះអង្គបានដឹកនាំស្ដេចមហាសេន ឱ្យជឿនៅក្នុងនិកាយវត្តល្បីយរបស់លោកវិញ។

នៅពេលដែលស្ដេចមហាសេន បានបង្កនូវគ្រោះថ្នាក់ជាច្រើនដល់ព្រះពុទ្ធសាសនាដូច្នេះ មន្ត្រីម្នាក់ឈ្មោះមេឃវណ្ណភយ ដែលជាមិត្តសម្លាញ់ដ៏ជិតស្និទ្ធជាមួយនិងព្រះអង្គតាំងពីកុមារភាពមកនោះ ក៏បានក្រោកឈរប្រឆាំងនិងព្រះរាជាវិញ។ ពេលនោះមេឃវណ្ណភយ ក៏បានរត់គេចខ្លួនទៅកាន់តំបន់រុហុនៈ (Ruhuna) ហើយក៏បានបង្កបង្កើតទ័ពប្រឆាំង និងព្រះបាទមហាសេន ដើម្បីស្រោចស្រង់ប្រទេសឱ្យរួចផុតអំពីគ្រោះមហន្តរាយ ដែលបានបង្កឡើងដោយស្ដេចមហាសេន និងព្រះរាជគ្រូរបស់ព្រះអង្គ។ មុនពេលសង្គ្រាមចាប់ផ្ដើមកើតឡើង មេឃវណ្ណភយក៏បានលបចូលទៅក្នុងព្រះរាជដំណាក់របស់ព្រះបាទមហាសេន ហើយបានទូលថ្វាយទ្រង់អំពីគ្រោះមហន្តរាយដែលបានបង្កឡើងដោយសារ


www.elibraryofcambodia.org

តែព្រះអង្គជឿនូវពាក្យញុះញង់អំពីភិក្ខុសង្ឃមិត្តា ដែលធ្វើឱ្យមាន គ្រោះថ្នាក់យ៉ាងខ្លាំងដល់ព្រះពុទ្ធសាសនា។ ក្រោយអំពីព្រះរាជាទ្រង់ ព្រះសណ្តាប់នូវរឿងនេះ ព្រះអង្គក៏បានយល់ច្បាស់ ហើយក៏មានការ សោកស្តាយនូវកំហុស ដែលទ្រង់បានធ្វើក្នុងកាលកន្លងមក។ ដើម្បី ជៀសវាងកុំឱ្យកើតមាននូវសង្គ្រាម ព្រះអង្គក៏បានកែខ្លួន ហើយត្រឡប់ មកធ្វើជាស្តេចដ៏ល្អ និងជាអ្នកជួយទំនុកបំរុងដល់ព្រះពុទ្ធសាសនា ដោយ ការចាប់ផ្តើមកសាងឡើងវិញនូវបូជនីយដ្ឋានគ្រប់ទីកន្លែង សម្រាប់ធ្វើ សក្ការគោរពបូជា ក្នុងនោះមានវត្តមហាវិហារ លោហប្រាសាទ និង ទីកន្លែងផ្សេងៗទៀត ដែលព្រះអង្គបានបញ្ជាឱ្យគេបំផ្លាញក្នុងកាលកន្លង ទៅនោះ។ ចំណែកឯភិក្ខុសង្ឃមិត្តា ដែលជាព្រះសង្ឃមានគំនិតអាក្រក់ នោះ ក្រោយមកក៏ត្រូវបានប្រជាជនចាប់វាយធ្វើបាបរហូតដល់ទទួល អនិច្ចកម្មបាត់ទៅ។

ក្នុងកាលជាខាងក្រោយមកទៀតព្រះបាទមហាសេន ព្រះអង្គក៏ បានកសាង វត្ត វិហារ ព្រះស្តូប ក្នុងនោះព្រះអង្គក៏បានកសាងព្រះស្តូប ដ៏ធំមួយនៅក្នុងក្រុងអនុរាធបុរី នោះគឺៈ ព្រះស្តូប និងវត្តជេតវនារាម សម្រាប់ព្រះសង្ឃគង់នៅផងដែរ។ មិនតែប៉ុណ្ណោះព្រះអង្គក៏បានកសាង


www.elibraryofcambodia.org

នូវប្រឡាយ និងទំនប់ទឹកជាច្រើនកន្លែង សម្រាប់ប្រជាជនប្រើប្រាស់ ហើយនឹងអាចស្រោចស្រប់នៅលើផ្ទៃដីសំរាប់ដាំដំណាំផ្សេងៗបានយ៉ាងច្រើនហិចតាទៀតផង។

ព្រះបាទមហាសេន ព្រះអង្គបានឡើងគ្រងរាជ្យនៅក្នុងនគរកោះលង្កា ពីឆ្នាំ ២៧៦-៣០៦ ក្រោយ ព.ស ព្រះអង្គបានចូលទិវង្គតនៅឆ្នាំ ៣០៦ ក្រោយព.ស។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមកិត្តិស្រីមេឃវណ្ណ ទ្រង់ឡើងគ្រងរាជ្យបន្ត។ ព្រះទន្តធាតុរបស់ព្រះសម្មាសម្ពុទ្ធដែលនាំមកកាន់នគរកោះលង្កា ដោយព្រះនាងហេម្មមាលា និងព្រះរាជកុមារទន្តមកអំពីទន្តបុរៈក្នុងដែនគលិង្គនោះ គឺនៅក្នុងរជ្ជកាលរបស់ព្រះរាជាកិត្តិស្រីមេឃវ័ន។


www.elibraryofcambodia.org

# ជេតវនចេតិយ

ព្រះបាទមហាសេន បានឡើងគ្រងរាជ្យ (២៧៣-៣០៦) ក្រោយពុទ្ធសករាជ ព្រះអង្គបានកសាងព្រះចេតិយដ៏ធំមួយនៅក្នុងវត្តជេតវនារាមនៃនគរកោះលង្កា។ ព្រះចេតិយនេះមានឈ្មោះថាជេតវនារាមចេតិយដែលបានកសាងនៅក្នុងឧទ្យានរបស់មហាឧបាសកម្នាក់ឈ្មោះជោតិ។ ខាងក្នុងនៃព្រះចេតិយគេបានបញ្ចុះវត្ថុពន្ធរបស់ព្រះសម្មាសម្ពុទ្ធ។ ព្រះចេតិយមានកំពស់ ២៣២ ហ្វីត (៧០.៧១៣ម៉ែត្រ) ឋិតនៅក្នុងវត្តជេតវនារាម នៃនិកាយសាគលិក។ ផ្ទៃដីនៃវត្តនេះមាន ៨ អេឃើ (៣.២៣៧ ហិកតា) ជ្រុងនីមួយៗនៃព្រះចេតិយមានប្រវែង ៥៧៦ ហ្វីត (១៧៥ .៥៦៤ ម៉ែត្រ)និងមានជណ្ដើរឡើងគ្រប់ជ្រុងទាំងអស់។ ជណ្ដើរនីមួយៗ មានទទឹង ២៨ ហ្វីត (៨.៥៣៤ ម៉ែត្រ)។ ច្រកទ្វារចូលទៅកាន់បរិវេណនៃព្រះចេតិយមានកំពស់ ២៧ ហ្វីត (៨.២២៩ ម៉ែត្រ) និងមានគ្រឹះជម្រៅ ១ហ្វីត (០.៣០៤ ម៉ែត្រ)។ នៅលើទីធ្លានៃព្រះចេតិយ ក៏មានចារឈ្មោះសប្បុរសជនដែលបានបរិច្ចាគក្នុងការកសាងនៅលើផ្ទាំងសិលានោះផងដែរ។

www.elibraryofcambodia.org

# មិរិស្សវេទិចេតិយ

ក្រោយពេលដែលព្រះបាទទុដ្ឋគាមិនីអភ័យ បានបណ្តេញស្តេចនៃពពួកចោរទមិឡឈ្មោះអេឡារៈ ហើយព្រះអង្គក៏បានកសាងមិរិស្សវេទិចេតិយ នៅត្រង់ទីកន្លែងដែលព្រះអង្គបានដាក់ព្រះធាតុ និងដំបងរាជ នៅពេលដែលព្រះអង្គយាងទៅស្រង់សុគន្ធវារី (ងូតទឹក) នៅក្នុងបឹងតិសាវេវៈ។ នៅពេលដែលព្រះអង្គយាងត្រឡប់មកកាន់ទីកន្លែងនោះវិញ ព្រះអង្គពុំអាចលើកនូវព្រះធាតុ និងដំបងអំពីទីនោះបាន។ មានសេចក្តីតំណាលមួយផ្សេងទៀតថា នៅមុនពេលដែលព្រះអង្គសោយនូវព្រះស្ងោយ ព្រះអង្គតែងតែបូជាចង្ហាន់ដល់ព្រះភិក្ខុសង្ឃ ប៉ុន្តែក្រោយមកនៅពេលដែលព្រះអង្គបានសោយនូវមធុបាយ និងម្ទេសបុកដោយមិនបានប្រគេនដល់ព្រះសង្ឃ ទ្រង់ក៏បានដាក់ទណ្ឌកម្មខ្លួនឯង ដោយកសាងមិរិស្សវេទិចេតិយ និងថ្វាយដល់ព្រះភិក្ខុសង្ឃ ដើម្បីរំលឹកនូវកំហុសរបស់ព្រះអង្គ។ ព្រះចេតិយនេះមានកំពស់ ១៦០ ហ្វីត (៤៨.៧៦៨ ម៉ែត្រ) នៅលើផ្ទៃដី ៥០ អេឃឺ (២០.២៣៥ ហិកតា)។ តាមជំនឿរបស់ប្រជាជនស្រីលង្កាថា ក្នុងព្រះចេតិយនេះមានតម្កល់ព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធផងដែរ។


www.elibraryofcambodia.org

# វត្តឥសុរុមុនី

នៅក្រោយពេលដែលមានកុលបុត្រចំនួន៥០០នាក់ មកអំពីត្រកូលខ្ពង់ខ្ពស់ បានចូលសាងព្រះផ្នួសនៅក្នុងព្រះពុទ្ធសាសនា ព្រះបាទទេវានម្បិយតិស្ស ក៏បានកសាងវត្តឥសុរុមុនីនេះ នៅក្បែរបឹងតិសាវេវៈ ដើម្បីថ្វាយដល់ភិក្ខុទាំង៥០០អង្គ គង់ស្នាក់អាស្រ័យ ។ នៅក្រោយពុទ្ធសករាជ ៤៧៣-៤៩១ ព្រះបាទកស្សបបានកសាងវត្តនេះជាថ្មី ហើយបានដាក់ឈ្មោះវត្តនេះ ដោយភ្ជាប់ជាមួយព្រះនាមរបស់ព្រះអង្គ និងព្រះនាមរបស់ព្រះរាជបុត្រីទាំងពីរអង្គថា បុប្ផវិន. កស្សគិរី វង្គមហាវិហារ។ នៅក្នុងទីវត្តនេះមានគុហា និងមានភ្នំមួយបែកញែកពីគ្នា មានរាងដូចជាភ្លុកដំរីនៅខាងលើកំពូលភ្នំ គេបានកសាងព្រះចេតិយតូចមួយសម្រាប់ធ្វើសក្ការបូជា។ នៅផ្នែកខាងក្រោមនៃកូនភ្នំទាំងពីរ គេបានឆ្លាក់រូបដំរីនិងសេះនៅលើផ្ទាំងថ្មក្បែរស្រះទឹក ចំណែកឯគ្រែគូរស្នេហ៍ដែលធ្វើអំពីថ្មនោះ គេបាននាំមកអំពីទីកន្លែងផ្សេង ហើយក៏បានយកមកទុកដាក់នៅក្នុងវត្តឥសុរុមុនី។ មង្គលឧទ្យាននៅមិនឆ្ងាយអំពីទីនេះឡើយ ។



www.elibraryofcambodia.org

## ព្រះពុទ្ធអវុខណៈ

អវុខណៈ គឺជាភូមិតូចមួយដែលស្ថិតនៅក្នុងស្រុកអនុរុធគ្រាម។ ព្រះពុទ្ធរូបទ្រង់ឈរឱ្យអភ័យ ដែលធ្វើអំពីថ្មអង្គនេះ គឺជាព្រះពុទ្ធរូបធំជាងគេនៅក្នុងប្រទេសស្រីលង្កា និងមានព្រះភ័ក្ត្របែរទៅបឹងកាលវេវៈ ដែលបានកសាងឡើងដោយព្រះបាទធាតុសេន។ ព្រះពុទ្ធរូបអង្គនេះមានកំពស់ ៤២ ហ្វីត (១២.៨០១៦ ម៉ែត្រ) រួមទាំងបល្ល័ង្កទ្រ។




www.elibraryofcambodia.org

# ព្រះបាទធាតុសេន

ធាតុសេន បានប្រសូត្រនៅក្នុងក្រុមគ្រួសារធម្មតាមួយនៃត្រកូលមោរិយៈ។ កាលពីកុមារភាព ធាតុសេនបានរស់នៅ និងសិក្សាជាមួយឪពុកមារបស់គាត់ ដែលបួសជាព្រះសង្ឃ។ ព្រះសង្ឃអង្គនេះលោកបានដឹងថា ក្មួយរបស់ព្រះអង្គនឹងបានក្លាយជាស្តេចដ៏ល្អមួយអង្គនាពេលអនាគត។ ដូច្នេះព្រះអង្គក៏បានខិតខំបណ្តុះបណ្តាលធាតុសេនយ៉ាងអស់ពីសមត្ថភាពរាល់មុខជំនាញផ្សេងៗ និងរបៀបនៃការគ្រប់គ្រងប្រទេសហើយក៏បានបំបួសជាសាមណេរដល់ធាតុសេនផងដែរ។ ក្រោយមក នៅពេលដែលធាតុសេន មានវ័យធំឡើងព្រះអង្គក៏បានលាចាកសិក្ខាបទអំពីព្រះផ្នួស ហើយបានចូលទៅសិក្សាផ្នែកខាងសិកសង្គ្រាម និងបានបង្កើតនូវពលសេនា ដើម្បីប្រឆាំងនិងពួកឈ្លានពាន ដែលបានមកពីភាគខាងត្បូងនៃប្រទេសឥណ្ឌា។ នៅពេលដែលពួកត្រាវីឌាន (Dravi dians) ដែលគ្រប់គ្រងនៅភាគខាងជើងប្រទេសស្រីលង្កា ក្នុងតំបន់រាជរដ្ឋ (Rajarata) បានដឹងថា ធាតុសេនធ្វើការបះបោរ ពួកគេក៏បានព្យាយាមម្តងហើយម្តងទៀតដើម្បីសម្លាប់ធាតុសេន ក៏ប៉ុន្តែមិនបានសម្រេចឡើយ។


www.elibraryofcambodia.org

ក្រោយមក ធាតុសេន និងពលសេនាក៏បានធ្វើសឹកសង្គ្រាមតតាំង ជាមួយនិងពួកបរទេសឈ្លានពានទាំងនេះអស់រយៈពេល២០ឆ្នាំ ទើប ទទួលបានជ័យជំនះ។ ដោយការដឹកនាំដ៏ឈ្លាសវៃរបស់ធាតុសេន ទើប នគរកោះលង្កាទទួលបានឯករាជ្យ និងមានសុខសន្តិភាព។ ប្រជានុរាស្ត្រ និងមន្ត្រីទាំងឡាយ ក៏បានតែងតាំងធាតុសេន ឱ្យឡើងធ្វើជាស្តេចគ្រង រាជ្យ (៤៥៩-៤៧៧ ក្រោយ ព.ស)។ ចាប់តាំងអំពីព្រះរាជាថ្មីអង្គនេះ បានឡើងគ្រងរាជ្យសម្បត្តិមក ព្រះបាទធាតុសេនក៏បានចាប់ផ្តើមស្តារ និងកសាងនគរ ដែលបានខូចខាតដោយសារសង្គ្រាម មិនតែប៉ុណ្ណោះ ទ្រង់ក៏បានកសាងប្រឡាយ និងទំនប់ទឹកចំនួន ១៨កន្លែង រួមទាំងទំនប់ កាលវេវៈ។ ម្យ៉ាងវិញទៀត ព្រះអង្គក៏បានជួសជុលនូវទីសក្ការៈ ព្រម ទាំងព្រះស្តូបទាំងឡាយ ដែលបានបាក់បែកដោយសារការបំផ្លិចបំផ្លាញ នៅក្នុងអំឡុងពេលដែលពួកបរទេសគ្រប់គ្រង។

ព្រះបាទធាតុសេន ក៏បានកសាងវត្តអារាមថ្មី ចំនួន ១៨កន្លែង ហើយពិសេសជាងនេះទៅទៀត ព្រះអង្គបានកសាងព្រះពុទ្ធរូបទ្រង់ឱ្យ អភ័យមួយព្រះអង្គដ៏ធំ ដែលធ្វើអំពីថ្ម (ព្រះពុទ្ធអវុខណៈ) ។ ព្រះបាទ ធាតុសេន គឺជាស្តេចដែលប្រកបដោយបញ្ញាញាណ ទ្រង់ក៏បានកសាង


www.elibraryofcambodia.org

នូវស្នាប្រហស្ដដ៏ច្រើននៅក្នុងនគរកោះលង្កា។ ព្រះអង្គគ្រងរាជ្យបាន ១៨ ឆ្នាំ ក៏ត្រូវបានព្រះរាជបុត្ររបស់ព្រះអង្គ ព្រះនាមកស្សបធ្វើគត់ ដើម្បីដណ្ដើមរាជ ។

អ្នកមានវិជ្ជាមិនល្ងង់ខ្លៅ
នោះបីខ្លួនខ្មៅមុខក្រខ្វះ
អាក្រក់តែរូបប៉ុន្តែចេះ
អ្នកនោះគេថាជាមនុស្សល្អ។


www.elibraryofcambodia.org

# ភ្នំមហិន្ទលេ

ភ្នំមហិន្ទលេ ស្ថិតនៅភាគខាងកើតនៃក្រុងអនុរាធបុរី ដែលមានចម្ងាយប្រមាណ ៨ម៉ៃ (១២. ៨៧២ គីឡូម៉ែត្រ) ។ ភ្នំនេះមានកំពស់ ១000ហ្វីត (៣0៤.៨ ម៉ែត្រ) និងជាភ្នំខ្ពស់មួយក្នុងចំណោមភ្នំទាំងឡាយនៅតំបន់នេះ ។ ភ្នំនេះមានឈ្មោះផ្សេងទៀតដូចជាៈ មិសកបពិត, ចេតិយគីរី ឬសាគីរី ក៏ប៉ុន្តែតាំងអំពីពេលដែលព្រះមហិន្ទត្ថេរនិមន្តមកផ្សព្វផ្សាយព្រះពុទ្ធសាសនាដំបូងនៅទីកន្លែងនេះ, ភ្នំនេះក៏ត្រូវបានគេហៅជាទូទៅថាៈ ភ្នំមហិន្ទលេ តរៀងមក ។

ព្រះមហិន្ទត្ថេរ បាននិមន្តមកផ្សព្វផ្សាយព្រះពុទ្ធសាសនានៅនគរកោះលង្កានេះ គឺនៅថ្ងៃ១៥ កើត ពេញបូណ៌មី ខែជេស្ឋ ។ ព្រះអង្គបានជួបជាមួយព្រះបាទទេវានម្បិយតិស្ស និងពលសេនារបស់ព្រះអង្គនៅនាភ្នំមហិន្ទលេ ។ ព្រះអង្គក៏បានសម្តែងនូវព្រះធម៌ ដើម្បីអនុគ្រោះដល់ព្រះរាជា និងពលសេនានៅទីនេះ ។ ជារៀងរាល់ឆ្នាំ នៅថ្ងៃពេញបូណ៌មីខែជេស្ឋ ប្រជាជនស្រីលង្កា អ្នកកាន់ព្រះពុទ្ធសាសនាតែងតែធ្វើធម្មយាត្រាទៅកាន់ក្រុងអនុរាធបុរី និងភ្នំមហិន្ទលេនេះ ដើម្បីថ្វាយបង្គំទីកន្លែងដែលព្រះមហិន្ទត្ថេរនិមន្តមក ។


www.elibraryofcambodia.org

កាលពីសម័យដើម គេបានកសាងនូវជណ្ដើរដ៏ធំ ដើម្បីឡើងទៅលើកំពូលភ្នំ. ព្រះបាទទេវានម្បិយតិស្ស ព្រះអង្គបានកសាងវត្តមួយនិងគុហាចំនួន៦៨ សម្រាប់ភិក្ខុសង្ឃអាស្រ័យនៅនឹងភ្នំនេះ ។ ចាប់តាំងពីពេលនោះភ្នំនេះ ក៏បានក្លាយទៅជាអារាម និងមានភិក្ខុសង្ឃគង់នៅជាច្រើន ។



ព្រះធម៌មិនស្តាប់ច្បាប់មិនអាន
ចេះដឹងនឹងបានមកពីណា
ខ្លួនឯងមិនស្វែងរកគេខាសនា
សង្ស័យទេវតាណាគេជួយ។


www.elibraryofcambodia.org

## ធម្មទូតមកកាន់នគរកោះលង្កា

នៅក្នុងព.ស២៣៥ ព្រះអរហន្តមោគ្គល្លីបុត្តតិស្សត្ថេរ បានដឹកនាំប្រារព្ធធ្វើនូវតតិយសង្គាយនា ដើម្បីផ្ទៀងផ្ទាត់នូវព្រះពុទ្ធវចនៈ ដែលមានភិក្ខុជាព្រះអរហន្តចំនួន១០០០អង្គចូលរួម។ សង្គាយនានេះបានប្រព្រឹត្តទៅអស់រយៈពេល ៩ខែ ដែលបានប្រារព្ធធ្វើនៅក្នុងវត្តអសោការាមក្នុងដែនបត្តលីបុត្ត ដែលមានព្រះបាទធម្មាសោកជាសាសនូបត្ថម្ភក៍។ ក្រោយអំពីតតិយសង្គាយនា ព្រះអរហន្តមោគ្គល្លីបុត្តតិស្សត្ថេរ ព្រះអង្គដែលជាអ្នកយល់អំពីកាលដ៏គួរ- ព្រះអង្គក៏បានរៀបចំនូវធម្មទូតដើម្បីបញ្ជូនឱ្យចេញទៅផ្សព្វផ្សាយសាសនា ទៅកាន់ទីកន្លែងផ្សេងៗដូចជា:

-មជ្ឈន្តិកត្ថេរ និមន្តទៅកាន់ កស្មេរ និងគន្ធារៈ

-មហាទេវត្ថេរ និមន្តទៅកាន់ មហិស្សមណ្ឌលៈ

-រក្ខិតត្ថេរ និមន្តទៅកាន់ វណ្ណវាសី

-ធម្មរក្ខិតត្ថេរ និមន្តទៅកាន់ អបរន្តក និង យោនៈ

-មហាធម្មរក្ខិតត្ថេរ និមន្តទៅកាន់ មហារដ្ឋ

-មហារក្ខិតត្ថេរ និមន្តទៅកាន់ ដែនយោនៈ

-មជ្ឈិមត្ថេរ និមន្តទៅកាន់ ដែនហេមល័យ


www.elibraryofcambodia.org

-សោណត្ថេរ និង ឧត្តរត្ថេរ និមន្តទៅកាន់ ដែនសុវណ្ណភូមិ

-មហិន្ទត្ថេរ និងព្រះថេរៈ៤ព្រះអង្គទៀតគឺៈ ឥទ្ធិយ ឧទ្ធិយ សម្បល និង ភទ្ទសាលត្ថេរ និមន្តទៅកាន់នគរកោះលង្កា. និងមានសាមណេរមួយអង្គព្រះនាមសុមនសាមណេរ ជាព្រះអរហន្តដែលបានសម្រេចអភិញ្ញា៦ មានឫទ្ធិបារមីដ៏អស្ចារ្យ ព្រមទាំងឧបាសកមួយរូបជាព្រះអនាគាមិបុគ្គល នាមភណ្ឌុកៈឧបាសក។

ព្រះមហិន្ទត្ថេរ លោកបានពិចារណារំពឹងមើលឃើញថា ពុំទាន់ដល់កាលគួរសម្រាប់ព្រះអង្គដើម្បីនិមន្តទៅកាន់នគរកោះលង្កានោះនៅឡើយទេ ព្រោះថាព្រះមហាក្សត្រដែលសោយរាជនៅក្នុងនគរលង្កា គឺព្រះបាទមុទ្ទសីវ ទ្រង់កំពុងតែមានអាពាធជាទម្ងន់ ព្រះអង្គនឹងមិនអាចជួយជ្រោមជ្រែង ដើម្បីផ្សព្វផ្សាយសាសនានេះបានឡើយ។ ដូច្នេះហើយព្រះអង្គត្រូវរង់ចាំដល់ព្រះរាជបុត្រនាមទេវានម្បិយតិស្ស ឡើងគ្រងរាជ្យសិនទើបជាការគួរ ហើយក៏មិនយឺតយូរណាស់ណានោះដែរ។

អាស្រ័យហេតុដូច្នោះហើយ ទើបកាលដែលព្រះមហិន្ទត្ថេរ ដែលជាប្រមុខនៃសង្ឃទូតចេញអំពីអសោការាមនោះហើយ ព្រះអង្គមិនបាននិមន្តទៅកាន់នគរកោះលង្កាតែម្តងទេ តែព្រះអង្គបាននិមន្តទៅដែន

www.elibraryofcambodia.org

វេទិស្សនគរ ដែលជាស្រុកកំណើតរបស់ព្រះមាតារបស់ព្រះអង្គនោះទៅវិញ។ នៅទីនោះព្រះមហិន្ទត្ថេរ បានសម្តែងព្រះធម៌ទេសនាប្រោសប្រទានដល់ព្រះមាតា និងពុទ្ធបរិស័ទ ព្រះអង្គបានទទួលវិហារនៅទីនោះអស់រយៈពេល៧ខែ គឺរហូតដល់ថ្ងៃ១៥កើត ខែ ជេស្ឋ នៅមុនចូលវស្សាមួយខែ ទើបលោកនិមន្តចេញអំពីវេទិស្សបពិតដោយឫទ្ធិឆ្ពោះទៅប្រាកដនៅលើភ្នំមិស្សកបពិត (ភ្នំមហិន្តលេ) ដែលនៅខាងកើតក្រុងអនុរាធបុរី។

---

**ពោត្ថកេសុ ច យំ សិប្បំ បរហត្ថេសុ យំ ធនំ**

**យថា កិច្ចេ សមុប្បន្នេ ន តំ សិប្បំ ន តំ ធនំ។**

**វិជ្ជាផ្សេងៗ ដែលនៅតែក្នុងគម្ពីរ ទ្រព្យដែលនៅតែក្នុងដៃអ្នកដទៃ កាលបើមានកិច្ចចាំបាច់កើតឡើង វិជ្ជានោះៗ ក៏មិនបានដឹងដល់យើង ទ្រព្យនោះៗ ក៏ប្រើប្រាស់ជារបស់យើងមិនបាន។**

www.elibraryofcambodia.org

# មន្ទីរពេទ្យ

កាលពីសម័យដើម នៅជំរាលភ្នំមហិន្ទលេ គេបានកសាងមន្ទីរពេទ្យសំរាប់ព្យាបាលព្រះសង្ឃមួយ ក៏ប៉ុន្តែបច្ចុប្បន្ននេះមន្ទីរពេទ្យនោះត្រូវបានខូចខាតអស់ទៅហើយ ។ ក្រុមអ្នកបុរាណវិទូ បានជីករកឃើញទូកថ្មសម្រាប់ត្រាំថ្នាំ និងផ្ទាំងសិលាចារិក ដែលបានសរសេររឿងរ៉ាវកាលពីសម័យនោះ ហើយការជីករកនេះ គេបានរកឃើញនៅចន្លោះមន្ទីរពេទ្យ និងជណ្តើរឡើង ។ ជ្រុងនីមួយៗនៃមន្ទីរពេទ្យនេះមានប្រវែង១២៥ហ្វីត( ៣៨.១ម៉ែត្រ) មានបង្កាន់ដៃ និងរូបសំណាក់ធ្វើអំពីថ្មយ៉ាងស្រស់ស្អាត នៅសងខាងផ្លូវចូលនៃមន្ទីរពេទ្យ ។ នៅតាមផ្លូវឡើងភ្នំខាងទិសបូព៌មកកាន់មន្ទីរពេទ្យនេះ មានចំណោតចោតយ៉ាងខ្លាំង. នៅទីនោះមានបន្ទប់ដ៏ធំបួន សំរាប់ទទួលពិនិត្យជំងឺ ។ ជណ្តើរឡើងទៅលើកំពូលភ្នំមាន១៨៤០កាំ ដែលធ្វើអំពីថ្ម នៅទីបញ្ចប់នៃជណ្តើរជាន់ទីមួយ មានទីធ្លាវាលរាបមួយនៅខាងស្តាំដៃ ទីនោះមានកូនភ្នំតូចមួយនៅលើកំពូលភ្នំគេបានកសាង ព្រះចេតិយមួយឈ្មោះកណ្តកចេតិយ ។

www.elibraryofcambodia.org

# សាលាឆាន់

សាលាឆាន់នេះ ឋិតនៅលើទីធ្លានៃជម្រាលភ្នំ ខាងឆ្វេងដៃជាន់ទីបីនៃជណ្តើរឡើង។ សាលានេះមានបណ្តោយ ៦២ ហ្វីត ( ១៨.៨៩៧៦ ម៉ែត្រ) ទទឹង ២៥ហ្វីត (៧.៦២ម៉ែត្រ)។ នៅទីនេះគេបានរកឃើញលូនិងទដាក់ទឹក ដែលធ្វើអំពីថ្មសម្រាប់ប្រើប្រាស់នៅទីនេះ និងជុំវិញនៃសាលាឆាន់ មានតម្កល់សំភារៈផ្ទះបាយផ្សេងៗជាច្រើន។ នៅខាងក្នុងសាលាឆាន់សព្វថ្ងៃនេះនៅសល់ស្នូករវែង ដែលធ្វើអំពីថ្មសម្រាប់ដាក់បាយ១ និងស្នូកខ្លីសម្រាប់ដាក់សម្ល។ នៅច្រកចូលនៃសាលាឆាន់នេះ មានសិលាចារិកធំពីរផ្ទាំង ដែលសរសេរអំពីច្បាប់វិន័យ សម្រាប់អ្នកចូលមកអាស្រ័យនៅក្នុងទីអារាម ហើយសិលាចារិកនេះធ្វើអំពីថ្មកានិត (ថ្មដែលមានពណ៌ប្រផេះ) ដែលមានឈ្មោះថាៈ សិលាចារិកមហិន្ទលេ ដែលបានកសាងដោយព្រះបាទមហិណ្ឌុ (៩៥៦-៩៧៦ ក្រោយ ព.ស)។

ចំណែកឯទីធ្លារាបស្មើនៅក្បែរនេះ គឺជាសាលាសម្រាប់ជួបជុំព្រះសង្ឃ និងជាសាលាធម្មសភា សម្រាប់ព្រះសង្ឃពិគ្រោះគ្នានូវព្រះធម៌ និង វិន័យ។ សាលានេះមានផ្ទៃ៦២ហ្វីត (១៨.៨៩៧៦ ម៉ែត្រ ក្រឡា)


www.elibraryofcambodia.org

ដែលបានកសាងអំពីសសរថ្មមានចំនួន ៤៨ដើម និងនៅចំកណ្តាលនៃសាលាធម្មសភា គេបានកសាងនូវវេទិកាមួយដែលមានច្រកចូលបួន ។







www.elibraryofcambodia.org

# អម្បថលៈចេតិយ

អម្បថលៈចេតិយ ស្ថិតនៅលើទីធ្លារាបស្មើនៃកំពូលភ្នំមហិន្ទលេ កាលពីសម័យដើម ព្រះចេតិយនេះ គេក៏បានកសាងនូវអគារសម្រាប់គ្របមិនឱ្យត្រូវភ្លៀង បច្ចុប្បន្ននេះអគារនោះត្រូវបានខូចខាតអស់ទៅហើយ នៅសល់តែសសរជុំវិញនៃព្រះចេតិយ ។ ព្រះចេតិយនេះកសាងឡើងដោយព្រះបាទមកឡនតិស្ស ។ ព្រះអង្គបានកសាងព្រះចេតិយនេះនៅត្រង់កន្លែងដែលព្រះបាទទេវានម្បិយតិស្ស និងព្រះអរហន្តមហិន្ទត្ថេរ ជួបគ្នាដំបូង ហើយទីកន្លែងនេះក៏ជាទីកន្លែងបូជាព្រះសពរបស់ព្រះមហិន្ទត្ថេរផងដែរ ។ ដូច្នេះហើយព្រះចេតិយនេះកសាងឡើងសម្រាប់បញ្ចុះព្រះធាតុរបស់ព្រះមហិន្ទត្ថេរ និងជាទីសំគាល់នូវកន្លែងដែលព្រះបាទទេវានម្បិយតិស្ស និងព្រះអរហន្តមហិន្ទត្ថេរ ជួបគ្នាដំបូងផងដែរ ។




www.elibraryofcambodia.org

# គុហាព្រះមហិន្ទត្ថេរ

នៅក្បែរអម្បថលៈចេតិយ មានផ្លូវតូចមួយចុះទៅតាមជម្រាលភ្នំ ដើម្បីឆ្ពោះទៅកាន់ទីកន្លែង ដែលព្រះមហិន្ទត្ថេរអាស្រ័យនៅនឹងរូងភ្នំ ។ ទីនោះគេបានឱ្យឈ្មោះថា គុហាព្រះមហិន្ទត្ថេរ ។ ពុទ្ធសាសនិកអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់ បានចាត់ទុកគុហានេះថា ជាទីកន្លែងដ៏ពិសិដ្ឋសម្រាប់ធ្វើសក្ការបូជា ។



គុហាព្រះមហិន្ទត្ថេរ



www.elibraryofcambodia.org

# មហាសាយចេតិយ

ព្រះចេតិយដ៏ធំ ដែលបានកសាងនៅលើកំពូលភ្នំមហិន្ទលេនេះ ឈ្មោះមហាសាយចេតិយ ។ ព្រះចេតិយនេះបានកសាងឡើងដោយព្រះបាទមហាដាធិកៈមហានាគ (៧-១៩ ក្រោយ ព.ស) ដែលមានកម្ពស់១៣៦ ហ្វីត (៤១.៤៥២៨ ម៉ែត្រ) ។ តាមជំនឿរបស់ប្រជាជនស្រីលង្កាថា ព្រះមហាចេតិយនេះមានបញ្ចុះព្រះធាតុថ្ងាសរបស់ព្រះសម្មាសម្ពុទ្ធ ។



មហាសាយចេតិយ



www.elibraryofcambodia.org

# អារាធនាកាលៈ

អារាធនាកាលៈ គឺជាកន្លែងដែលសុមនសាមណេរឡើងទៅអារាធនាពពួកទេវតា ដើម្បីមកស្តាប់នូវព្រះធម៌។ អារាធនាកាលៈនេះតាំងនៅលើកំពូលភ្នំមហិន្ទលេ ទល់មុខនឹងមហាសាយចេតិយ។ នៅរាត្រីថ្ងៃពេញបូណ៌មី ១៥កើត ខែ ជេស្ឋ នៃ ព.ស ២៣៦ ព្រះមហិន្ទត្ថេរ បានឱ្យសុមនសាមណេរចេញទៅប្រកាសពេលវេលាដើម្បីអញ្ជើញពពួកទេវតាទូទាំងនគរកោះលង្កាទាំងមូល ដើម្បីមកស្តាប់នូវព្រះធម៌។ សុមនសាមណេរ កាលណោះបាននិមន្តឡើងទៅគង់លើកំពូលភ្នំយ៉ាងខ្ពស់ ហើយសូត្រប្រកាសអញ្ជើញពពួកទេវតាដោយបទថាៈ

**សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ**
**ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ**
**ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វ នាគា**
**តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ**

www.elibraryofcambodia.org

នសេចក្តីថា: ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភុម្មទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ឰដ៏អាកាសក្តី នៅនាកោះនិង ដែននិងស្រុកក្តី នៅនាដើមព្រឹក្សា និងព្រៃញាតស្បាត ឬទីស្រែចំការក្តី យក្សនិង គន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹកទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីនេះក្តី សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ពាក្យឯណាដែលជាពាក្យរបស់ព្រះសក្យមុនីដ៏ប្រសើរ ដែលយើងខ្ញុំនឹងសូត្រឥឡូវនេះ លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះអំពីសំណាក់នៃខ្ញុំដោយគោរព ។

- **ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់នូវព្រះធម៌ ។
- **ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់នូវព្រះធម៌ ។
- **ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់នូវព្រះធម៌ ។

www.elibraryofcambodia.org

សម្លេងដែលសុមនសាមណេរ បានសូត្រនេះ បានបង្កើតឱ្យមានភាពផ្អើលកក្រើកពាសពេញនគរកោះលង្កា សូម្បីតែព្រះរាជាដែលទ្រង់គង់នៅក្រុងអនុរាធបុរីឯណោះ ក៏ព្រះអង្គភ្ញាក់ផ្អើល ហើយដោយព្រះទ័យព្រួយបារម្ភ ក្រែងមានហេតុការណ៍អាក្រក់កើតឡើងចំពោះព្រះថេរៈ ទើបទ្រង់បញ្ជាឱ្យអាមាត្យមកសាកសួរពីហេតុការណ៍ចំពោះព្រះថេរៈ។ ពេលនោះ ព្រះថេរៈបានប្រាប់ទៅអាមាត្យនូវដំណើររឿងដែលសុមន-សាមណេរ បានសូត្រប្រកាសអញ្ជើញពពួកទេវតា ដើម្បីមកស្តាប់នូវព្រះធម៌។ ពេលដែលនាយអាមាត្រនោះត្រឡប់ទៅទូលថ្វាយព្រះរាជាវិញ ទើបព្រះអង្គទ្រង់ស្បើយព្រះចិន្តា ហើយមានព្រះទ័យជ្រះថ្លាចំពោះព្រះថេរៈយ៉ាងក្រៃពេក។ នៅរាត្រីនោះព្រះថេរៈបានសម្តែងអំពីសមចិត្តសូត្រ លុះចប់ព្រះធម៌ទេសនា មានទេវតាជាច្រើនបានសម្រេចនូវធម៌ជាន់ខ្ពស់។

លុះព្រឹកស្អែកឡើង ព្រះរាជាក៏បានបង្គាប់ឱ្យព្រះនាងអនុឡាទេវីព្រមដោយស្នំដែលជាបរិវារ រៀបចំចាត់ចែងនូវចង្ហាន់បិណ្ឌបាត រួចហើយទ្រង់ក៏បានឱ្យអាមាត្រយករាជរថរបស់ព្រះអង្គ មកទទួលព្រះថេរៈ ដើម្បីចូលរាជដំណាក់ក្នុងព្រះរាជវាំង។ ព្រះថេរៈនៅពេលដែលបានទ្រង់ទត

www.elibraryofcambodia.org

ឃើញនូវរាជរថនោះមកដល់ហើយ រាជអាមាត្របាននិមន្តព្រះអង្គឱ្យឡើងលើរាជរថ ពេលនោះព្រះថេរៈបានប្រកែកមិនព្រមនិមន្តឡើងជិះលើរាជរថនោះទេ តែព្រះអង្គបានឱ្យរាជអាមាត្រត្រឡប់ទៅវិញមុន។ នៅពេលដែលរាជអាមាត្រចេញផុតអំពីព្រះអង្គបន្តិច ពេលនោះព្រះថេរៈបាននិមន្តចាកចេញអំពីមិស្សកបពិតនេះ ហើយបានមកដល់ត្រង់ទ្វារក្រុងខាងកើតមុនពេលដែលរាជរថរបស់អាមាត្រ ដែលបានបរទៅទទួលព្រះអង្គនោះទៅទៀត។ ទីកន្លែងដែលព្រះមហិន្ទត្ថេរ លោកនិមន្តមកដល់ច្រកទ្វារខាងកើតក្រុងនេះ ក្រោយមកព្រះរាជាក៏បានកសាងព្រះចេតិយមួយ ហើយឱ្យឈ្មោះបឋមចេតិយ នៅត្រង់ទីកន្លែងដែលព្រះមហិន្ទត្ថេរលោកទ្រង់ឈរ។

ក្រោយអំពីទទួលភត្តកិច្ចហើយ ព្រះមហិន្ទត្ថេរ ព្រះអង្គបានសម្តែងព្រះធម៌ទេសនាអំពីវិមានវត្ថុ និងបេតវត្ថុ ព្រមទាំងសច្ចសំយុត្តញ៉ាំងឱ្យព្រះនាងអនុឡាទេវី មួយអន្លើដោយបរិវារទាំង ៥០០ នាក់បានសម្រេចនូវសោតាគ្រប់ៗគ្នា។ នៅថ្ងៃនោះផងដែរ ដោយមានអ្នកស្រុកបានមកបន្តបន្ទាប់ច្រើនពេក ទើបព្រះរាជាចាត់ឱ្យគេរៀបចំទីលានរោងដំរីយ៉ាងស្អាត ទើបនិមន្តព្រះថេរៈទៅកាន់ទីនោះ ដើម្បីសម្តែង

www.elibraryofcambodia.org

ព្រះធម៌ទេសនា ពេលនោះព្រះថេរៈ បានសម្តែងអំពីទេវទូតសូត្រ។ លុះចប់ព្រះធម៌ទេសនា មហាជនប្រមាណ ១០០០នាក់ បានសម្រេចមគ្គផលទៅតាមឧបនិស្ស័យរបស់ពួកគេរៀង១ខ្លួន។ បន្ទាប់មក នៅថ្ងៃទីពីរ ព្រះមហិន្ទត្ថេរបានសម្តែងអំពីអសីវិសូបមសូត្រ នៅក្នុងនន្ទឧទ្យាន ហើយបានញ៉ាំងឱ្យមហាជន ២៥០០នាក់ បានសម្រេចនូវមគ្គផល និងបានដល់នូវត្រៃសរណគមន៍គ្រប់១គ្នា។

នៅរាត្រីថ្ងៃនោះ ព្រះមហិន្ទត្ថេរ និងភិក្ខុសាវ័កបានគង់សំរាកនៅក្នុងឧទ្យានមហាមេឃវ័ន។ លុះព្រឹកឡើងជាថ្ងៃទីបី ត្រូវនឹងថ្ងៃ២រោច ខែជេស្ឋ ព្រះរាជាបានវេរថ្វាយឧទ្យានមហាមេឃវ័ននេះថ្វាយដល់ព្រះថេរៈ ដើម្បីធ្វើជាអារាម សម្រាប់ព្រះអង្គ និង ព្រះសង្ឃគង់នៅ។ នៅពេលដែលច្រួចទឹកដាក់ព្រះហស្តព្រះថេរៈ ក្នុងការវេរថ្វាយឧទ្យានមហាមេឃវ័ននេះ ស្រាប់តែផ្ទៃកោះលង្កាទាំងមូល បានរញ្ជួយញ័រឡើងរហូតធ្វើឱ្យព្រះរាជា និងមនុស្សទាំងឡាយមានការផ្អើលឆោឡោ ទើបព្រះរាជាទ្រង់ត្រាស់សួរព្រះថេរៈ។ បានថ្វាយព្រះពរថា បពិត្រមហារាជ! ទីនេះនឹងកើតជាមហាវិហារ ហើយព្រះពុទ្ធសាសនា នឹងតាំងនៅមាំក្នុងកោះលង្កានេះឯង។ ថ្ងៃបន្តមកទៀត ព្រះថេរៈបានសម្តែងអំពីអនមតគ្គ


www.elibraryofcambodia.org

តគ្គសូត្រ និងអគ្គិក្ខន្ធោបមសូត្រ នៅទីបំផុតព្រះថេរៈបានសម្ដែងអំពីអប្បមាទសូត្រ ថ្វាយព្រះរាជា ។



កន្លែង អារាធនាកាលៈ

**នត្ថិ បញ្ញា សមា អាភា**

**ពន្លឺអ្វី ស្មើដោយបញ្ញា មិនមានឡើយ**



www.elibraryofcambodia.org

# វស្សាទី១ នៃព្រះមហិន្ទត្ថេរនៅក្នុងកោះលង្កា

ព្រះមហិន្ទត្ថេរ មួយអន្លើដោយព្រះថេរៈជាធម្មទូត ដែលបាននិមន្ត មកអំពីនគរបត្តលិបុត្ត ព្រះអង្គបានគង់ចាំព្រះវស្សានៅក្នុងវត្ត មិស្សកបពិត មហាវិហារ។ មុនថ្ងៃចូលចាំព្រះវស្សា មានមហាមាត្យម្នាក់ឈ្មោះអរិដ្ឋ ដែលជាមិត្តសម្លាញ់ ជាទីគាប់ព្រះទ័យរបស់ព្រះរាជា បានសុំចូលសាង ព្រះផ្នួសបួសជាសង្ឃជាមួយ និងញាតិមិត្តរបស់ខ្លួនចំនួន ៥៥នាក់។ ក្រោយពីបានបួសហើយ ព្រះអង្គបានគង់ចាំព្រះវស្សាជាមួយនឹងព្រះ មហិន្ទត្ថេរ ព្រមទាំងព្រះថេរៈជាធម្មទូត ដើម្បីប្រតិបត្តិធម៌រហូតបាន សម្រេចជាព្រះអរហន្តទាំងអស់អង្គនៅក្នុងវស្សាទីមួយនោះឯង។

លុះដល់រដូវចេញព្រះវស្សា ព្រះមហិន្ទត្ថេរបានសម្ដែងនូវទឹក ព្រះទ័យដាក់ព្រះរាជា ធ្វើហាក់ដូចជាចង់ចម្រើនពរលាត្រឡប់ទៅនគរ បត្តលិបុត្តវិញ។ ក្រោយអំពីព្រះរាជាទ្រង់បានជ្រាបនូវរឿងនេះ ព្រះអង្គ មានព្រះទ័យខ្វល់ខ្វាយយ៉ាងខ្លាំង ហើយទ្រង់ពោលទៅកាន់ព្រះថេរៈថា ខ្ញុំព្រះករុណាបានទំនុកបំរុងព្រះអង្គ ដោយចតុប្បច្ច័យគ្រប់បែបយ៉ាង ហើយនឹងវេរថ្វាយឧទ្យានមហាមេឃវ័នដល់ព្រះអង្គទៀត។ នេះគឺជា បំណងរបស់ខ្ញុំព្រះករុណា ដែលប្រាថ្នាចង់សុំអារាធនាព្រះអង្គឱ្យគង់នៅ


www.elibraryofcambodia.org

ទីនេះ ដើម្បីនឹងបានអនុគ្រោះដល់ខ្ញុំព្រះករុណា ព្រមទាំងប្រជានុរាស្ត្រនៅក្នុងកោះលង្កានេះតរៀងទៅ។ ចុះហេតុដូចម្ដេចបានជាឥឡូវនេះលោកម្ចាស់ចង់និមន្តទៅកាន់នគរបត្តលិបុត្តវិញដូច្នេះ? ព្រះថេរៈតបទៅព្រះរាជាវិញថា អាត្មាភាពខានបានចូលគាល់ព្រះសម្មាសម្ពុទ្ធជាយូរមកហើយ ឥឡូវនេះអាត្មា ឥតបានចូលគាល់ព្រះអង្គទៀត ដូច្នេះអាត្មាចង់ទៅធ្វើសក្ការ គោរពបូជាចំពោះព្រះអង្គផ្ទាល់នៅពេលនេះ។ ព្រះរាជាត្រាស់តបថា: ចុះក្រែងលោកម្ចាស់បានប្រាប់ខ្ញុំព្រះករុណាថា ព្រះសម្មា-សម្ពុទ្ធព្រះអង្គទ្រង់បរិនិព្វានហើយមែនទេ? ព្រះថេរៈមានថេរដីកាតបវិញថា មែនហើយ. ក៏ប៉ុន្តែអាត្មាភាពមានការនឿយណាយ និងធុញទ្រាន់នឹងនៅទីនេះណាស់ ព្រោះថាទីនេះពុំមានឱកាសសម្រាប់អាត្មាធ្វើសក្ការគោរពបូជាចំពោះព្រះអង្គនោះឡើយ។ ចំណែកនៅឯជម្ពូទ្វីបឯណោះវិញ មានព្រះបរមសរីរិកធាតុសម្រាប់អាត្មាភាពធ្វើសក្ការគោរពបូជាបានគ្រប់ពេលគ្រប់វេលា។

ព្រះរាជាព្រះអង្គទ្រង់ឈ្វេងយល់ដល់អធ្យាស្រ័យរបស់ព្រះថេរៈទើបទ្រង់មានព្រះបន្ទូលថា សូមឱ្យតែលោកម្ចាស់ទ្រង់គង់នៅទីនេះដើម្បីអនុគ្រោះដល់ប្រជានុរាស្ត្រនៅក្នុងដែនលង្កាទ្វីបនេះចុះ ខ្ញុំព្រះករុណានឹង


www.elibraryofcambodia.org

ទទួលរាប់រង និងចាត់ចែងនូវអ្វីៗទាំងអស់សម្រាប់ព្រះពុទ្ធសាសនា ព្រមទាំងការកសាងនូវព្រះស្តូប តែខ្ញុំព្រះអង្គពុំដឹងថា តើនឹងបាន ព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធអំពីទីណានុ៎ះទេ។ ពេលនោះ ព្រះមហិន្ទត្ថេរ ក៏បានមានដីកាតបវិញថា ចំពោះរឿងហ្នឹង សូមមហារាជ យាងទៅពិគ្រោះជាមួយនឹងសុមនសាមណេរចុះ។ សុមនសាមណេរ នៅ ពេលដែលព្រះមហាក្សត្រ ព្រះអង្គយាងទៅពិគ្រោះសាកសួរអំពីបញ្ហារក ព្រះសរីរិកធាតុ ពេលនោះលោកក៏បានថ្វាយព្រះពរថា អាត្មាភាពធានា រ៉ាប់រងទៅអារធនានិមន្តព្រះសារីរិកធាតុ ទោះនៅទីកន្លែងណាក៏ដោយ ឱ្យតែព្រះឧបជ្ឈាយ៍របស់អាត្មាចាត់ឱ្យអាត្មាទៅ អាត្មាឥតមានប្រកែក នោះឡើយ។ បន្ទាប់អំពីនោះមក ព្រះរាជាក៏បានចាត់ចែងឱ្យគេកសាង ព្រះស្តូប ចំណែកឯសុមនសាមណេរ ព្រះអង្គក៏បាននិមន្តទៅកាន់ដែន ជម្ពូទ្វីប ដើម្បីទៅអារធនាព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធ អំពីព្រះបាទ ធម្មាសោក ដែលជាជីតា ដែលព្រះអង្គបានរៀបចំទុកដាក់នៅក្នុងបាត្រ ដើម្បីនាំមកប្រគេនថ្វាយដល់ព្រះឧបជ្ឈាយ៍។ បន្ទាប់មក សុមនសាមណេរ ក៏បាននិមន្តដោយឫទ្ធិទៅកាន់ឋានតាវត្តិង្ស ដើម្បីសុំព្រះអក្ខកធាតុ (ឆ្អឹង ដងកាំបិត) អំពីព្រះឥន្ទ្រាធិរាជ ។ នៅពេលដែលសុមនសាមណេរ


www.elibraryofcambodia.org

ទៅដល់ឋានទេវលោកហើយនោះ ព្រះអង្គបានពោលទៅកាន់សក្កទេវរាជថា អូ! មហាបពិត្រ ព្រះអង្គឱ្យពួកអាត្មាទៅផ្សព្វផ្សាយព្រះធម៌នៅក្នុងនគរកោះលង្កា ហើយមហារាជលែងពួកអាត្មាចោលអញ្ចឹងឬ? ព្រះឥន្ទ្រាធិរាជតបថា: លោកម្ចាស់សុមនៈ! មិនពិតទេលោកម្ចាស់ តើពេលនេះលោកម្ចាស់ចង់បានអ្វី ឬក៏លោកម្ចាស់ចង់ឱ្យខ្ញុំព្រះករុណាជួយយ៉ាងណា សូមលោកម្ចាស់មានដីកាមកចុះ។ ពេលនោះ សុមនសាមណេរពោលតបថា: សូមមហាបពិត្រ! បូជាឱ្យទូលបង្គំនូវអក្ខកធាតុ (ឆ្អឹងដង់កាំបិតខាងស្តាំ) ឱ្យមកទូលបង្គំ ដើម្បីទូលបង្គំ និងប្រជាជននៅក្នុងនគរកោះលង្កា បានធ្វើសក្ការគោរពបូជាផង។ ពេលនោះព្រះឥន្ទ្រាធិរាជ ព្រះអង្គឥតបានប្រកែកអ្វីបន្តិចជាមួយនិង សុមនសាមណេរនោះឡើយ។ ព្រះអង្គបានទៅបើកនូវចុឡាមុនីចេតិយនាឋានទេវលោក ហើយនាំយកព្រះអក្ខកធាតុមកប្រគេនដល់សុមនសាមណេរនាពេលនោះផងដែរ។ សុមនសាមណេរ បាននាំព្រះអក្ខកធាតុមកថ្វាយព្រះមហិន្ទត្ថេរ ដែលជាព្រះឧបជ្ឈាយ៍ គឺនៅថ្ងៃពេញបូណ៌មី ១៥កើត ខែកត្តិក ព.ស ២៣៦ ពេលដែលព្រះអង្គកំពុងគង់រង់ចាំនៅក្នុងសួនមហាមេឃវ័ន។


www.elibraryofcambodia.org

ព្រះរាជាបានរៀបចំទទួលព្រះធាតុតាមកម្មវិធី ដែលបានពិគ្រោះជាមួយនិងសុមនសាមណេរពីមុន។ ព្រះអង្គស្តេចគង់លើដំរីមង្គលដែលប្រដាប់ដោយស្វេតច្ឆ័ត្រ រួចឆ្ពោះទៅកាន់សួនមហាមេឃវ័ន ដែលព្រះមហិន្ទត្ថេរព្រះអង្គកំពុងតែកាន់ទ្រព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធនៅទីនោះ។ ព្រះរាជាព្រះអង្គទ្រង់បានព្រះតំរិះថាៈ បើសិនជាព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធពិតប្រាកដមែននោះ សូមឱ្យដំរីមង្គលរបស់យើងនេះលុតជង្គង់នៅទីចំពោះមុខព្រះធាតុកុំខាន់ឡើយ។ ដូចទ្រង់ព្រះតំរិះមែននៅពេលដែលព្រះអង្គយាងទៅដល់ ពេលនោះដំរីមង្គលរបស់ព្រះអង្គក៏បានលុតជង្គង់ ហាក់បង្អោនចិត្តឆ្ពោះទៅរកព្រះធាតុ។ ព្រះរាជាទ្រង់ទតឃើញដូច្នោះ ព្រះអង្គក៏យាងចុះអំពីលើខ្នងដំរី។ ពេលនោះព្រះថេរៈក៏បានយកព្រះសារីរិកធាតុនៅក្នុងព្រះហស្តរបស់ព្រះអង្គទៅដាក់លើក្បាលដំរី ពេលនោះដំរីមានចិត្តត្រេកអរ ហើយក៏ស្រែកបន្លឺនូវសម្លេងឡើងគួរឱ្យរំភើបក្រៃលែង។ ដំរីទូលព្រះធាតុតែម្នាក់ឯង ហាក់ដូចជាមានចិត្តសប្បាយរីករាយណាស់ ដើរគេចចុះគេចឡើង ហាក់ដូចមិនចង់ឱ្យឃ្លាតទៅណានោះឡើយ។ ចំណែកឯព្រះរាជាវិញ ព្រះអង្គក៏មានព្រះទ័យអន្ទះសារ ទ្រង់យាងចុះយាងឡើង ដោយបំណងចង់ទូលព្រះ


www.elibraryofcambodia.org

សារីរិកធាតុនោះដែរ ។ ទើបព្រះថេរៈទូលថ្វាយព្រះរាជាថា មិនទាន់ដល់កាលវេលាដ៏សមគួរសម្រាប់ព្រះអង្គនៅឡើយទេ ។

ពេលនោះព្រះធាតុ បានសម្តែងបាដិហារ្យហោះអណ្តែតឡើងទៅលើអាកាស ដែលមានកំពស់ប្រមាណជា៧ដើមត្នោតលៃ ហើយបញ្ចេញពន្លឺរស្មី៦ពណ៌ រួចក៏ធ្លាក់ចុះសន្សឹមៗមកប្រថាប់លើសិសៈរបស់ព្រះរាជា ទើបទ្រង់នាំយកទៅបញ្ចុះនៅក្នុងបឋមចេតិយ ( ថូបារាម ) ។ បាដិហារ្យដែលព្រះធាតុបានសម្តែងនេះគឺពុំមែនព្រះអរហន្តអង្គណា ឬក៏ទេវតាឥន្ទព្រហ្មណានិមិត្តនោះទេ នេះគឺជាបាដិហារ្យដែលសម្តែងឡើងដោយព្រះធាតុនេះផ្ទាល់តែម្តង ព្រោះថាកាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់គង់ធរមាននៅឡើយ ព្រះអង្គទ្រង់បានអធិដ្ឋានទុកជានិមិត្តមកយ៉ាងនេះឯង ។

កាលគ្រានោះ មហាជនមីរដេរដាស បានឃើញនូវហេតុដ៏អស្ចារ្យនេះក៏បាននាំគ្នាផ្សព្វផ្សាយចេញទៅល្បីរន្ទឺពាសពេញទាំងនគរកោះលង្កា មានអ្នកស្រុកជាច្រើនទាំងប្រុសទាំងស្រី ដោយសេចក្តីជ្រះថ្លា ក៏បានចូលមកសុំសាងព្រះផ្នួសជារៀងរាល់ថ្ងៃ រហូតដល់ព្រះនាងអនុឡាទេវី ព្រមទាំងស្ត្រីបំរើទាំង ៥០០នាក់ ក៏បានសុំព្រះរាជានុញ្ញាត ដើម្បីចូលសាង


www.elibraryofcambodia.org

ព្រះផ្នួសផងដែរ ។ ប៉ុន្តែពេលនោះ ព្រះមហិន្ទត្ថេរ ព្រះអង្គមិនអាចបំបួសបានទេ ព្រោះថានៅក្នុងនគរកោះលង្កានេះពុំមានភិក្ខុនីសង្ឃ ។ តាមព្រះវិន័យ ភិក្ខុសង្ឃតែម្ខាងពុំអាចបំបួសភិក្ខុនីបានទេ លុះត្រាតែប្រកបដោយឧភតោសង្ឃ គឺដំបូងបំបួសដោយភិក្ខុនីសង្ឃ រួចចូលមកកាន់ឧបសម្បទាជាមួយនិងភិក្ខុសង្ឃម្តងទៀតទើបបាន ។

អាស្រ័យដូចនេះហើយ ទើបព្រះរាជាចាត់ចែងធ្វើព្រះរាជសារទៅថ្វាយព្រះបាទធម្មាសោក នៅឯជម្ពូទ្វីបដើម្បីសុំនិមន្តព្រះនាងសង្ឃមិត្តាថេរី ដើម្បីបានបំបួសឱ្យបានជាភិក្ខុនី នៅក្នុងនគរកោះលង្កានេះផង ។ ចំណេរកាលជាខាងក្រោយមក ព្រះនាងសង្ឃមិត្តាថេរី បាននិមន្តមកកាន់នគរកោះលង្កានេះមួយអន្លើដោយភិក្ខុនីសង្ឃជាច្រើន ហើយព្រះនាងបាននាំមកនូវមែកមហាពោធិព្រឹក្សអំពីទីកន្លែងដែលព្រះសម្មាសម្ពុទ្ធព្រះអង្គត្រាស់ដឹងនោះមកជាមួយផងដែរ ។

www.elibraryofcambodia.org

# វត្តតម្បូលៈ

វត្តតម្បូលៈ ឋិតនៅក្នុងស្រុកមត្តលេ ដែលមានចម្ងាយប្រមាណ ១០ ម៉ៃ (១៦.០៩ គីឡូម៉ែត្រ)ពីភ្នំសិគិរី និងមានចម្ងាយប្រមាណ ២៩ម៉ៃ (៤៦.៦៦១ គីឡូម៉ែត្រ)ពីក្រុងខេនឌី។ ភ្នំតម្បូលៈ មានកំពស់១៧៥ ហ្វីត (៥៣.៣៤ ម៉ែត្រ)។ ភ្នំនេះមានប្រវត្តិរឿងរ៉ាវជាច្រើន ដែលបានកត់ត្រានៅក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ប្រទេសស្រីលង្កា។ នៅលើសិលាចារិកនៃគុហាបានសរសេរថា ព្រះបាទសទ្ធាតិស្សទ្រង់បានថ្វាយទីនេះធ្វើជាអារាមសម្រាប់ព្រះសង្ឃគង់នៅ។

នៅក្នុងសម័យព្រះបាទវដ្តគាមិនីអភ័យ ទីនេះគឺជាទីជម្រករបស់ព្រះអង្គគង់លាក់ព្រះកាយ នៅក្រោយពេលដែលព្រះអង្គបានចាញ់សង្គ្រាមជាមួយនិងពួកទមិឡ ។ ក្រោយពេលដែលព្រះអង្គបានធ្វើសង្គ្រាមបង្ក្រាបពួកចោរទមិឡហើយនោះ ព្រះបាទវដ្តគាមិនីអភ័យ បានកសាងទីនេះទៅជាវត្តដ៏ប្រណិតនៅក្នុងនគរកោះលង្កា សម្រាប់ព្រះភិក្ខុសង្ឃគង់នៅ។ យោងតាមសៀវភៅប្រវត្តិសាស្ត្រឈ្មោះចុល្លវង្សបានសរសេរថា ព្រះបាទវិជ័យពាហុ ដែលជាស្តេចគ្រងរាជ្យនៅក្នុងក្រុងឈ្មោះ បុឡុណ្ណារុវៈ បានកសាងវត្តតម្បូលៈសាជាថ្មីឡើងវិញ ។

www.elibraryofcambodia.org

នៅក្នុងសិលាចារិករបស់ព្រះបាទនិសង្កមាលៈ ព្រះអង្គបានកសាងវត្តនេះម្តងទៀត ហើយព្រះអង្គកសាងព្រះពុទ្ធរូបចំនួន ៧៣ព្រះអង្គ និងបានឱ្យឈ្មោះវត្តនេះថា រង្គីរីតម្បូលៈ។ នៅក្នុងអំឡុងឆ្នាំ ១៨១៧-១៨១៨ ការបះបោរមួយបានកើតឡើងនៅក្នុងនគរកោះលង្កានេះ ពេលនោះមន្ត្រីឈ្មោះបុរាណពូ និងគុង្គលេគោដបណ្ឌ បានយកទីកន្លែងនេះធ្វើជាកន្លែងលាក់ខ្លួនរបស់ពួកគេផងដែរ។

នៅខាងលើកំពូលភ្នំតម្បូលៈនេះ មានគុហាចំនួន៥ ដែលមានព្រះពុទ្ធរូបយ៉ាងច្រើន សម្រាប់ពុទ្ធបរិស័ទគ្រប់ទិសទីធ្វើសក្ការគោរពបូជា។ នៅពិដានខាងលើ គេបានរចនាធ្វើជារូបផ្សេងៗ នៅក្នុងរឿងនៃពុទ្ធប្រវត្តិ។ នៅក្នុងគុហាទាំង៥ មានគុហាមួយដែលតម្កល់នូវព្រះវិស្ណុរបស់សាសនាព្រាហ្មណ៍។ ចំណែកឯនៅក្នុងគុហាធំ មានហេតុដ៏អស្ចារ្យណាស់ ព្រោះថានៅចំកណ្តាលនៃគុហានោះ មានតំណក់ទឹកស្រក់គ្រប់រដូវមិនចេះរីងស្ងួត ទោះជានៅរដូវប្រាំងឬនៅក្នុងរដូវវស្សា។ នៅទីនោះគេបានដាក់បាត្រដ៏ធំមួយ សម្រាប់ត្រងទឹកទុកប្រើសម្រាប់ដាំមធុបាយាសនិងភេសជ្ជៈថ្វាយដល់ព្រះសម្មាសម្ពុទ្ធ ។


www.elibraryofcambodia.org

# ភ្នំសិគីរី

ភ្នំសិគីរី គឺជាឈ្មោះនៃព្រះបរមរាជវាំងរបស់ព្រះបាទកស្សបៈ ដែលបានកសាងនៅលើថ្មភ្នំមួយ នៅក្នុងសតវត្សរ៍ទី៥។ សព្វថ្ងៃបាន ក្លាយទៅជាអច្ឆរិយវត្ថុទី ៨ នៅលើពិភពលោក។ ទីនេះក៏បានរំលឹក យើងឱ្យចងចាំនូវប្រវត្តិសាស្ត្រនៃការលាក់ខ្លួនរបស់ស្តេចកស្សប កាលពី សម័យដើម។ ភ្នំសិគីរី ឋិតនៅក្នុងស្រុកមត្តលេ ក្នុងឃុំឈ្មោះឥណាមលុ វកុរល។ ភ្នំនេះមានចម្ងាយប្រមាណ ១០ម៉ៃ (១៦.០៩ គីឡូម៉ែត្រ)ពី ភ្នំតម្បូលៈ។

ភ្នំសិគីរីនេះមានរឿងនិទានថា នៅនគរកោះលង្កា ក្រោយរាជ ព្រះបាទមហានាម មានកើតសង្គ្រាមដណ្តើមរាជសម្បត្តិអំពីជនជាតិ អំបូរទមិឡដើម្បីសោយរាជ ហើយបានបំផ្លិចបំផ្លាញវត្តអារាម។ ពួក គេបានតាំងចិត្តប្រទូស្តរាយនឹងព្រះពុទ្ធសាសនា និងនាំឱ្យព្រះពុទ្ធសាសនា មានការធ្លាក់ចុះយ៉ាងខ្លាំង។ ពួកទមិឡបានឡើងគ្រងរាជ្យនៅក្នុងនគរ កោះលង្កានេះអស់រយៈពេល ២៤ឆ្នាំ។ កាលនោះមានសាមណេរមួយ រូប ឈ្មោះធាតុសេន កើតក្តីក្តៅក្រហាយនឹងសង្គ្រាម ក៏លាចាកសិក្ខាបទ អំពីព្រះផ្នួស ហើយបានមកបង្កើតកងទ័ពដើម្បីធ្វើសឹកសង្គ្រាមប្រឆាំងនិង


www.elibraryofcambodia.org

ពួកចោរទមិឡ រហូតបានទទួលជោគជ័យ។ នៅពេលដែលបានបញ្ចប់សង្គ្រាមហើយ ប្រជានុរាស្ត្រនៅក្នុងនគរកោះលង្កាទាំងមូល បានលើកមេទ័ពឈ្មោះធាតុសេន ឱ្យឡើងសោយរាជ។ ព្រះបាទធាតុសេនសោយរាជសម្បត្តិបាន ១៨ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១០០២-១០២០។

ក្នុងរាជព្រះបាទធាតុសេន មានរឿងតំណាលថា ព្រះរាជាអង្គនេះមានអគ្គមហេសីពីរ មហេសីទី១ មានព្រះរាជបុត្រមួយព្រះអង្គឈ្មោះមោគ្គល្លាន, ឯមហេសីទី២ ក៏មានព្រះរាជបុត្រមួយព្រះអង្គដែរ ឈ្មោះកស្សប។ ព្រះបាទធាតុសេនបានលើកព្រះរាជបុត្រីរបស់ព្រះអង្គ ដែលជាកូនស្រីសុំ ឱ្យធ្វើជាប្រពន្ធមេទ័ពដែលត្រូវជាក្មួយបង្កើត គឺថាម្ដាយបង្កើតនៃមេទ័ពនោះ ត្រូវជាប្អូនស្រីបង្កើតរបស់ព្រះបាទធាតុសេន។ ខាងក្រោយមក ព្រះរាជបុត្រីរបស់ព្រះបាទធាតុសេន ដែលជាភរិយានៃមេទ័ព បានកើតមានរឿងរ៉ាវឈ្លោះប្រកែកគ្នាជាមួយម្ដាយក្មេក។ ឯលោកមេទ័ពជាកូន ក៏បាននិយាយទូន្មានភរិយា តែនាងមិនស្ដាប់ ក៏បានវាយភរិយារហូតដល់បែកឈាម។ ភរិយានៃមេទ័ពនោះ ក៏បានមកទូលពិតរឿងរ៉ាវនោះដល់ព្រះបាទធាតុសេន។ ព្រះបាទធាតុសេនទ្រង់ក៏ពិរោធយ៉ាងខ្លាំង ហើយក៏មិនបានសួរនាំទៅមេទ័ពដែលជាកូន


www.elibraryofcambodia.org

ប្រសារឱ្យបានដឹងនូវរឿងនោះទេ ទ្រង់បែរជាព្រះតម្រិះថា ហេតុការណ៍នេះគឺបណ្តាលមកពីប្អូនស្រីរបស់ព្រះអង្គដែលជាម្តាយមេទ័ពនោះទៅវិញ។ ព្រះអង្គក៏បានបញ្ជាឱ្យគេចាប់ប្អូនស្រ្តីដែលត្រូវជាម្តាយមេទ័ពនោះទៅដុតទាំងរស់ ឥតត្រាប្រណីរហូតបាត់បង់ជីវិត។ មេទ័ពដែលជាកូនប្រសារមានការឈឺចិត្តយ៉ាងខ្លាំង ហើយក៏បានរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីប្រឆាំងតបតនឹងព្រះរាជាវិញ។ ពេលនោះមេទ័ពនោះក៏បានទៅទាក់ទង និងរួមគំនិតជាមួយនិងកស្សប ដែលជាព្រះរាជបុត្រនៃអគ្គមហេសីទី២ ហើយញុះញង់ឱ្យព្រះរាជកុមារអង្គនេះ រកវិធីដើម្បីស្នងរាជបន្តអំពីព្រះបិតារបស់ព្រះអង្គ បើមិនដូច្នោះទេ រាជសម្បត្តិនេះនឹងបានទៅមោគ្គល្លាន ដែលជាព្រះរាជបុត្រនៃអគ្គមហេសីទី១ នោះមិនខាន។ ការញុះញង់របស់មេទ័ពនេះ ធ្វើឱ្យព្រះកស្សបសព្វព្រះទ័យយ៉ាងខ្លាំង ទើបរិះរកវិធីដើម្បីបង្ខំព្រះបាទធាតុសេន ដែលជាបិតាឱ្យប្រគល់រាជសម្បត្តិដល់ខ្លួន។ ព្រះបាទធាតុសេន មិនព្រមប្រគល់រាជសម្បត្តិនេះឱ្យទៅកស្សប ទើបមានការឃាត់ខ្លួនព្រះអង្គ ហើយធ្វើទារុណកម្មរហូតដល់ចូលទិវង្គត។ ពេលនោះព្រះកស្សប ក៏បានឡើងសោយរាជជាស្តេច ក៏ប៉ុន្តែព្រះអង្គមិនបាននូវសេចក្តីសុខក្នុងរាជសម្បត្តិនោះទេ ព្រោះ


www.elibraryofcambodia.org

ថាប្រជានុរាស្ត្រធ្វើការបះបោរប្រឆាំងនឹងព្រះអង្គ ណាមួយព្រះអង្គព្រួយបារម្ភអំពីមោគ្គល្លាន ដែលជាបងដែលបានគេចខ្លួនអំពីនគរកោះលង្កាទៅនៅឯប្រទេសឥណ្ឌានោះ ត្រឡប់មកដណ្តើមរាជសម្បត្តិវិញ។

មិនយូរប៉ុន្មាន មោគ្គល្លានក៏បានចេញមកអំពីប្រទេសឥណ្ឌា ហើយបានចូលមកកាន់នគរកោះលង្កានៅភាគខាងជើង។ ទីនោះព្រះអង្គបានបង្កើតទ័ព ដើម្បីប្រឆាំងនឹងកស្សប ដែលជាប្អូនដែលគ្រងរាជ្យនៅក្រុងអនុរាធបុរី។ នៅពេលនោះព្រះបាទកស្សបមិនអាចទប់ទល់នឹងទ័ពរបស់ព្រះមោគ្គល្លានបាន ទើបព្រះអង្គសម្រេចព្រះទ័យបោះបង់ក្រុងអនុរាធបុរីចោល ហើយមកតាំងនគរនៅនាភ្នំសិគីរី។

ភ្នំសិគីរីនេះ កាលពីសម័យព្រះបាទទេវានម្បិយតិស្ស ព្រះអង្គឱ្យឈ្មោះភ្នំនេះថា: ភ្នំរាជសីហ៍ ព្រោះភ្នំនេះមានសណ្ឋានដូចជាសត្វសីហ:។ ភ្នំនេះមានកំពស់ ៦០០ហ្វីត (១៨២.៨៨ម៉ែត្រ)។ សព្វថ្ងៃនេះពាក្យថារាជនេះ ត្រូវបានគេឈប់ប្រើ នៅសល់តែពាក្យសិគីរី ដែលគេនិយមប្រើជាទូទៅ។

ស្តេចកស្សប បានយកភ្នំសិគីរីនេះធ្វើជាទីតាំងការពារខ្លួន ព្រះអង្គបានកសាងរាជដំណាក់មួយនៅជើងភ្នំ និងរាជដំណាក់មួយទៀតនៅ


www.elibraryofcambodia.org

លើកំពូលភ្នំ។ មោគ្គល្លានបានវាយលុកចូលមកតំបន់នេះ ហើយបានកាត់ផ្តាច់ផ្លូវនាំស្បៀងអាហារ ធ្វើឱ្យស្តេចកស្សបមិនអាចធ្វើសិកសង្គ្រាមប្រឆាំងតបតទៀតបាន ទើបព្រះអង្គធ្វើអត្តឃាតខ្លួនឯងនៅលើកំពូលភ្នំនោះទៅ។ ព្រះបាទកស្សប គឺជាស្តេចតែមួយព្រះអង្គគត់ ដែលបានគ្រងរាជ្យនៅភ្នំសិគិរីនេះ។







www.elibraryofcambodia.org

# វត្តអាលុវិហារ

វត្តអាលុវិហារ ស្ថិតនៅក្នុងស្រុកមត្តលេ ដែលមានចម្ងាយប្រមាណ ២ម៉ៃ (៣.២១៨ គីឡូម៉ែត្រ)ពីទីរួមស្រុកមត្តលេ។ វត្តនេះមានរឿងរ៉ាវដ៏សំខាន់នៅក្នុងព្រះពុទ្ធសាសនា និងប្រវត្តិរបស់ស្តេចវដ្ដគាមិនីអភ័យ ទីនេះក៏ជាទីកន្លែងដែលព្រះរាជាអង្គនេះលាក់ខ្លួនដូចជានៅវត្តតម្បូលៈនោះដែរ។ នៅពេលដែលព្រះអង្គបានកម្ចាត់ពពួកចោរទមិឡ ដែលបានចូលលុកលុយ និងដណ្តើមរាជសម្បត្តិហើយនោះព្រះអង្គក៏បានឡើងគ្រងរាជ្យជាថ្មី។ នៅពេលដែលព្រះអង្គបានឡើងគ្រងរាជ្យជាថ្មី ព្រះអង្គក៏បានកសាងវត្ត ព្រះវិហារ និងព្រះចេតិយដ៏ច្រើនក្នុងនគរកោះលង្កា ក្នុងនោះព្រះអង្គក៏បានថ្វាយគុហាវត្តអាលុវិហារនេះដល់ភិក្ខុសង្ឃ។

វត្តអាលុវិហារ បានកសាងឡើងនៅក្នុងសតវត្សរ៍ទី១ មុនគ.ស។ គម្ពីរព្រះត្រៃបិដកកាលពីសម័យដើម ព្រះសង្ឃពីមួយជំនាន់ទៅមួយជំនាន់ តែងរៀនទន្ទេញតាមមាត់ត។គ្នា ក៏ប៉ុន្តែនៅក្នុងសម័យព្រះបាទវដ្ដគាមិនីអភ័យ ព្រះអង្គបានជ្រើសរើសយកវត្តអាលុវិហារនេះ ធ្វើជា


www.elibraryofcambodia.org

កន្លែងសម្រាប់កត់ត្រាព្រះពុទ្ធវចនៈដំបូងនៅក្នុងគម្ពីរស្លឹករឹត (អារាធនាព្រះធម៌ចូលកាន់គម្ពីរ) ។



វត្តអាលុវិហារ

អាគារដែលមើលឃើញនៅខាងមុខនោះ

កសាងឡើងដោយ សម្តេច សីហនុ នៅឆ្នាំ ១៩៦៥



www.elibraryofcambodia.org

# ព្រះពុទ្ធឃោសាចារ្យ

ភទន្តាចរិយព្រះពុទ្ធឃោសាចារ្យ ព្រះអង្គប្រសូត្រនៅតំបន់គយាសីសៈ ជិតពុទ្ធគយា។ ព្រះអង្គប្រសូត្រនៅក្នុងត្រកូលព្រាហ្មណ៍ដែលមានឪពុកឈ្មោះកេសី ហើយម្តាយឈ្មោះកេសិនី។ នៅពេលដែលព្រះអង្គប្រសូត្រ កាលណោះមានពពួកញាតិជាច្រើនបានមកជួបជុំ និងបានបញ្ចេញនូវសូរសព្ទសម្លេងយ៉ាងទ្រហឹងអឹងកង ក្នុងបរិយាកាសដ៏សប្បាយរីករាយយ៉ាងក្រៃលែង។ ដោយសារតែពេលដែលព្រះអង្គប្រសូត្រនោះមានភាពអ៊ូអរយ៉ាងហ្នឹងហើយ ទើបឪពុកម្តាយដាក់ឈ្មោះឱ្យកូននេះថា ឃោសៈ មានន័យថាអ្នកញ៉ាំងសម្លេងឱ្យកងរំពងឡើង។

ឃោសកុមារ គឺជាកុមារដែលមានប្រាជ្ញាវាងវៃជាងកុមារឯទៀតៗ នៅពេលដែលកុមារនេះមានវ័យធំឡើង ឪពុកម្តាយបានឱ្យទៅរៀននៅក្នុងសំណាក់នៃអាចារ្យព្រាហ្មណ៍។ ការសិក្សានេះមិនយូរប៉ុន្មាន ឃោសកុមារក៏បានរៀនចេះចប់នូវគម្ពីរសិល្បសាស្ត្រជាច្រើនយ៉ាងស្ទាត់ជំនាញ ក្នុងនោះមានទាំងគម្ពីរត្រៃវេទជាដើម។ ក្រោយអំពីការសិក្សាបានចេះចប់ ឃោសកុមារក៏បានចោទសួរនូវសំណួរផ្សេងៗ ទៅអ្នកដែលបានសិក្សាជ្រៅជ្រះជាច្រើន ក៏ប៉ុន្តែគ្មានអ្នកណាម្នាក់ អាចឆ្លើយដោះស្រាយ


www.elibraryofcambodia.org

នូវសំណួររបស់គាត់បានឡើយ ។ ប៉ុន្តែរាល់សំណួរ ដែលគេបានចោទសួរមកគាត់វិញ ឃោសកុមារបានដោះស្រាយយ៉ាងងាយនៅគ្រប់ទិសទី ។

ក្នុងកាលជាខាងក្រោយមក ឃោសកុមារបានចូលទៅក្នុងវត្ត ហើយបានជួបជាមួយនឹងព្រះថេរៈមួយព្រះអង្គ ដែលជាព្រះអរហន្ត បដិសម្ភិទា ព្រះនាមរេវតតិស្សត្ថេរ ។ ឃោសកុមារក៏បានចោទសួរនូវបញ្ហាជាច្រើនដល់ព្រះថេរៈអង្គនេះ ព្រះអង្គបានដោះស្រាយបានយ៉ាងក្បោះក្បាយ និងស្រាយបំភ្លឺបានយ៉ាងជាទីគាប់ចិត្តនូវរាល់សំណួរដែលឃោសកុមារបានចោទសួរ ។ បន្ទាប់មក ព្រះថេរៈលោកក៏បានយកបញ្ហាមួយមកចោទសួរ ត្រឡប់ទៅឃោសកុមារវិញ នោះគឺជាចិត្តបរមត្ថនៅក្នុងគម្ពីរយមកវគ្គ ដូចមានបទជាភាសាបាលីថា:

**យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ**
**និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ។**

ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់
ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ។

**យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧបជ្ជិស្សតិ**
**តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ។**


www.elibraryofcambodia.org

ឬក៏ចិត្តរបស់បុគ្គលណា និងរលត់ និងមិនកើតឡើង

ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់...។

ពេលនោះឃោសកុមារមិនអាចឆ្លើយបាន ហើយនឹកគិតមិនដល់សោះថា តើនឹងមានអ្វីទៀតនោះ ដែលខ្លួនមិនទាន់បានរៀន។ ដោយការមិនបានយល់ដឹងអំពីអត្ថន័យបញ្ហាធម៌ខាងលើ ទើបឃោសកុមារសុំព្រះថេរៈរៀននូវព្រះគាថានេះ។ ព្រះថេរៈមានដីកាតបថា អាត្មាមិនអាចបង្រៀនដល់អ្នកបានទេ ព្រោះអ្នកមិនមែនជាសង្ឃផងនោះ។ ឃោសកុមារតបថា ត្រូវបួសក៏បួសដែរ តែសុំឱ្យព្រះអង្គបំបួសខ្ញុំព្រះករុណា ហើយនឹងបង្រៀននូវមន្តវិជ្ជានោះដល់ខ្ញុំព្រះករុណា។

ព្រះរេវតតិស្សត្ថេរ ព្រះអង្គបានរំពឹងពិចារណាឃើញឱកាសដ៏ល្អដូច្នេះ ទើបព្រះអង្គបំបួសឃោសកុមារ រួចព្រះអង្គក៏ជួយបង្រៀននូវព្រះពុទ្ធវចនៈ គឺគម្ពីរព្រះត្រៃបិដកទាំងអស់ដល់ឃោសភិក្ខុ។ ឃោសភិក្ខុក៏បានសិក្សានូវគម្ពីរព្រះត្រៃបិដកបានចេះចាំយ៉ាងស្ទាត់មាត់។ ព្រះអង្គក៏ជាព្រះថេរៈដែលមានវោហារសព្ទល្អ និងជាធម្មកថិកសម្ដែងព្រះធម៌ទេសនាផ្សព្វផ្សាយល្បីពាសពេញទូទាំងដែនជម្ពូទ្វីប។ ដោយការល្បីខ្ចរខ្ចារនេះហើយ ទើបគេប្រសិទ្ធនាមព្រះអង្គថា ពុទ្ធឃោសាចារ្យ មានន័យថា


www.elibraryofcambodia.org

អាចារ្យជាអ្នកឃោសនា។ ព្រះពុទ្ធឃោសាចារ្យ ចាប់តាំងពីពេលដែលព្រះអង្គបានចូលសាងព្រះផ្នួសមក ព្រះអង្គពុំដែលទំនេរនៅពេលណានោះឡើយ ព្រះអង្គតែងតែសរសេរកត់ត្រាទុកនូវព្រះពុទ្ធវចនៈ ធ្វើជាគម្ពីរផ្សេងៗ បានយ៉ាងច្រើនទុកនៅក្នុងដែនជម្ពូទ្វីប។ មិនតែប៉ុណ្ណោះ ព្រះអង្គមានបំណងចង់រៀបរៀងគម្ពីរអដ្ឋសាលិនី និងគម្ពីរអដ្ឋកថាអភិធម្មសង្គណី ដើម្បីចារទុកនៅក្នុងគម្ពីរសស្ត្រាស្លឹករឹត។

អាស្រ័យដោយមានបំណងយ៉ាងនេះហើយ ទើបព្រះឧបជ្ឈាយ៍ (ព្រះរេវតតិស្សត្ថេរ) លោកបានពន្យល់ណែនាំឱ្យព្រះពុទ្ធឃោសាចារ្យនិមន្តមកកោះលង្កា ព្រោះថានៅកោះលង្កាមានគម្ពីរដីកា អដ្ឋកថាព្រះត្រៃបិដកជាច្រើនដែលព្រះថេរអង្គមុនៗ លោកបានសរសេរចារទុក។

www.elibraryofcambodia.org

# រឿងព្រះពុទ្ធឃោសាចារ្យនៅកំពង់ផែនាកោះលង្កា

ព្រះរេវតតិស្សត្ថេរ ព្រះអង្គបានជ្រាបយ៉ាងច្បាស់ថា ព្រះពុទ្ធឃោសាចារ្យព្រះអង្គគឺជាព្រះសង្ឃដែលមានសមត្ថភាពខ្ពស់ និងចេះចាំស្ទាត់នូវព្រះពុទ្ធវចនៈ ព្រមទាំងភាសាបាលី ដែលជាភាសាអ្នកស្រុកដែនមគធៈ ទើបលោកអនុញ្ញាតឱ្យព្រះពុទ្ធឃោសាចារ្យនិមន្តទៅកោះលង្កានោះ ព្រោះថាទីនោះមានគម្ពីរក្បួនច្បាប់ជាច្រើនដែលសុទ្ធតែជាភាសាសីហឡៈ។

ព្រះពុទ្ធឃោសាចារ្យ បាននិមន្តធ្វើដំណើរចេញអំពីប្រទេសឥណ្ឌាទៅតាមសំពៅឆ្ពោះទៅកាន់កោះលង្កា។ នៅពេលដែលលោកនិមន្តទៅដល់កំពង់ផែនៃនគរកោះលង្កា មិនទាន់ទាំងបានចាកចេញអំពីសំពៅផង ក៏ស្រាប់តែបានជួបនូវរឿងហេតុដ៏ចៃដន្យមួយ គឺថាមានទាសីម្នាក់កាន់ក្អមទឹកចុះមកដងទឹក ហើយឡើងទៅលើច្រាំងវិញ លំដាប់នោះមានទាសីម្នាក់ផ្សេងទៀតដែល មកអំពីត្រកូលគហបតី ក៏បានកាន់ក្អមចុះមកដងទឹកនាពេលនោះដែរ ក៏បានប៉ះទង្គិចគ្នាជាមួយនឹងនាងទាសីដែលកំពុងយកទឹកឡើងទៅលើច្រាំង។ ពេលនោះនាងទាំងពីរក៏បានដួលហើយបានធ្លាក់ក្អមបែកខ្ចាត់ខ្ចាយអស់ ពេលនោះក៏កើតជារឿងឈ្លោះ


www.elibraryofcambodia.org

ប្រទូស្តរាយជេរប្រទិចគ្នាទៅវិញទៅមក ដោយប្រការផ្សេងៗយ៉ាងច្រើន។ ព្រះពុទ្ធឃោសាចារ្យព្រះអង្គគិតថា នឹងប្រាកដជាកើតនូវរឿងធំមិនខាន ហើយម្យ៉ាងវិញទៀត នៅទីនេះពុំមានអ្នកណាឃើញ ឬអាចធ្វើជាសាក្សីក្រៅអំពីខ្លួនព្រះអង្គនោះផង ហើយនាងទាសីទាំងពីរនេះប្រាកដជាអាងលើអាត្មាអញពុំខានឡើយ តែអាត្មាអញជាព្រះសង្ឃពុំអាចនិមន្តទៅកាន់សាលាក្តីនោះបានទេ។ ដូច្នេះទើបលោកចាប់ដែកចារនឹងស្លឹករឹតដែលជាប់មកជាមួយ កាលដែលព្រះរេវតតិស្សត្ថេរបានប្រគល់ឱ្យលោក មុនចុះកាន់សំពៅយកមកចារ។ លោកបានចាររឿងរ៉ាវទាំងអស់ ហើយនិងពាក្យជេរបញ្ចោគ្នាទៅវិញទៅមក ទាំងជេរថាយ៉ាងម៉េចៗ លោកបានកត់ត្រាទាន់ទាំងអស់ឥតចន្លោះមួយមាត់ណាឡើយ។ តាមតំណាលមកថា: លោកបានចារដោយប្រើដៃទាំងពីរតែម្តង។ ដៃមួយលោកសរសេរពាក្យរបស់នាងម្ខាង ហើយដៃមួយទៀតលោកសរសេរពាក្យជេររបស់នាងម្ខាងទៀត។ ពាក្យជេរគ្រប់ម៉ាត់ទាំងប៉ុន្មានលោកបានសរសេរ ហើយបើរាប់ទៅឃើញមានពាក្យជេរទាំងអស់ប្រាំបីម៉ឺនពាក្យ រួចលោកប្រមូលស្លឹករឹតនោះទុកមួយដំផ្សេងៗគ្នា។


www.elibraryofcambodia.org

មែន! កើតទៅជារឿងមែន គឺរឿងផ្តើមតាំងពីរឿងនាងទាសីឈ្មោះប្រកែកគ្នា តរហូតដល់រឿងរបស់សេដ្ឋី និងគហបតីដែលជាចៅហ្វាយនាយរបស់នាងទាសីម្នាង១ ឈ្មោះប្រកែកគ្នានឹងមានការប្តឹងផ្តល់គ្នារហូតទៅដល់ព្រះរាជា។ កាលណោះព្រះរាជាក៏បានសាកសួររកសាក្សីដើម្បីជួយស្រាយបំភ្លឺពេលនោះ។ នាងទាសីក៏បានទូលថ្វាយព្រះអង្គថាមានតែព្រះថេរៈមួយព្រះអង្គប៉ុណ្ណោះ ដែលព្រះអង្គបានគង់នៅទីនោះដែលជាអ្នកបានឃើញនូវរឿងហេតុនេះផ្ទាល់។ ពេលនោះ ព្រះរាជាទ្រង់បានបញ្ជាឱ្យអាមាត្យទៅនិមន្តព្រះសង្ឃអង្គនោះ មកបំភ្លឺដល់ព្រះអង្គ។ ព្រះពុទ្ធឃោសាចារ្យ នៅពេលដែលព្រះអង្គបានឃើញនូវរាជអាមាត្យមកនិមន្តព្រះអង្គដូច្នោះ ទើបមានថេរដីកាទៅកាន់អាមាត្យទាំងនោះថា អាត្មាមិនសមគួរនឹងចូលទៅកន្លែងកាត់ក្តីនោះទេ ក៏ប៉ុន្តែរឿងនេះអាត្មាបានកត់ត្រាទុកអស់ហើយ គឺនៅក្នុងសន្ត្រាស្លឹករឹតនេះឯង សូមអ្នកយកទៅថ្វាយព្រះរាជា ដើម្បីឱ្យទ្រង់វិនិច្ឆ័យទៅតាមព្រះរាជអធ្យាស្រ័យរបស់ព្រះអង្គចុះ ចំណែកអាត្មាមិនបាច់និមន្តទៅនោះទេ។

កាលដែលព្រះរាជា ទ្រង់ទតឃើញនូវកំណត់ហេតុនៃរឿងរ៉ាវនេះសព្វគ្រប់ហើយ ទើបព្រះអង្គទ្រង់កោតសរសើរចំពោះបញ្ញាដ៏ឈ្លាស


www.elibraryofcambodia.org

វិវរបស់ព្រះថេរៈ។ ព្រះអង្គទ្រង់មានសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធឃោសាចារ្យយ៉ាងខ្លាំង ហើយទ្រង់ព្រះតំរិះថា នៅនគរកោះលង្កាមានព្រះថេរៈច្រើនមែនហើយ ក៏ប៉ុន្តែព្រះសង្ឃទាំងនោះមិនឈ្លាសវៃដូចព្រះថេរៈនេះឡើយ។ ព្រះរាជាព្រះអង្គមានសទ្ធាចំពោះព្រះពុទ្ធឃោសាចារ្យ ហើយបានទំនុកបំរុងនូវចតុប្បច្ច័យ ព្រមទាំងបានជួយនូវរាល់កិច្ចការងារដែលព្រះពុទ្ធឃោសាចារ្យត្រូវការ។

ព្រះមហាក្សត្រសោយរាជនៅនគរកោះលង្កាកាលណោះគឺព្រះអង្គព្រះនាមមហានាម នៅក្នុងរជ្ជកាលរបស់ព្រះអង្គនេះ តាំងពី គ.ស ៤១២-៤៣៤។



រូបសំណាក ព្រះពុទ្ធឃោសាចារ្យ


www.elibraryofcambodia.org

# ស្លាមព្រះហស្តព្រះពុទ្ធឃោសាចារ្យ

កាលព្រះភទន្តចរិយាពុទ្ធឃោសាចារ្យ និមន្តមកគង់នៅក្នុងនគរកោះលង្កាដំបូង ព្រះសង្ឃទាំងឡាយខាងមហាវិហារមិនសូវជាអើពើយកចិត្តទុកដាក់ទេ សំគាល់គ្រាន់តែជាសង្ឃធម្មតាប៉ុណ្ណោះ បានប្រគល់នូវគាថាពីរបទក្នុងសំយុត្តនិកាយ គឺមួយបទត្រង់ដែលទេវតាទូលសួរព្រះមានព្រះភាគ និងមួយបទទៀតត្រង់ដែលព្រះពុទ្ធដីកាសំដែងទៅកាន់ពពួកទេវតា ។ មិនតែប៉ុណ្ណោះទេ បានប្រមូលពុទ្ធវចនៈពីក្នុងព្រះត្រៃបិដកយកមកប្រគេនដល់ព្រះពុទ្ធឃោសាចារ្យដើម្បីឱ្យលោករៀបរៀងគឺ:

១. **សព្វបាបស្ស អករណំ** = មិនធ្វើនូវអំពើបាបទាំងពួង ។

២. **កុសលស្សូបសម្បទា** = ធ្វើនូវអំពើជាកុសល ។

៣. **សចិត្តបរិយោទបនំ** = ជំរះចិត្តឱ្យស្អាតផូរផង់ ។

ព្រះពុទ្ធឃោសាចារ្យ បានរៀបរៀងពិពណ៌នាអធិប្បាយព្រះពុទ្ធវចនៈទាំងអស់ឱ្យបានពិស្តារ ហើយយកទៅប្រគេនព្រះសង្ឃដែលគង់ក្នុងវត្តមហាវិហារ នោះគឺជាគម្ពីរវិសុទ្ធិមគ្គ ។ លោកបានធ្វើកិច្ចការដ៏ធំដើម្បីជាប្រយោជន៍ព្រះពុទ្ធសាសនា គឺការរៀបរៀងចងក្រងព្រះពុទ្ធ


www.elibraryofcambodia.org

វចនៈនៅក្នុងគម្ពីរសស្ត្រាស្លឹករឹត និងបកប្រែពីភាសាសីហឡៈ ទៅជាភាសាមគធៈ (ភាសាបាលី) ទាំងអស់។ ព្រះពុទ្ធឃោសាចារ្យបានប្រែអស់រយៈពេល១ឆ្នាំទើបចប់ ដែលអ្នកស្រុកស្រីលង្កាបានចាត់ទុកថាជាសង្គាយនាទី ៦ (ឆដ្ឋសង្គាយនា)។ មិនតែប៉ុណ្ណោះ ព្រះពុទ្ធឃោសាចារ្យបានសរសេរគម្ពីរអដ្ឋកថាជាច្រើនដូចជា:

## វិន័យបិដក

| | | |
|---|---|---|
| គម្ពីរ | សមន្តប្បាសាទិកា | អដ្ឋកថាព្រះវិន័យ |
| គម្ពីរ | កង្ខាវិតរណី | អដ្ឋកថាបាតិមោក្ខ |

## អដ្ឋកថាសុត្តន្តបិដក

| | |
|---|---|
| គម្ពីរ សុមង្គលវិលាសិនី | អដ្ឋកថាទីឃនិកាយ |
| គម្ពីរ បបញ្ចសូទនី | អដ្ឋកថា មជ្ឈិមនិកាយ |
| គម្ពីរ សារត្ថប្បកាសិនី | អដ្ឋកថា សំយុត្តនិកាយ |
| គម្ពីរ មនោរថបូរណី | អដ្ឋកថា អង្គុត្តរនិកាយ |
| គម្ពីរ បរមត្ថជោតិកា | អដ្ឋកថា ខុទ្ទកបាឋសុត្តនិបាត |
| គម្ពីរ ធម្មបទដ្ឋកថា | អដ្ឋកថា ធម្មបទ |


www.elibraryofcambodia.org

គម្ពីរ ជាតកត្ថកថា អដ្ឋកថា ជាតក

## អដ្ឋកថាអភិធម្មបិដក

គម្ពីរ អដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណី

គម្ពីរ សម្មោហវិនោទនី អដ្ឋកថា វិភង្គ

គម្ពីរ បញ្ចបករណត្ថកថា អដ្ឋកថា មានប្រាំគម្ពីរ

ស្នាមព្រះហស្តដែលព្រះពុទ្ធឃោសាចារ្យបានរៀបរៀងនេះគឺសុទ្ធតែមានសារៈសំខាន់ទាំងអស់ ហើយជាពិសេសគឺគម្ពីរវិសុទ្ធិមគ្គ ដែលជាស្នាដៃឯក ដែលព្រះពុទ្ធឃោសាចារ្យលោកបាននិពន្ធរៀបរៀងនូវព្រះពុទ្ធវចនៈចេញអំពីព្រះត្រៃបិដក ដែលសម្តែងអំពី សីល សមាធិ បញ្ញា។ ការរៀបចំគម្ពីរវិសុទ្ធិមគ្គនេះមានរឿងតំណាលថាៈ គម្ពីរវិសុទ្ធិមគ្គ កាលដែលបានរៀបរៀងរួចហើយ មានភិក្ខុទាំងឡាយបានយកគម្ពីរនេះទៅអាន ហើយក៏បានបាត់មិនដឹងទៅទីណា ទើបព្រះពុទ្ធឃោសាចារ្យលោកសរសេររៀបរៀងមួយក្បាលទៀត។ លើកទី២នេះ ក៏បានរសាត់បាត់ដូចកាលពីលើកទី១ទៀត។ ព្រះពុទ្ធឃោសាចារ្យ ព្រះអង្គមិនបានស្រាវជ្រាវរកនោះឡើយ លោកក៏បានសរសេររៀបរៀងមួយក្បាលទៀតជាសៀវភៅទី៣ ប្រគេនព្រះសង្ឃក្នុងវត្តមហាវិហារដើម្បីសិក្សា។

www.elibraryofcambodia.org

លំដាប់នោះគម្ពីរវិសុទ្ធិមគ្គ ក្បាលទី១ និងទី២ ដែលបានបាត់នោះ ស្រាប់តែបានឃើញមកវិញ ព្រះថេរៈទាំងឡាយដែលគង់ក្នុងវត្តមហាវិហារ ក៏បាននាំគ្នាពិនិត្យផ្ទៀងផ្ទាត់នូវគម្ពីរទាំងបីនោះឃើញថា មានសេចក្តីអធិប្បាយ និងឃ្លាទាំងឡាយដូចគ្នា ឥតមានខុសបន្តិចណាឡើយ។ ឃើញដូច្នោះ ភិក្ខុសង្ឃទាំងឡាយដែលគង់ក្នុងវត្តមហាវិហារអង្គខ្លះសន្និដ្ឋានថាព្រះពុទ្ធឃោសាចារ្យគឺជាតួអង្គព្រះពោធិសត្វព្រះសិអារ្យមេត្តេយ្យ។



រូបសំណាកព្រះពុទ្ធឃោសាចារ្យកំពុងចារគម្ពីរ

www.elibraryofcambodia.org

# ទីក្រុងខេនឌី

ខេនឌី គឺជាទីក្រុងមួយដែលបានបង្កើតឡើងដោយព្រះបាទសេនាសមន្តាវិក្រាមពាហុ កសាងនៅ គ.ស ១៤៦៩។ ទីក្រុងខេនឌីគឺជាទីក្រុងមួយដែលមានលំអទៅដោយភ្នំ ស្ទឹង បឹង និង ទឹកឈូរ។ ទីក្រុងនេះស្ថិតនៅតាមជងភ្នំ ដែលមានចម្ងាយប្រមាណ ១១៦គីឡូម៉ែត្រ ពីក្រុងកូឡុំបូ។ ទីក្រុងនេះមានសាសនាជាច្រើន ហើយសាសនាមួយៗ គេបានកសាងនូវព្រះវិហារសម្រាប់ធ្វើសក្ការបូជាទៅតាមជំនឿរបស់ពួកគេ។ ខេនឌី ក៏ជារាជធានីចុងក្រោយមួយសម្រាប់ស្តេចគ្រងរាជសម្បត្តិនៅក្នុងនគរកោះលង្កា។ ព្រះទន្តធាតុ (ព្រះចង្កូមកែវ) របស់ព្រះសម្មាសម្ពុទ្ធ បាននាំយកមកតម្កល់ទុកនៅក្នុងទីក្រុងនេះ ដោយព្រះបាទវិមុលធម្មសុរិយទី១ ។ វត្តដែលតម្កល់ព្រះទន្តធាតុនេះ បានកសាងឡើងដោយព្រះបាទស្រីវិក្រាមរាជសីហះ ។

www.elibraryofcambodia.org

# វត្តតម្កល់ព្រះទន្តធាតុ

ព្រះទាឋធាតុ ឬ ព្រះទាឋាធាតុ = ព្រះទន្តធាតុ (ជាវេវចនស័ព្ទ) មានន័យថា ព្រះចង្កូមកែវរបស់ព្រះសម្មាសម្ពុទ្ធ ដែលប្រតិស្ឋានទុកមក ដល់សព្វថ្ងៃនេះ។ ព្រះទន្តធាតុរបស់ព្រះសម្មាសម្ពុទ្ធទាំង៤ បានប្រតិស្ឋាន នៅទីផ្សេងៗ ដូចជា :

១. ព្រះទន្តធាតុស្តាំខាងលើ ប្រតិស្ឋាននៅនាឋានតាវត្តិង្ស ទេវលោកដែលពពួកទេវតា និងព្រហ្មទាំងឡាយធ្វើសក្ការ បូជា។

២. ព្រះទន្តធាតុឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុងដែនគន្ធារៈ។ សព្វថ្ងៃប្រទេស អហ្គានិស្ថាន (Afghanistan) ព្រះទន្តធាតុ នេះសព្វថ្ងៃ បានស្ថិតនៅក្រុងប៉េកាំង ប្រទេសចិន។

៣. ព្រះទន្តធាតុឆ្វេងខាងក្រោម ប្រតិស្ឋាននៅក្នុងពិភពនាគ។

៤. ព្រះទន្តធាតុមួយ ស្ថិនៅដែនកលិង្គៈ។ សព្វថ្ងៃនេះបានឃ្លាត មកដល់នគរកោះលង្កា (សីហឡទ្វីប) គេបានតម្កល់នៅ ក្នុងក្រុងខេនឌី។ ជារៀងរាល់ឆ្នាំនៅចុងខែកក្កដា និង ដើមខែសីហា គេតែងតែប្រារព្ធធ្វើពិធីបុណ្យដង្ហែព្រះទន្ត

www.elibraryofcambodia.org

ធាតុនេះចេញអំពីវត្តដែលតម្កល់ ហើយដាក់ព្រះទន្តធាតុ នោះនៅក្នុងបុស្បុកលើខ្នងដំរី និងមានកម្មវិធីដង្ហែទៅតាមវិថីទាំងឡាយ ដើម្បីពួកជនអ្នកស្រុកបានធ្វើសក្ការៈគោរពបូជា។ នេះគឺជាព្រះទន្តធាតុស្ដាំខាងក្រោម។

ប្រវត្តិនិងដំណើររឿងនៃព្រះទន្តធាតុ ដែលបាននាំមកកាន់នគរកោះលង្កានេះ មានសេចក្ដីតំណាលថា នៅពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ចូលបរិនិព្វាន ព្រះកាយរបស់ព្រះអង្គត្រូវបានគេដាក់បូជានៅក្នុងម្ឈូសដែលធ្វើអំពីឈើខ្លឹមចន្ទន៍ នៅក្រុងកុសិនារាប្រទេសឥណ្ឌា។ ព្រះអង្គបានបន្សល់នូវព្រះទន្តធាតុរបស់ព្រះអង្គ ព្រះអរហន្តភិក្ខុនីខេមាបាននិមន្តទៅយកព្រះទន្តធាតុនេះនៅទីកន្លែងបូជាព្រះសពរបស់ព្រះសម្មាសម្ពុទ្ធ។ ភិក្ខុនីខេមា បាននាំយកព្រះទន្តធាតុនេះទៅថ្វាយដល់ព្រះបាទព្រហ្មទត្តសម្រាប់ព្រះអង្គធ្វើសក្ការៈគោរពបូជា។ ព្រះបាទព្រហ្មទត្តក៏បានរៀបចំពិធីដង្ហែព្រះទន្តធាតុ មកតម្កល់នៅក្នុងក្រុងទន្តបុរី (បច្ចុប្បន្នឈ្មោះបុរីក្នុងរដ្ឋអូរិស្សា)។

ចាប់តាំពីព្រះទន្តធាតុរបស់ព្រះសម្មាសម្ពុទ្ធនេះ បានមកតាំងនៅក្នុងនគររបស់ព្រះបាទព្រហ្មទត្តមក ធ្វើឱ្យប្រជានុរាស្ត្រនៅក្នុងនគរនេះ

www.elibraryofcambodia.org

ទាំងមូល បានបោះបង់ចោលជំនឿរបស់ខ្លួន ហើយមកកាន់យកជំនឿនៅក្នុងព្រះពុទ្ធសាសនាវិញ។ នៅសតវត្សរ៍ទី៤ ក្រោយពីព្រះអង្គទ្រង់ចូលបរិនិព្វានទៅបាន៨០០ឆ្នាំ ព្រះបាទគុហសីវៈ ក្នុងដែនកលិង្គៈក៏មានព្រះទ័យច្រណែន ចង់បានព្រះទន្តធាតុមកទុកនៅក្នុងនគររបស់ព្រះអង្គ១ ក៏បានធ្វើសឹកសង្គ្រាមដណ្តើមព្រះទន្តធាតុអំពីព្រះបាទព្រហ្មទត្ត។ ក្រោយមក ព្រះអង្គក៏បានដណ្តើមព្រះទន្តធាតុនោះបាន ហើយបានយកទៅតម្កល់នៅក្នុងដែនកលិង្គៈ។ ចាប់តាំងពីពេលនោះមក ប្រជានុរាស្ត្រនៅក្នុងដែននេះទាំងមូល ក៏បានកាន់យកជំនឿនៅក្នុងព្រះពុទ្ធសាសនា ដែលមានព្រះទន្តធាតុជាទីពឹងទីរលឹករបស់ពួកគេ។ ដោយបានឃើញការផ្លាស់ប្តូរនូវជំនឿដោយសារព្រះទន្តធាតុនេះ ប្រជានុរាស្ត្រមួយចំនួន ដែលមានចិត្តទោមនស្សនឹងព្រះពុទ្ធសាសនា ក៏បាននាំរឿងនេះមកក្រាបទូលថ្វាយព្រះបាទបណ្ឌុនៃដែនមធុរៈថា ព្រះបាទគុហសីវៈព្រះអង្គបានបញ្ឈប់ប្រជានុរាស្ត្រ មិនឱ្យជឿទៅលើព្រះអាទិទេព ហើយបានបង្ខំឱ្យប្រជានុរាស្ត្រធ្វើសក្ការគោរពបូជាតែចំពោះព្រះទន្តធាតុ និងកាន់យកជំនឿនៅក្នុងព្រះពុទ្ធសាសនា។ ព្រះបាទបណ្ឌុ ក្រោយពីទ្រង់ព្រះសណ្តាប់នូវរឿងនេះ ព្រះអង្គពិរោធយ៉ាងខ្លាំង ហើយព្រះអង្គមាន

www.elibraryofcambodia.org

ព្រះទ័យចង់បំផ្លាញព្រះទន្តធាតុនោះចោល។ ព្រះអង្គក៏បានបញ្ជាឱ្យគេទៅនាំព្រះទន្តធាតុមកថ្វាយព្រះអង្គ។ នៅពេលដែលគេបាននាំយកព្រះទន្តធាតុនេះមកដល់នគររបស់ព្រះបាទបណ្ឌុ ពេលនោះព្រះទន្តធាតុក៏បានសម្តែងនូវបាដិហារ្យដ៏អស្ចារ្យ ធ្វើឱ្យព្រះបាទបណ្ឌុ និងប្រជានុរាស្ត្រនៅក្នុងដែននេះកាន់យកនូវជំនឿក្នុងព្រះពុទ្ធសាសនាដែរ។ នៅពេលដែលព្រះបាទកេសរធរៈ បានឮនូវដំណឹងថា ព្រះបាទបណ្ឌុបានកាន់យកព្រះពុទ្ធសាសនាជាជំនឿដូច្នោះ ព្រះអង្គក៏ពិរោធយ៉ាងខ្លាំង ហើយបានយាងមកកាន់ដែនមធុរៈជាមួយពលសេនាដ៏ច្រើន ដើម្បីប្រឆាំងនឹងព្រះបាទបណ្ឌុ។ ព្រះបាទកេសរធរៈ ត្រូវបានគេធ្វើគុត នៅពេលដែលព្រះអង្គចូលលុកលុយដែនមធុរៈ។ ក្រោយមកព្រះរាជកុមារមួយព្រះអង្គព្រះនាមទន្តកុមារ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា មកអំពីដែនឧជ្ជេនីដើម្បីមកថ្វាយបង្គំចំពោះព្រះទន្តធាតុ។ ពេលនោះព្រះបាទគុហសីវបានទតឃើញព្រះអង្គក៏សព្វព្រះទ័យចំពោះទន្តកុមារ ហើយបានអភិសេកព្រះរាជកុមារនេះ ជាមួយព្រះរាជបុត្រីរបស់ព្រះអង្គឈ្មោះ ហេម្មមាលា។

នៅពេលដែលគេបានដឹងថា ព្រះបាទកេសរធរៈទ្រង់បានសោយទិវង្គតនៅក្នុងសង្គ្រាមនោះ ព្រះរាជបុត្ររបស់ព្រះអង្គបានដឹកនាំពល

www.elibraryofcambodia.org

សេនាដ៏ច្រើន ដើម្បីមកប្រឆាំងនឹងព្រះបាទគុហសីវ និងបំផ្លាញចោល នូវព្រះទន្តធាតុនោះ ប៉ុន្តែនៅពេលដែលពួកគេបានចូលមកជិតដល់ច្រក ទ្វារក្រុង ព្រះបាទគុហសីវបានលួចបញ្ជូនព្រះរាជកុមារទន្ត និងព្រះនាង ហេម្មមាលា ចេញពីក្រុងដោយភ្ជាប់ជាមួយនិងព្រះទន្តធាតុផងដែរ។



ព្រះនាងហេម្មមាលា បានលាក់ព្រះទន្តធាតុនៅក្នុងផ្នួងសក់ រួច ព្រះនាងនិងព្រះស្វាមី បានតាក់តែងខ្លួនធ្វើជាព្រាហ្មណ៍ ដើម្បីជៀសវាង នូវការសង្ស័យអំពីអ្នកដទៃ។ បន្ទាប់មកព្រះនាង និងព្រះស្វាមីបាន ចាកចេញអំពីរាជធានី ហើយធ្វើដំណើរឆ្ពោះទៅកាន់កំពង់ផែ ដែលមាន ឈ្មោះថា តម្ពលិទិ ក៏បានឡើងសំពៅអំពីទីនោះឆ្ពោះមកកាន់នគរ កោះលង្កា។ ពួកគេបានមកដល់កំពង់ផែនៃនគរកោះលង្កាដែលមាន ឈ្មោះថាលង្កាបត្តនៈ។ ចាប់តាំងពីពេលនោះមក ព្រះទន្តធាតុបានមក

www.elibraryofcambodia.org

តាំងនៅក្នុងនគរកោះលង្កា ដូចដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ប្រតិ-ស្ថានទុកថា នគរកោះលង្កាជាទីកន្លែងដែលសាសនារបស់ព្រះអង្គ នឹងតាំងនៅយូរអង្វែងជាងទីណាៗ នោះមែន ។

ព្រះរាជបុត្រទន្ត និងព្រះនាងហេម្មមាលា បានមកដល់នគរកោះលង្កានេះនៅក្នុងរជ្ជកាលនៃព្រះបាទកិត្តិស្រីមេឃវ័ន ដែលគ្រងរាជ្យនៅក្នុងក្រុងអនុរាធបុរី ។ ព្រះរាជាទ្រង់មានព្រះទ័យរីករាយឥតឧបមា នៅពេលដែលព្រះអង្គទ្រង់បានទទួលដំណឹងថា ព្រះរាជកុមារនិងព្រះនាងហេម្មមាលា បាននាំព្រះទន្តធាតុមកកាន់នគររបស់ព្រះអង្គ ។ ដោយសេចក្តីជ្រះថ្លា ព្រះអង្គក៏បានចាត់ចែងធ្វើពិធីបុណ្យយ៉ាងឱឡារិក និងចាត់ចែងឱ្យគេកសាងប្រាសាទដ៏ប្រណីតនៅក្នុងបរិវេណព្រះបរមរាជវាំងដើម្បីតម្កល់ព្រះទន្តធាតុ ។ ជារៀងរាល់ឆ្នាំ ដោយសេចក្តីគោរព និងជ្រះថ្លា ព្រះអង្គក៏បានចាត់ចែងឱ្យគេរៀបចំពិធីបុណ្យមួយឈ្មោះ បេរាហរៈ ដើម្បីដង្ហែព្រះទន្តធាតុ ។

នៅសម័យកាលខាងក្រោយមក ក្រុងអនុរាធបុរីត្រូវបានពួកជនបរទេសចូលឈ្លានពានជាញឹកញាប់ ដូច្នេះរាជធានីក៏ត្រូវបានផ្លាស់ប្តូរពីកន្លែងមួយទៅកាន់កន្លែងមួយ ដូចជាពីក្រុងអនុរាធបុរី ប្តូរទៅកាន់


www.elibraryofcambodia.org

ក្រុងបុទ្បុណ្ណវូរ: បន្ទាប់មកប្តូរទៅតម្លទេនិយ: និងប្តូរអំពីទីនេះទៅកាន់កន្លែងផ្សេងៗជាច្រើនទៀត។ រាល់ការប្តូររាជធានី ប្រាសាទសម្រាប់តម្កល់ព្រះចង្កូមកែវក៏ត្រូវបានគេកសាងនៅគ្រប់ក្រុងទាំងអស់ផងដែរ។ នៅពេលបច្ចុប្បន្ន ព្រះទន្តធាតុក៏ត្រូវបានគេនាំមកតម្កល់នៅក្នុងក្រុងខេនឌី។ បុណ្យឬការប្រារព្ធពិធីបូជាផ្សេងៗ ចំពោះព្រះទន្តធាតុមានពិធីច្រើនបែបច្រើនយ៉ាង ដូចកាលដែលព្រះអង្គគង់ធរមាននៅដូច្នោះដែរ។ សព្វថ្ងៃនេះមានព្រះសង្ឃរាជនៃនិកាយពីរ ដែលទទួលភារៈ មើលថែរក្សាព្រះទន្តធាតុ

១- និកាយមាវត្ត:។

២- និកាយមាលិត្តវ: និងរដ្ឋាភិបាលស្រីលង្កាទាំងមូល។


www.elibraryofcambodia.org

# ភ្នំសុមនកូដ

ភ្នំសុមនកូដ, ស្រីបាទ ឬ អាដាំភិក ជាទីកន្លែងដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកនូវស្នាមព្រះបាទ សម្រាប់ពុទ្ធសាសនិកជនគ្រប់រូបធ្វើសក្ការៈគោរពបូជា។ ភ្នំនេះមានកំពស់ ៧៣៦០ ហ្វីត (២២៤៣.៣២៨ ម៉ែត្រ) អំពីផ្ទៃសមុទ្រ។ រដូវកាលដែលគេអនុញ្ញាតឱ្យឡើងភ្នំ គឺនៅរៀងរាល់ឆ្នាំ ក្នុងថ្ងៃពេញបូណ៌មី ខែមិគសិរ (ពាក់កណ្ដាល ខែធ្នូ) ហើយបញ្ចប់ទៅវិញ នៅរៀងរាល់ឆ្នាំ ក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ (ពាក់កណ្ដាល ខែឧសភា)។ ទីស្ថានដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកនូវស្នាមព្រះបាទមាន ៥ កន្លែងគឺ :

១ - សុវណ្ណមាលិកេ នៅសុវណ្ណមាលិក

២ - សុវណ្ណបព្វតេ នៅលើភ្នំសុវណ្ណបពិត

៣ - សុមនកូដេ នៅលើភ្នំសុមនកូដ

៤ - យោនកបុរេ នៅក្នុងយោនកបុរី

៥ - នម្មទាយ នៅក្បែរស្ទឹងនម្មទា

តាមគម្ពីរមហាវង្សបានសម្ដែងថា ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រតិស្ឋានស្នាមព្រះបាទទុកនៅលើភ្នំសុមនកូដ នៅក្នុងកាលដែលព្រះ


www.elibraryofcambodia.org

អង្គយាងមកកាន់នគរកោះលង្កានេះលើកទី៣ ជាមួយនិងភិក្ខុសង្ឃជាសាវ័ក ៥០០អង្គ ដើម្បីទទួលភត្តរបស់ស្តេចនាគឈ្មោះមនិអក្ខិកនៅក្នុងនគរកល្យាណី។ ក្រោយអំពីភត្តកិច្ចចប់ស្រេចហើយ ព្រះអង្គទ្រង់បានយាងទៅកាន់ភ្នំសុមនកូដ តាមការអារាធនារបស់សុមនទេវបុត្រ។ ព្រះអង្គនិងសាវ័កទាំងឡាយ ទ្រង់បានគង់នៅក្នុងទីនោះ អស់រយៈពេលមួយថ្ងៃ។ បន្ទាប់មកព្រះអង្គព្រមទាំងសាវ័កបាននិមន្តទៅកាន់តំបន់មួយឈ្មោះទីឃវាបិ។ ក្រោយមកទីនោះ គេបានកសាងព្រះចេតិយនៅត្រង់ទីកន្លែងដែលព្រះអង្គទ្រង់គង់ចូលនិរោធសមាបត្តិ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គជាអ្នកជ្រាបនូវទីឋានដ៏សមគួរ ពេលនោះព្រះអង្គបាននិមន្តយាងមកកាន់សួនឧទ្យានមេឃវ័ន ហើយទ្រង់យាងចូលនិរោធសមាបត្តិ នៅទីកន្លែងដែលដាំដើមមហាពោធិព្រឹក្សជាមួយនិងភិក្ខុសាវ័ក។ បន្ទាប់មកព្រះអង្គក៏បានយាងទៅកាន់កន្លែងដែលកសាងសុវណ្ណមាលិកចេតិយនិងកន្លែងកសាងថូបារាម។ រួចមកព្រះអង្គទ្រង់បានធ្វើនូវសេចក្តីប្រកាសនូវទីឋាន ដែលត្រូវកសាងបូជនីយដ្ឋាន សម្រាប់ធ្វើសក្ការគោរពបូជា។ ពេលនោះទេវតាទាំងឡាយ បានបញ្ចេញនូវសម្លេងកងរំពងគ្រប់៧ឋាន។ ព្រះសម្មាសម្ពុទ្ធ មួយអន្លើដោយភិក្ខុសង្ឃជាសាវ័កទាំងឡាយបាន


www.elibraryofcambodia.org

ប្រទក្សិណនៅទីឋានទាំងនោះ ចំនួនបីជុំរួចហើយទើបព្រះអង្គទ្រង់យាង ត្រឡប់ទៅកាន់វត្តជេតពន នៅជម្ពូទ្វីបវិញ ។



ភ្នំសុមនកូដ ប្រទេសស្រីលង្កា


www.elibraryofcambodia.org

# វត្តគង្គារាម

វត្តគង្គារាម កាលដើមឡើយជាវត្តតូចធម្មតាមួយដូចជាវត្តគេដ៏ទៃឯទៀតៗដែរ ក៏ប៉ុន្តែក្រោយមក វត្តនេះមានការរីកចំរើន ហើយបានក្លាយទៅជាវត្តមួយដ៏ល្បីឈ្មោះ ទាំងក្នុងនិងក្រៅប្រទេស។ វត្តគង្គារាម ជាវត្តមួយដ៏សំខាន់ក្នុងចំណោមវត្តដ៏ច្រើននៅក្នុងប្រទេសស្រីលង្កាសំរាប់ពុទ្ធមាមិកជនធ្វើបុណ្យទានផ្សេងៗ។ វត្តនេះឋិតនៅក្នុងទីក្រុងកូឡំបូ នៅតាមបណ្តោយផ្លូវ ស្រីជិណ្ណរតនលេខ ៦១ ។ អ្វីដែលសំខាន់ជាងគេដែលវត្តនេះមាននោះគឺព្រះពុទ្ធរូបតូចធំដែលបាននាំមកអំពីប្រទេសផ្សេងៗ ហើយមានគម្ពីរស្លឹករិតជាភាសាស្រីលង្កាជាច្រើនប្រភេទ ដែលគេបានយកមករក្សាទុកនៅក្នុងបណ្ណាល័យរបស់វត្ត។

ម្យ៉ាងវិញទៀត វត្តនេះក៏ជាមជ្ឈមណ្ឌលសិក្សាដ៏សំខាន់សំរាប់ប្រជាជនទូទៅ។ មិនតែប៉ុណ្ណោះ វត្តនេះជាទីកន្លែងដែលទាក់ទាញភ្ញៀវទេសចរណ៍បរទេសដ៏សំខាន់។ ជារៀងរាល់ឆ្នាំមានភ្ញៀវទេសចរណ៍បរទេសជាច្រើន បានចូលមកទស្សនានៅក្នុងទីវត្តនេះមិនដែលខានឡើយ។ ក្នុងបរិវេណវត្តនេះ មានបណ្ណាល័យសំរាប់សិក្សា និងដើមមហាពោធិព្រឹក្សព្រមទាំងព្រះចេតិយ និងមានបន្ទប់សំរាប់តម្កល់ព្រះធាតុរបស់ព្រះអរហន្ត



www.elibraryofcambodia.org

ហើយនៅក្នុងបន្ទប់នោះក៏មានតម្កល់ព្រះពុទ្ធរូបធ្វើអំពីមាស និងវត្ថុដ៏មានតំលៃផ្សេងៗជាច្រើនផងដែរ។ នៅក្នុងគុហាកណ្តាលនៃទីវត្តមានព្រះពុទ្ធរូបពណ៌មាសមួយព្រះអង្គធំ និងខាងស្តាំមានព្រះពុទ្ធរូបទ្រង់ឈរមួយព្រះអង្គ។ នៅទីនេះគេមានជំនឿថា ក្មេងៗដែលទើបនឹងកើតឪពុកម្តាយតែងតែនាំមកថ្វាយព្រះអង្គ ដើម្បីឱ្យព្រះអង្គជួយប្រោសព្រំឱ្យបាននូវសេចក្តីសុខចម្រើន។





ពិធីបុណ្យបំបួសនាគ ដល់កុលបុត្រត្រីត្រនិងកំព្រា ដែលមានចំនួន ២២អង្គ

ស្ថិតនៅក្នុងវត្តឧទុម្ពរ ហៅក្រាំងល្វា

រៀបចំដោយព្រះតេជគុណ សន្តត្ថេរ **យ៉េខ់ យ៉ឹម**

ក្រោមការជួយឧបត្ថម្ភថវិកា អំពីសំណាក់ញាតិញោមពុទ្ធបរិស័ទ

នៅសហរដ្ឋអាមេរិក

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៨



www.elibraryofcambodia.org

# វត្តប៉ែលឡាំងវិលៈ

វត្តប៉ែលឡាំងវិលៈ ឋិតនៅក្នុងសង្កាត់ឱហិវលៈ ដែលមានចម្ងាយប្រមាណ២ម៉ៃ (៣.២១៨ គីឡូម៉ែត្រ)ពីផ្លូវប្រសព្វ ឬរង្វង់មូលឱហិវលៈ។ វត្តនេះបានកត់ត្រានៅក្នុងសៀវភៅប្រវត្តិសាស្ត្រជាភាសាសីហឡៈ ឈ្មោះពោធិវង្សថា : កូនមហាពោធិព្រឹក្សមួយដើម បានយកមកដាំនៅក្នុងវត្តនេះ ក្នុងចំណោមកូនពោធិ៍ទាំង ៣២ ដែលគេបានបណ្តុះចេញអំពីមែកមហាពោធិព្រឹក្សនៅនាក្រុងអនុរាធបុរី ដែលភិក្ខុនីសង្ឃមិត្តាបាននាំមកកាន់នគរកោះលង្កា។ ដើមមហាពោធិព្រឹក្សនេះបានដាំនៅក្នុងព្រៃជ្រាស់ ដែលមនុស្សម្នាមិនអាចមើលឃើញ ក៏ប៉ុន្តែនៅឆ្នាំ១៨៥០ មានព្រះថេរៈមួយព្រះអង្គព្រះនាម តិណ្ណោគោទ្ទជេធរ ព្រះអង្គដែលជាអ្នកមានភព្វសំណាង បានរកឃើញនូវដើមមហាពោធិព្រឹក្សនេះមុនគេ។

បច្ចុប្បន្នព្រះគ្រូចៅអធិការ ព្រះអង្គបានកសាងកន្លែងសម្រាប់ធ្វើសក្ការបូជាផ្សេងៗ នៅជុំវិញដើមមហាពោធិព្រឹក្សជាច្រើន និងទីសេនាសនៈសម្រាប់ព្រះសង្ឃគង់ស្នាក់នៅ ព្រមទាំងមានសាលាធម្មសភាផងដែរ។ ពិធីបុណ្យបេរាហារៈ (Esala Perahera) បានចាប់ផ្តើមធ្វើនៅ


www.elibraryofcambodia.org

ថ្ងៃពេញបូណ៌មី ខែអាសាធ តាំងពីឆ្នាំ ១៩៥០ នៅក្នុងវត្តប៉ៃលឡាំង វិលៈ តរៀងមក។



ធម៌រមែងឈ្នះអធម៌

សច្ចបវរឈ្នះពាក្យភូតព្រោង

អំណត់អត់ឱនឈ្នះពាក្យគួចគាង

វេទនាបុណ្យស្រាងឈ្នះអស់អសុរ។


www.elibraryofcambodia.org

# រឿងព្រះកែវមរកត

(ព្រះកែវមរកត ជាមតិករបស់ប្រទេសកម្ពុជា)

ព្រះកែវមរកត កើតឡើងក្នុង ព.ស. ៥០០ កើតដោយអានុភាពរបស់ព្រះនាគសេនត្ថេរ ជាព្រះអរហន្ត ដែលគង់នៅក្នុងអសោការាមនាក្រុងបត្តលីបុត្ត ដែនមគធៈ។ ព្រះអរហន្តអង្គនេះ មានបំណងចង់កសាងព្រះពុទ្ធបដិមា. បំណងនោះក៏បានជ្រាបដល់ព្រះឥន្ទ្រ ទ្រង់ក៏ជ្រះថ្លាក្នុងការកសាងនោះដែរ ទើបត្រាស់ប្រើវិស្សុកម្មទេវបុត្រឱ្យទៅយកកែវមណីជោតិ នៅភ្នំវេបុល្លៈ ដែលពួកកុម្ភណ្ឌថែរក្សា។ ពួកកុម្ភណ្ឌមិនហ៊ានថ្វាយកែវមណីជោតិនោះឡើយ ដោយខ្លាចក្រែង មានស្តេចចក្កពត្រាធិរាជកើតឡើង មិនបានយកកែវមណីជោតិទៅថ្វាយ នឹងបែកក្បាលជាប្រាំពីរភាគ។ វិស្សុកម្មទេវបុត្រ ក៏ត្រឡប់ទៅក្រាបទូលព្រះឥន្ទ្រវិញតាមដំណើរ។ ព្រះឥន្ទ្រកាលបើមិនបាននូវកែវមណីជោតិនោះហើយ ទើបស្តេចយាងទៅកាន់ភ្នំវេបុល្លៈជាមួយនិងវិស្សុកម្មទេវបុត្រ។ ពួកកុម្ភណ្ឌទាំងឡាយ ក៏ក្រាបទូលតាមហេតុដែលថ្វាយមិនបាន។ ព្រះឥន្ទ្របានសួររកកែវដ៏ទៃទៀត ដែលល្អបន្ទាប់ពីកែវមណីជោតិ។ កុម្ភណ្ឌក្រាបទូលថា មានកែវមរកតមួយដុំ ពណ៌ដូចត្រួយចេក នៅបាតភ្នំវេបុល្លៈ


www.elibraryofcambodia.org

ជាកែវឥតម្ចាស់។ ព្រះឥន្ទ្រទ្រង់ប្រើពួកកុម្ភណ្ឌឱ្យទៅយកកែវមកិតនោះ មកថ្វាយ លុះបានហើយ ទើយកទៅប្រគេនព្រះនាគសេនត្ថេរ។ ព្រះថេរៈ មិនអាចរកជាងឆ្លាក់បានឡើយ ព្រោះកែវនោះរឹងពេក។ ព្រះឥន្ទ្របាន ជ្រាបដំណឹងនោះ ទ្រង់បានប្រើវិស្សុកម្មទេវបុត្រ ឱ្យទៅឆ្លាក់ប្រគេន ដោយហេតុថា វិស្សុកម្មទេវបុត្រធ្លាប់បានឃើញព្រះសម្មាសម្ពុទ្ធ កាល គង់ព្រះជន្មនៅឡើយ អាចឆ្លាក់ព្រះពុទ្ធរូបមានលក្ខណៈប្រហាក់ប្រហែល នឹងតួអង្គព្រះសម្មាសម្ពុទ្ធដោយច្រើន។ ព្រះពុទ្ធរូបព្រះកែវមកិតនោះ មានកំពស់ ១ហត្ថ ៧ធ្នាប់ ព្រះភ្នែន ២៣ ធ្នាប់។ ព្រះនាគសេនត្ថេរបាន បញ្ចុះព្រះបរមធាតុ៧អង្គទៅក្នុងព្រះកែវមកិតនោះ គឺបញ្ចុះនូវព្រះសិរ ១អង្គ, ព្រះនលាដ ១អង្គ, ព្រះឧរា ១អង្គ, ព្រះអង្សាស្មាស្តាំ ១អង្គ, ឆ្វេង ១អង្គ, ព្រះជង្ឃស្មងស្តាំ ១អង្គ, ឆ្វេង ១អង្គ។ លុះបានកសាងរួច ស្រេចហើយ ពុទ្ធបរិសទ័ទាំងឡាយមានព្រះនាគសេនត្ថេរជាប្រធាន បានចាត់ចែងធ្វើមណ្ឌប ប្រតិស្ឋានព្រះកែវមកិតនោះនៅក្រុងបត្តលីបុត្ត ហើយមានការសម្ពោធអភិសេកជាឱឡារិក។

តមកក្នុងរជ្ជកាលព្រះបាទសិរិកិត្តិរាជ រវាង ព.ស.១000, ប្រទេស


www.elibraryofcambodia.org

មគធៈ កើតចលាចល បះបោរដណ្តើមរាជសម្បត្តិ, ឯព្រះពុទ្ធសាសនាក៏រារាំងថយចុះជាច្រើន ទើបមានពុទ្ធបរិស័ទមួយក្រុម និមន្តព្រះកែវមរកតចុះសំពៅ បើកសំដៅទៅកោះលង្កា ដោយបំណងយកព្រះកែវមរកតទៅទុកនៅទីនោះ ឱ្យផុតពីកណ្តាប់ដៃពួកជនមិច្ឆាទិដ្ឋិ។ ទៅដល់កោះលង្កា ពុទ្ធបរិស័ទទាំងឡាយមានព្រះមហាក្សត្រ និងព្រះសង្ឃបរិនាយកជាដើម បានទទួលយកព្រះកែវមរកតហែទៅប្រតិស្ឋាននៅវត្តមេឃគិរីមហាវិហារ ដែលជាវត្តសំខាន់បំផុតក្នុងទីក្រុង។ ពេលនោះព្រះពុទ្ធសាសនានៅកោះលង្ការុងរឿងជាងនានាប្រទេស មានគម្ពីរព្រះត្រៃបិដកគ្រប់គ្រាន់បរិបូណ៌ ទាំងបែបជាភាសាបាលី ទាំងភាសាលង្កា។ តមកក្នុង ព.ស. ១៥៦០ ប្រទេសភូមាមានព្រះមហាក្សត្រមួយអង្គព្រះនាមអនុរុទ្ធ ជាអគ្គពុទ្ធសាសនូបត្ថម្ភក៏ ទ្រង់បានជ្រាបថា នៅកោះលង្កាមានព្រះត្រៃបិដកចប់បរិបូណ៌ ទើបទ្រង់ឱ្យគេតាក់តែងសំពៅពីរហើយស្តេចយាងចុះសំពៅទៅលង្កាទ្វីបជាមួយនិងអ្នកប្រាជ្ញច្រើនរូបមានទាំងបព្វជិតទាំងគ្រហស្ថ ដើម្បីចម្លងព្រះត្រៃបិដក។ លុះទៅដល់កោះលង្កាហើយ ស្តេចយាងចូលទៅគាល់ព្រះចៅកោះលង្កា ព្រះនាមលង្កិស្សរាជ។ ព្រះចៅកោះលង្កាទ្រង់បានធ្វើបដិសណ្ឋារៈយ៉ាងខ្ពង់ខ្ពស់


www.elibraryofcambodia.org

លុះទទួលបដិសណ្ឋារកិច្ចរួចហើយ ទើបស្ដេចយាងទៅថ្វាយបង្គំព្រះសង្ឃបរិនាយក នៅនាវត្តមេឃគិរីមហាវិហារ សុំចម្លងព្រះត្រៃបិដកជាភាសាបាលីមួយចប់ ភាសាលង្កាមួយចប់។ លុះចម្លងស្រេចហើយ ព្រះបាទអនុរុទ្ធទ្រង់សុំព្រះកែវមកិតយកទៅប្រតិស្ឋានទុកនៅប្រទេសភូមាជាទីរលឹក។ ព្រះបាទលង្កិស្សររាជ បានថ្វាយព្រះកែវមកិតដល់ព្រះបាទអនុរុទ្ធ តាមសេចក្ដីស្នើសុំ ទើបព្រះបាទអនុរុទ្ធត្រាស់បង្គាប់ឱ្យគេជញ្ជូនព្រះត្រៃបិដកភាសាបាលីដាក់ក្នុងសំពៅមួយ ហើយព្រះត្រៃបិដកភាសាលង្កា និងព្រះកែវមកិតដាក់ក្នុងសំពៅមួយ ចំណែកព្រះអង្គគង់សំពៅដែលដាក់ព្រះត្រៃបិដកភាសាបាលី។ សំពៅទាំងពីរបានបើកចេញពីកោះលង្កា សំដៅទៅប្រទេសភូមា ដល់ពាក់កណ្ដាលមហាសាគរ សំពៅដែលតម្កល់ព្រះត្រៃបិដកភាសាលង្កា និងព្រះកែវមកិត ត្រូវខ្យល់បោកបក់រសាត់មកជាប់នៅត្រើយសមុទ្រ ត្រង់ជាយខេត្តបន្ទាយមាសនៃប្រទេសកម្ពុជាភាគខាងត្បូង។ រាជការខេត្តបន្ទាយមាសចាប់សំពៅនោះបាន ទើបនាំយកគម្ពីរព្រះត្រៃបិដកនិងព្រះកែវមកិត ទៅថ្វាយព្រះបាទសុរិយវរ្ម័នទី១ នៅក្រុងស្រីសោធរបុរៈ។ ស្ដេចទ្រង់ទតឃើញព្រះកែវមកិតនោះហើយ ទ្រង់សោមនស្សណាស់ បានឱ្យគេសាងវិហារមួយ


www.elibraryofcambodia.org

តម្កល់ទុកខាងក្នុងព្រះបរមរាជវាំង ។ ថ្ងៃក្រោយព្រះបាទអនុរុទ្ធបានជ្រាប ដំណឹង ទើបប្រើរាជបំរើឱ្យនាំរាជសាររមកសុំយករបស់ទាំងនោះទៅវិញ ។ ព្រះបាទសុរិយវរ្ម័នទី១ បានប្រគល់តែព្រះត្រៃបិដកឱ្យវិញ ទ្រង់ទុកព្រះកែវមរកត ពុំបានថ្វាយដល់ព្រះបាទអនុរុទ្ធព្រះចៅភូមាឡើយ ព្រោះទ្រង់សព្វព្រះរាជហឫទ័យសោមនស្សជ្រះថ្លា ចំពោះព្រះកែវមរកតក្រៃពេក ។ ព្រះកែវមរកត ក៏បានមកជាមរកតប្រទេសកម្ពុជាក្នុងវេលានោះដោយសិរី ឥតបានដឹងបានប្រាថ្នា ឬសុំអំពីសំណាក់បុគ្គលណាឡើយ ។


www.elibraryofcambodia.org

# ដំណើរធម្មយាត្រាទៅកាន់ប្រទេសស្រីលង្កា

ស្រុកស្រីលង្កាសំបូរបុណ្យ ទឹកដីអរហន្តលោកគង់នៅ
ព្រះពុទ្ធក៏ទ្រង់ធ្លាប់យាងទៅ ភ្នំខ្ពស់ជ្រោះជ្រៅត្រជាក់ចិត្ត ។
តែទីដែលគួរឱ្យជ្រះថ្លា គឺព្រះសាស្ដាស្ដេចអាណិត
បន្សល់ព្រះធាតុថ្លៃពិត១ ឱ្យពុទ្ធបរិស័ទទាំងប្រុសស្រី ។
បានថ្វាយបង្គំធាតុពីរនាទី ក្នុងសុវណ្ណមាលិកចេតិយ
បង្កើតសទ្ធាទាំងយប់ថ្ងៃ ដោយឧបនិស្ស័យផ្សំពីមុន ។
កាលឃើញព្រះស្រីពោធិព្រឹក្ស ដាក់ចិត្តឱ្យនឹកព្រះមានបុណ្យ
ទ្រង់មានករុណាបញ្ញាគុណ វិសុទ្ធិគុណប្រៀបពុំបាន ។
ពេលថ្វាយបង្គំព្រះនលាដ ឧណ្ហីសធាតុដ៏ថ្កើងថ្កាន
ហាក់ដូចអណ្តែតផុតពីស្ថាន ព្រោះមិននឹកស្មានបានមកដល់ ។
ទាំងអក្ខកធាតុថ្លៃបវរ ព្រះកេសធាតុក៏ក្របានយល់
អ្នកជួបពិតជាបុណ្យឱ្យផល ដែលមហាកុសលកើតព្រោះហេតុ ។
ពុទ្ធស្ថានពិសេសមានមួយទៀត គឺព្រះទន្តធាតុល្អត្រដែត
គង់ក្នុងកោដ្ឋមាសខ្ពស់មួយម៉ែត្រ វន្ទាមិនឆ្អែតទេម្ចាស់ថ្លៃ ។
ដំបូលប្រក់មាសល្អអស្ចារ្យ ពិតានមានផ្កាម្លៃប្រាំបី
ធ្វើពីមាសសុទ្ធរុងរឿងក្រៃ រចនាដោយដៃជាងប្រណិត ។


www.elibraryofcambodia.org

ជាទីសក្ការៈបូជា
តម្កល់ទន្ទាព្រះទ្រង់ឫទ្ធិ
ចង្ក្រមស្តាំក្រោមល្អពេកពិត
ភ្លឺផ្លេកវិចិត្រដូចផ្កាយព្រឹក ។
ទីដែលបរិស័ទចាំរហូត
ភ្នំសុមនកូដល្អពន្លឹក
ខ្ពស់មែនតែនៅចាញ់ចិត្តនឹក
រលឹកដល់ស្នាមព្រះបាទថ្លៃ ។
មនុស្សម្នាជាច្រើនទាំងក្មេងចាស់
តស៊ូខ្លាំងណាស់ប្រឹងយប់ថ្ងៃ
អ្នកខ្លះវារឡើងពាក់ស្រោមដៃ
គិតថាទោះក្ស័យក៏មិនស្តាយ ។
ចំនែកជនជាតិស្រីលង្កា
ស្រែកនមស្សការពីចម្ងាយ
ជាមួយពួកយើងយ៉ាងសប្បាយ
ថាគេមកថ្វាយបង្គំព្រះ ។
បរិស័ទខ្មែរយើងពឹងឈើច្រត់
បើសិនបើអត់មុខជាស្ទះ
មិនងាយឡើងទេព្រះគុណម្ចាស់
ព្រោះភ្នំខ្ពស់ណាស់កប់វេហាស៍ ។
ពេលឡើងទៅដល់ចិត្តល្អស្អាត
វន្ទាព្រះបាទដោយជ្រះថ្លា
ក្រាបថ្វាយបង្គំដល់សិរសា
លើស្នាមបាទាព្រះពុទ្ធថ្លៃ ។
យប់នោះត្រជាក់ធ្លាក់សន្សើម
រងាររញ្ជួរថ្មើមអាសូរក្រៃ
ដល់ជនគ្មានទីស្នាក់អាស្រ័យ
សំរាកផ្ទាល់ដីឥតអ្វីបាំង ។
ពួកយើងជ្រៀតណែនក្នុងបន្ទប់
គង់គេងលក់ស៊ប់ព្រោះងុយខ្លាំង
ណាមួយឡើងភ្នំអស់កំលាំង
ចាំតែភ្លឺស្រាងនឹងអាលងើប ។
ទៅថ្វាយបង្គំព្រះបាទា
ពេលនមស្សការចិត្តរំភើប
ត្រេកអរសប្បាយហាក់ដូចទើប
ងើបពីស្ថានក្រោមមកសួគ៌ា ។


www.elibraryofcambodia.org

ពេលនោះអរុណចាំងរស្មី　　បច្ចូសសម័យយើងនាំគ្នា
ឈរចាំគោរពស្ទូត្រវន្ទា　　បែរទៅបូព៌ាទិសថ្ងៃរះ ។
តមកជនជាតិស្រីលង្កា　　ប្រទក្សិណបូជាដៃសំពះ
គោរពលើកទូលចង្ហាន់ព្រះ　　ថ្វាយចំពោះម្ចាស់ដ៏មានគុណ ។
តាំងពីព្រះអង្គចូលនិព្វាន　　បរិស័ទថ្វាយទានជាប់និរន្តរ៍
រស្មីពុទ្ធសករាជជាងពីរពាន់　　គិតទាំងក្រោយមុនរាល់៧ថ្ងៃ ។
ចុងក្រោយឱនកាយថ្វាយបង្គំ　　លាទីឧត្តមបាទាថ្លៃ
រូបកាយឆ្ងាយពិតចិត្តអាល័យ　　មិនដឹងមានថ្ងៃណាជួបទៀត ។
ម្ចាស់អើយទោះបីឃើញតែស្នាម　　ចិត្តនឹកដឹតដាមមិនរវាត
សូមជួបត្រៃរ័ត្នគ្រប់៧ជាតិ　　កុំបីឃ្លៀងឃ្លាតខុសប្រាថ្នា ។
ពេលចុះពីភ្នំក៏ដូចឡើង　　ឈឺចុកដៃជើងសព្វកាយា
ប៉ុន្តែកំលាំងចិត្តជ្រះថ្លា　　សប្បាយអស្ចារ្យភ្លេចឈឺចាប់ ។
យើងលាកូឡំបូចេញឆ្ងាយហើយ　　រាត្រីចុងក្រោយហាក់ផ្តាំប្រាប់
ឱ្យនឹកលង្កាមហាកំណប់　　នឹកយប់ចុះអ័ព្ទពេលឡើងភ្នំ ។
ពីថ្ងៃនេះទៅទោះនៅឆ្ងាយ　　វាចាចិត្តកាយខំបន្ទំ
ព្យាយាមស្តាប់ធម៌ហើយអប់រំ　　ធ្វើទានសីលផ្សំបូជាព្រះ ។

ដោយឧបាសិកា **ខិម លក្ខិណា**

www.elibraryofcambodia.org

# ស្តាយណាស់

(ពេលបានទៅដល់ព្រះពុទ្ធស្ថាន)

ស្តាយអើយសែនស្តាយ ខំស្តាត់ពីឆ្ងាយ មករកព្រះអង្គ
តែពុំបានជួប ដូចចិត្តដែលចង់ ត្បិតអីព្រះអង្គ
ទ្រង់និព្វានហើយ ។

ស្តាយអើយសែនស្តាយ ពីនាយដល់អាយ កាយចិត្តឥតស្បើយ
ទោះព្រះអានន្ទ ក៏ពុំឃើញឡើយ ព្រះគុណម្ចាស់អើយ
និមន្តទៅណា ។

ស្តាយអើយសែនស្តាយ យើងខ្ញុំទាំងឡាយ មានចិត្តជ្រះថ្លា
ចង់ឃើញសាវ័ក ជាក់នឹងនេត្រា តែក្តីប្រាថ្នា
ត្រូវអសារបង់ ។

ស្តាយអើយសែនស្តាយ កុដិវត្តទាំងឡាយ ពុំឃើញព្រះសង្ឃ
ឃើញតែស្នាមគ្រឹះ កម្ទេចសំណង់ ចិត្តស្លុតត្រយង់
ស្រយុតអង្គប្រាណ ។

តែទោះយ៉ាងណា ត្រូវយល់ដឹងថា លាភធំដែលបាន
មកដល់កន្លែង នៃព្រះពុទ្ធស្ថាន ព្រះអង្គធ្លាប់បាន
គង់អាស្រ័យនៅ ។

www.elibraryofcambodia.org

សូមថ្វាយបង្គំ ពុទ្ធស្ថានលើភ្នំ និគមព្រៃជ្រៅ
ដែលព្រះអង្គធ្លាប់ គង់អាស្រ័យនៅ ទោះជាខ្ញុំទៅ
មិនដល់ក៏ដោយ ។

សូមមហាកុសល ដែលបានតម្កល់ ទុកក្នុងចិត្តហើយ
សូមជួយរុញច្រាន ឆាប់បានដល់ត្រើយ កុំបីខានឡើយ
ដូចក្តីប្រាថ្នា ។

សូមឧទ្ទិសផល គោរពជូនដល់ មាតាបិតា
ដល់ញាតិសន្តាន ក្នុងវដ្តសង្សារ ទាំងគ្រូអាចារ្យ
ឧបជ្ឈាយ៍ទាំងឡាយ ។

ទោះរស់ជុំញាតិ ឬស្លាប់បែកឃ្លាត ចាប់ជាតិជិតឆ្ងាយ
សូមបានអាហារ បរិក្ខារទាំងឡាយ រីករាយសប្បាយ
នឹងបុណ្យកុសល ។

ដែលយើងខ្ញុំបាន ធ្វើទាំងប៉ុន្មាន ឧទ្ទិសជូនដល់
សូមឱ្យបានសុខ ផុតទុក្ខកង្វល់ សូមបានមគ្គផល
ដល់ព្រះនិព្វាន ។

ដោយឧបាសក : **គុយ សុធន**


www.elibraryofcambodia.org

សូម ក្រាប បង្គំ ប្រណម្យ វន្ទា
ឆ្ពោះ ព្រះភគវា ពុទ្ធា បានត្រាស់
ធម្មនិយាម ទំនៀម ល្អល្អះ
សាមសិបមុខច្បាស់ ខ្ញុំសូមពណ៌នា។

**មួយ** រញ្ជួយភពជាតិគ្រប់ចុងក្រោយ
បារមី នាំឱ្យ ដឹង ពេលវេលា
ទ្រង់ យាង កាន់ផ្ទៃ ស្មារតី ល្អជា
ដឹងខ្លួន គ្រប់គ្រា ក្នុង គភ៌មាតា។

**ពីរ** គឺព្រះភ័ក្ត្រ វរល័ក្ខណ៍ ក្នុងគភ៌
ស្ថិតស្ថាធី ក្នុង ធមិ បវរ កាយា
ព្រះភ័ក្ត្រ បែរ ផ្ទុយ ពីខ្នង មាតា
ឆ្ពោះ ផ្ទៃ ភ្លឺថ្លា មាតា រំពៃ។

**បី** ឥរិយាបថ នៃ ព្រះមាតា
ពេល គ្រប់ មាសា សាស្តា ចាក ផ្ទៃ
មាតា ទ្រង់ឈរ ខុសស្រី ដទៃ


www.elibraryofcambodia.org

ប្រសូត បុត្រថ្លៃ ឬទ័យ ជ្រះថ្លា។

**ប្អូន** សួន ឧទ្យាន ទីឋាន ប្រសូត

ក្នុងព្រៃ រហូត ឈើស្រួត ចេញផ្កា

ទេវតា និង មនុស្ស ថ្វាយ សាធុកា

ចក្រវាឡ បញ្ចតា ខ្ទររខ្ទារ អឺអរ។

**ឃាំ** ព្រះប្រសូតចុះស្រួតយាងឈាន

ប្រាំពីរ ជំហាន ឆ្ពោះ ទិស ឧត្តរ

ត្រួត គ្រប់ ទិស ឋាន ក្លាហាន បវរ

ទើប បាន បន្ត បន្លឺ សីហនាទ។

**ឆ្នាំមួយ** ប្រមើល ទត មើលនិមិត្ត

ទេវទូត បួនពិត ចិត្តគិត លះញាតិ

បុត្រកើត ថ្ងៃណា ថ្ងៃនោះ ទ្រង់ឃ្លាត

ចិត្តឥត រវាត យាត្រា សាង ផ្នួស។

**ឆ្នាំពីរ** ធីរោ ផ្តាច់ បួរ ព្យាយាម

ឥតមាន ទាក់ទាម ក្នុងនាម អ្នកបួស

កំណត់ វេលា មិន អាច តិច ហួស


www.elibraryofcambodia.org

ប្រាំពីរ ថ្ងៃ នោះ នឹងបាន ត្រាស់ដឹង ។

**ឆ្នាំបី** មហេសី គង់សោយ បាយាស

ក្នុងថ្ងៃ បានត្រាស់ ទ្រង់ ច្បាស់ ទីពឹង

បាយាស ថាសមាស ថ្វាយព្រះថ្ងៃហ្នឹង

ហៅបាយត្រាស់ដឹងបានបុណ្យមហិមា ។

**ឆ្នាំបួន** ជូនភ័ព្វទ្រង់ទ្រាប់ ស្បូវភ្លាំង

ក្លាយ ជា បល្ល័ង្ក គង់ តាំង ភាវនា

នៅ គល់ ពោធិព្រឹក្ស នា ទិស បូពា

ទេពធីតា មារ មក គ្រា សាយ័ណ្ហ ។

**ជប់** គាប់ ហឫទ័យ អានាបាណៈ

បរិកម្ម ប្រចក្ស សតិ ដឹង ទាន់

ខ្យល់ចេញខ្យល់ចូល ចិត្តមូលមិនភាន់

ដំណើរ ជវ៉ន ជាន់ ឆ្លង កាមា ។

**ជប់មួយ** ជំនួយ ពី ព្រះ បារមី

ផ្ចាញ់ មារ អប្រិយ៍ ព្រមទាំង សេនា

ពុទ្ធប្បវត្តិ ត្រង់ នេះ អស្ចារ្យ



www.elibraryofcambodia.org

បរិស័ទ ជ្រះថ្លា បាចផ្កា អភិសេក។
**ជប់ពីរ** មុនីអង្គ ទ្រង់សម្រេចញាណ
ត្រៃវិជ្ជា មាន ទ្រង់ញាណ អនេក
ពិសាខ បុណ្ណមី កើត ញាណ ប្លែកៗ
ពោធិញ្ញាណ ខ្ពស់ឯក កក្រើក ធរណី។
**ជប់បី** ក្សត្រ ថ្លៃ គង់ ក្នុង មហាឋាន
វិមុត្តិ ក្សេមក្សាន្ត អស់ឋាន ប្រាំពីរ
សប្តាហ៍ ឋានមួយ លើក ស្ទួយ ស្ថានទី
ចេតិយ ព្រះមុនី ប្រាំពីរ កន្លែង។
**ជប់បួន** ជូន ព្រហ្ម ជុំ អារាធនា
សូម ព្រះភគវា យាង ត្រាស់ សំដែង
ព្រះធម៌ ប្រពៃ វិស័យ សូរ្យសែង
ទ្រង់ ព្រមសំដែង ដោយ ព្រហ្មវិហារ។
**ជប់ប្រាំ** ចាំច្បាស់ ទ្រង់ត្រាស់ ធម្មចក្ក
ឥសិ បតនៈ ព្រៃ មិគទា
ឋាន ត្រៃ រតនៈ អាសាឡ្ហៈ បូជា


www.elibraryofcambodia.org

ថ្ងៃ ព្រះភគវា ស្ថាបនា ព្រះសង្ឃ។

**ដប់ឆ្នាំមួយ** ទ្រង់ គង់ ត្រាស់ ឱវាទ

បាតិមោក្ខ ស្អាងស្អាត ឱវាទ ផ្លូវផង់

បេះ ដូង ព្រះធម៌ ពន្លឺ ចតុរង្គ

ថ្ងៃ នោះ ត្រូវ ត្រង់ មាឃបុណ្ណមី។

**ដប់ឆ្នាំពីរ** ទ្រង់ គង់ វត្ត ជេតពន

ប្រោស ដល់ មហាជន និរន្តរ៍ ប្រក្រតី

ទ្រង់ យក អរុណ ជេតពន សួស្តី

ជេតពន ជិនស្រី អាស្រ័យ ជានិច្ច។

**ដប់ឆ្នាំបី** ទ្រង់ សំដែង បាដិហារ្យ

យមកៈ អស្ចារ្យ និគ្រន្ថ វត់គេច

នៅ ក្រុង សាវត្ថី ប្រុសស្រី មានតិច

នេះ គឺ ពុទ្ធកិច្ច សង្គ្រោះ លោកា។

**ដប់ឆ្នាំបួន** ទ្រង់ គង់ ឋានត្រៃត្រិង្ស

ត្រិះរិះ រំពឹង ថ្លឹង គុណ មាតា

សម្តែង អភិធម្ម ស័ក្តិសម អស្ចារ្យ



www.elibraryofcambodia.org

ថ្វាយ ព្រះមាតា សុខា អមតៈ។

**ថ្ងៃ** គឺ ព្រះអង្គ ទ្រង់ ចាក ទេវលោក
ស្ដេច យាង ចុះ មក ដែន សង្កស្សៈ
មហាជន ច្រើនពិត យកចិត្ត ទុកដាក់
បូជា គារវៈ អចលចេតិយ។

**ថ្ងៃមួយ** គឺ ទ្រង់ គង់ ក្នុង សមាបត្តិ
ព្រះញាណ ស្ងប់ស្ងាត់ លះកាត់លោកិយ៍
អរហត្តផល តម្កល់ ប្រក្រតី
ឆាប់ក្តី យូរក្តី វិស័យ ពុទ្ធញ្ញាណ។

**ថ្ងៃពីរ** ប្រមើល មើល គ្រប់ វេនេយ្យ
ឧបនិស្ស័យ សព្វ សត្វ ដែល មាន
ដោយ ព្រះករុណា សមាបត្តិញ្ញាណ
ត្រួត សត្វ កោដិលាន មាន ពីរ វារៈ។

**ថ្ងៃបី** ទ្រង់ លៃ វិន័យ អាជ្ញា
បញ្ញត្ត សិក្ខា តាមការ ជ្រាប ជាក់
មានរឿង កើតមុន ខូចគុណ សាវ័ក


www.elibraryofcambodia.org

មានហេតុ ជាក់លាក់ ទើបដាក់ វិន័យ ។

**ម្ភៃបួន** អង្រួន ហឫទ័យ ករុណា
ជាតក ទេសនា សាស្តា លកលៃ
ដើម រឿង ជាហេតុ បង្កើត អត្ថន័យ
ជាតក ប្រពៃ លៃ តាម ហេតុការណ៍ ។

**ម្ភៃប្រាំ** ទ្រង់ ប្រោសដល់ ពួកព្រះញាតិ
អង្គ ព្រះលោកនាថ សម្តែង បាដិហារ្យ
កម្ចាត់ មានះ ព្រះញាតិ វង្សា
ទើប ត្រាស់ ទេសនា គម្ពីរ ពុទ្ធវង្ស ។

**ម្ភៃប្រាំមួយ** ទ្រង់ គង់ ធ្ងន់ ក្នុង ធម៌
បរិស័ទ ណា ល្អ មាន ធម៌ ទ្រទ្រង់
ស្តេចយាង ទទួល ស្រុះស្រួល ដោយអង្គ
គារវៈ ផ្ចូរផង់ ឆ្ពោះ ត្រង់ ព្រះធម៌ ។

**ម្ភៃប្រាំពីរ** ទ្រង់ គង់ ចាំ វស្សា
បើ មាន នរណា និមន្ត ដោយល្អ
ពេល ចេញ វស្សា មុនយាង ចេញចរ

www.elibraryofcambodia.org

ទ្រង់ ចំរើនពរ ត្រាស់ លា អ្នក នោះ
**ម្ភៃប្រាំបី** ទ្រង់ គង់ យ៉ាង ហ្មត់ចត់
មុនភត្ត ក្រោយភត្ត គ្មាន ភ្លាត់ភ្លេចសោះ
បំពេញ ពុទ្ធកិច្ច គ្រប់ យាម ទាំងអស់
ពុទ្ធកិច្ច សង្គ្រោះ មនុស្ស និង ទេវតា។
**ម្ភៃប្រាំបួន** ទ្រង់ គង់ សោយ មំសៈ
ក្នុង ថ្ងៃ ទ្រង់ ដាក់ អនុដ្ឋាន កាយា
បិណ្ឌបាត ចុងក្រោយ ជាទាន ថ្លៃថ្លា
សោយ រស មំសា ហឫទ័យ បរិសុទ្ធ។
**សាមសិប** អវសាន ទ្រង់បាន ចូលឈាន
មុន នឹង និព្វាន ឈាន ច្រើន បំផុត
ម្ភៃបួន សែនកោដិ សមាបត្តិ បរិសុទ្ធ
រួចហើយ ទ្រង់ផុត រលត់ សង្ខារ។
**អហំ** វី ខ្ញុំ បង្គំ វន្ទា
ឆ្ពោះ ព្រះភគវា ព្រះធម៌ ថ្លៃថ្លា
ព្រម ទាំង ព្រះសង្ឃ ផ្ទូវផង់ សីលា


www.elibraryofcambodia.org

ចិន្តា    លំអុត      ព្រះពុទ្ធ  និយាម។
សូម  ឱ្យសព្វ  សត្វ  បដិបត្តិតាមធម៌
សាសនា   បវរ   ល្អ  ដូច  ព្រះនាម
អរហំ  សម្មា  គ្មាន  ការ  ទាក់ទាម
កិលេស  វវាម  វវាត   សូន្យបង់។
សូម   ឱ្យ   សាសនា   សម្មាសម្ពុទ្ធ
បរិស័ទ  មោះមុត  រួមចិត្ត   ទ្រទ្រង់
ឋិតថេរ ចិរកាល -អភិបាល ដោយសង្ឃ
ព្រមព្រៀង  ស្មោះត្រង់  ផ្ចិតផ្ចង់សិក្ខា។
សូម  មនុស្ស  ទេវតា មាន  ការគោរព
ទាំងថ្ងៃ    ទាំងយប់  ក្នុងព្រះសាសនា
សូម   បាន  សម្រេច  ដូចក្តី  ប្រាថ្នា
អស់ នូវ  តណ្ហា  ទុក្ខា   ចប់ហោង។


www.elibraryofcambodia.org

# បទសរភញ្ញ

១-សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិង ទេវា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។
ចង្អុលឱ្យដើរផ្លូវកណ្ដាល មាគ៌ាត្រកាលអាចកំចាត់
ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់ អាចកាត់សង្សារៈទុក្ខបាន ។
២-សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបុរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន កាន់តាមលំអានបានក្ដីសុខ ។
ឥតមានសុខណា ស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្ដីសុខនឹងមានព្រោះធម៌ស្ងប់ ។
៣-ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្នគួរគោរព ជាម្លប់ត្រជាក់ នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្ដា
សូមគុណត្រៃរ័ត្នជួយខេមរា ឱ្យបានសុខាតរៀងទៅ ។

ព្រះរាជនិពន្ធដោយ សម្ដេចព្រះសង្ឃរាជ **ជួន ណាត**

www.elibraryofcambodia.org

# បទលើកទង់ព្រះពុទ្ធសាសនា

១-សូមលើកទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវ លឿង ក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ភ្លឺផ្លេក។
២-ប្រទេសតូចធំ បានស្ម័គ្រស្មាគម ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង។
៣-ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃសម្ពុទ្ធធំចំបង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់។
៤-ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា។
៥-សូមសាសនាពុទ្ធ ថ្កុំថ្កើងបំផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លាច្រើនសែនលាន។
៦-មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្ដីសុខ។
៧-យើងខេមរៈជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តត្រាណ។
៨-ព្រមព្រៀងប្រព្រឹត្ត តាមធម៌សុចរិត ឆ្ពោះទៅកាន់ឋាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា។

www.elibraryofcambodia.org

# បទជាក់ទង់ជ័យព្រះពុទ្ធសាសនា

១-ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
២-ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងរិទ្ធិរុង្គប្រសើរបវរ
ឆ្មៀលឆ្វាតកាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
៣-កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ ។
៤-រស្មីពណ៌ខៀវនោះណា កាលឆ្មៀលនេត្រាទ្រង់ដោយចិត្តកាត់
ឱ្យទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីភិរាស្ត្រ ។
៥-រស្មីពណ៌លឿងភ្លឺថ្លា កាលដែលទ្រង់អារសាច់ផៃធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទជាងមាសទ្រង់វ៉ៃយបណ្ឌិត ។
៦-រស្មីក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា ។
៧-រស្មីពណ៌សសុទ្ធសាធ កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យទានដីរសសោភា ដែលព្រះប្រាថ្នារកពោធិញ្ញាណ ។
៨-រស្មីពណ៌ដូចជើងហង្ស កាលមាតាទ្រង់យក្សចាប់យកបាន

www.elibraryofcambodia.org

ពិទ្យាធរអារសាច់ខ្លួនប្រាណ ឱ្យយក្សសាមាន្យស៊ីប្តូរជីវិត ។
៩-រស្មីពណ៌ផ្លេកពណ្ណរាណ កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
១០-រស្មីខៀវលឿងក្រហម ស ហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចងចាំទុកអើយ ។

www.elibraryofcambodia.org

# ឯកសារយោង


១- Mahavamsa The Great Chronicle Of Ceylon Translated by Wilhelm Geiger,Ph.D. Published by Buddhist Cultural Centre – Sri Lanka 1912 (ISBN 955-8540-83-8).

២- Sri Lanka Pilgrim's Guide. Written by Kirama Wimalajothi Thero. Published by Buddhist Cultural Centre – Sri Lanka 2000 (ISBN 955-8129-38-0)

៣- Famous Kings Of Sri Lanka. Written by K. Samaranayake. Published by The Author – All rights reserved 2004 (ISBN 955-98890-0-1).

៤- The Tooth Relic and The Crown. Written by Dharmaratna Herath. First Published in 1994 Printed by Gunaratne Offset Ltd. Colombo 10. (ISBN 955-95663-0-X).

៥- Sigiriya Kassapa's Homage to Beauty. By Siri Gunasinghe. First Edition March 2008 Printed by Tharanjee Prints, Sri Lanka. (ISBN 978-955-665-004-4 and hardback ISBN 978-955-665-003-7).

៦- Sketches Of Ceylon History. By P. Arunachalam . Printed and Published by M.D. Gunasena &Co. Ltd P- 3267-08/2008. (ISBN 955-21-1255-9).

៧- The Sinhalese Written by Dr. Nanadadeva Wijesekera. Published by M.D. Gunasena &Co. Ltd 1990 (ISBN-955-21-0439-4/2).

៨- Some notes got from Sri Lanka Website


www.elibraryofcambodia.org

៩-MP3 Lok kru's (But Savong) Tripe to Sri Lanka 2007. From website www.Dhamma4khmers.Org

១០-ប្រជុំនិទានជាតក ដោយសិទ្ធត្ថបណ្ឌិត សុង ស៊ីវ រៀបរៀងជាមួយ ព្រះមហា សំ សុក សាស្ត្រាចារ្យសាលាបាលីវត្តលង្កា (បោះពុម្ពលើកទី ២) ព.ស ២៥០៥ គ.ស ១៩៦២។

១១-កំណាព្យ ចម្លងចេញពីសៀវភៅ ព្រះពុទ្ធ ២៨ ព្រះអង្គ វេមត្តកថា "សម្តែងដោយ អគ្គបណ្ឌិត ប៊ុត សាវង្ស" ថ្ងៃ ៨រោច ខែស្រាពណ៍ ឆ្នាំ កុរ ព.ស ២៥៥១។

១២-ប្រជុំភាណវារៈ

www.elibraryofcambodia.org

# នាមសប្បុរសជនដែលបានជួយឧបត្ថម្ភក្នុង
# ការបោះពុម្ពសៀវភៅ

០១-ភិក្ខុផុន សាបាន ..........................................២៥០០ រូពី

០២-ភិក្ខុ អ៊ុយ សុភាព..........................................៣៥០០ រូពី

០៣-ភិក្ខុ ថៅង ពេជ្រ ..........................................៣០០០ រូពី

០៤-ភិក្ខុ ខាត់ ប៊ុនថាយ ..........................................៣០០០ រូពី

០៥-ភិក្ខុ សាយ ប៊ុនថុន ..........................................២០ ដុល្លារ

០៦-ភិក្ខុ វ៉ាន់ ស្រៀង ..........................................២០០០ រូពី

០៧-ភិក្ខុ ណែម ធារ៉ា..........................................៣០០០ រូពី

០៨-សាមណេរ វង្ស សុច័ន្ទ..........................................២០០០ រូពី

០៩-សាមណេរ យ៉ត សុវណ្ណរ័ត្ន..........................................៣០០០ រូពី

១០-សាមណេរ តុប ថេង ..........................................៣០០០ រូពី

១១-សាមណេរ ស្វែង ដែន..........................................៥០០០ រូពី

១២-សាមណេរ ទេព សាន់សុគង.......................................... ២៥០០ រូពី

១៣-គ្រូធម្មាចារ្យ អឿ សៅ..........................................១០០ ដុល្លារ

១៤-ឧបាសក វង់ ម៉ៅ និង ឧបាសិកា ឆាន់ កាន់ជួង .........១០០ ដុល្លារ

www.elibraryofcambodia.org

១៥-ឧបាសិកា លី ឈុនលេក ........................................១០០ ដុល្លារ

១៦-ឧ.សិ ស្រ៊ុន គីមចេង និង ឧ.សិ ហួន ណៃត...............១០០ ដុល្លារ

១៧-ឧ.សិ សេង សៀង ឈុន និង គ្រួសារ .....................២០០ ដុល្លារ

១៨-ឧ.ស ឡូ ប៊ុនឡេង និង ឧ.សិ អៀប ឆៃគីម............២០០ ដុល្លារ

១៩-ឧ.សិ ភន ស៊ាងហៃ ............................................២៥០ ដុល្លារ

២០-ឧ.សិ យ៉ឹម ម៉ាស៊ី ..................................................២៥០ ដុល្លារ

២១-ឧ.សិ ថាច់ ទីវ៉ាន់នី និង ឧ.សិ កែវ ស៊ីន....................៥០ ដុល្លារ

២២-ឧ.សិ តាំង គីមលាង ព្រមទាំងបុត្រ........................៥០ ដុល្លារ

២៣-អ្នកស្រី ស៊ូ ស៊ីសេង ពេជ្រចិន្តា និងបុត្រ .................៥០ ដុល្លារ

២៤-ឧ.សិ តាន់ គីមថាន់ និង ឧ.សិ អាំង លានហ៊ី...........១២៥ ដុល្លារ

២៥-ឧ.ស នេត ហេង ឧ.សិ ឱម សង្វាន ព្រមទាំងបុត្រ....១២៥ ដុល្លារ

២៦-ឧ.សិ ជា រិន ព្រមទាំងបុត្រ ....................................១០០០០៛

២៧-ឧ.ស ជា ផាត និង ឧ.សិ ឯម ពុំ ព្រមទាំងបុត្រ.......... ១៥០០០៛

២៨-ព្រះគ្រូ អ៊ុក ប៊ុនធូន ចៅអធិការ វត្តក្រាំងល្វា..........១០០ ដុល្លារ

២៩-ភិក្ខុ. នឿ សុទ្ធិ........................................................ ២០០០០៛

៣០-សាមណេរ ហុង ស៊ីថា...............................................៥០០០៛

៣១-សាមណេរ កុយ សុផង់........................................... ១០០០០៛

www.elibraryofcambodia.org

៣២-សាមណេរ ជេត សុផល.......................................... ៥០០០៛

៣៣-សាមណេរ កុយ វាសនា.......................................... ១០០០០៛

៣៤-សាមណេរ ផុន ភារុន.......................................... ១០០០០៛

៣៥-សាមណេរ ខ្លួង សុវណ្ណា.......................................... ២០០០០៛

៣៦-សាមណេរ ហោ ពន្លក.......................................... ២០០០០៛

៣៧-សាមណេរ ជន លៀង.......................................... ៥០០០៛

៣៨-សាមណេរ ណុប វណ្ណៈ.......................................... ៥០០០៛

៣៩-សាមណេរ ស៊ុន ពុធ.......................................... ៧០០០៛

៤០-សាមណេរ តន រីម.......................................... ៥០០០៛

៤១-សាមណេរ យ៉ត ថេរានី.......................................... ២០០០០៛

៤២-សាមណេរ មី ផានិត.......................................... ២០០០៛

៤៣-សាមណេរ ធ្លូក សុគុណ.......................................... ៥០០០៛

៤៤-ភិក្ខុ មែតថៃ.......................................... ៥០០០៛

៤៥-ភិក្ខុ ញ៉ាញ់ លីម.......................................... ៣០០០៛

៤៦-ភិក្ខុ ញិល ចាន់.......................................... .១០០០០៛

៤៧-ភិក្ខុ ឡោម ប៊ុនយ៉ុង.......................................... ៥០០០៛

៤៨-សាមណេរ ស៊ុន ឡេន.......................................... ៥០០០៛

www.elibraryofcambodia.org

៤៩-ភិក្ខុ វ៉ែន ភារុន........................................................ ៥000៛

៥0-ភិក្ខុ ទីង ទ្រៀវ................................................. ១0000៛

៥១-ឧ.សិ ទន់ វឿន................................................. ១0000៛

៥២-ឧ.សិ អ៊ុន រីម..................................................... ២000៛

៥៣-ឧ.សិ កឹម ឈៀង.................................................. ២000៛

៥៤-ឧ.សិ ឆែម រិត........................................................ ៥000៛

៥៥-ឧ.សិ ម៉ុច មន.................................................... . ២000៛

៥៦-ឧ.សិ ម៉ុល សៀក.................................................. ៥000៛

៥៧-ឧ.សិ កែវ បឿន................................................. ១0000៛

៥៨-ឧ.សិ ម៉ុច សាម៉េត................................................ ២000៛

៥៩-ឧ.សិ ឈុន ហួត.................................................... ៤000៛

៦0-ឧ.សិ ជួន ផាន.................................................... ១0000៛

៦១-ឧ.ស អ៊ួង អ៊ិន.................................................... ២000៛

៦២-ឧ.ស សៅ គៀត.................................................... ១000៛

៦៣-ឧ.ស បិន និង ឧ.សិ ផុន........................................ ៥000៛

៦៤-ឧ.ស អឿន និង ឧ.សិ រី........................................ ១000៛

៦៥-ម៉េង យ៉ាប់......................................................... ៥000៛

www.elibraryofcambodia.org

៦៦-គឹម ផូ............................................................ ១០០០៛

៦៧-រ័ទ្ធ ម៉ុន............................................................ ១៥០០៛

៦៨-ណយ ហ៊ុន............................................................ ៥០០០៛

៦៩-លោក សេង ស្ថាពរ និង អ្នកស្រី ណាត សុធា............ ៤៣០០០៛

៧០-ឧ.សិ កុល ណំ និង បុត្រ............................................ ១៥០០០៛

៧១-យ៉ង់ ណែម............................................................ ៣៥០០៛

៧២-យ៉ង់ នេម............................................................ ៥៥០០៛

៧៣-យ៉ង់ ផុន............................................................ ៥០០០៛

៧៤-យ៉ង់ នាង............................................................ ២០០០៛

៧៥-យ៉ង់ ណាត............................................................ ២៥០០៛

៧៦-យ៉ង់ ស៊ុម............................................................ ៣០០០៛

៧៧-កង គឿន............................................................ ១០០០៛

៧៨-ញ៉ែប ធី............................................................ ១០០០៛

៧៩-ញ៉ែប ឡៅ............................................................ ១០០០៛

៨០-ជន យ៉ិន............................................................ ៣៥០០៛

៨១-ឧ.ស ពក យ៉ាន និង ឧ.សិ ម៉ែន ង៉ា......................... ១០០០០៛

៨២-សាមណេរ ណាល នួនវណ្ណៈ........................................ ៥០០០៛

www.elibraryofcambodia.org

៨៣-សាមណេរ ប៊ុម សារ៉ង................................................ ៣០០០៛

៨៤-សាមណេរ នៅ ស្រួច................................................ ១០០០០៛

៨៥-សាមណេរ តន ភារម្យ................................................ ៥០០០៛

៨៦-សាមណេរ ពាង ធំ................................................ ៥០០០៛

៨៧-សាមណេរ អ៊ុំ សំអាន................................................ ២០០០៛

៨៨-សាមណេរ ស៊ន សារិ................................................ ១០០០០៛

៨៩-សាមណេរ មួន ឌីន................................................ ៥០០០៛

៩០-ភិក្ខុ គីម សារ៉េម................................................ ៥០០០៛

៩១-ភិក្ខុ ជឿន សុផាត................................................ ៥០០០៛

៩២-ឧបាសិកា ញ៉ាញ់................................................ ៥០០០៛

៩៣-កញ្ញា កន ស្រីភាព................................................ ១០០០០៛

៩៤-កញ្ញា កន ស្រីមុំ................................................ ១០០០០៛

៩៥-កញ្ញា ឡៀប ស៊ីនួន................................................ ១០០០០៛

៩៦-កែវ គង់ . ឃីម សុខា ព្រមទាំងបុត្រ................................................ ៤០០០០៛

៩៧-សាមណេរ ណាត ម៉ាញ................................................ ៥០០០៛

៩៨-សាមណេរ គីម សុគីម................................................ ៣០០០៛

៩៩-សាមណេរ ម៉ន រស ................................................៥០០០៛

www.elibraryofcambodia.org

១០០-សាមណេរ ហួន សៅ..................................................៥០០០៛

១០១-ឧ.សិ សៅ ម៉ៃ..................................................... ៣០០០៛

១០២-ឧ.សិ គិន ទន់.................................................. ១០០០០៛

១០៣-កញ្ញា ម៉ៃ សួរ...................................................... ១០០០០៛

១០៤-កញ្ញា ម៉ៃ សុធា.................................................... ១០០០០៛

១០៥-កញ្ញា ម៉ៃ មុត...................................................... ១០០០០៛

១០៦-លោក អែ ដេត និង អ្នកស្រី ងិន ស្រីម៉ៅ...............២០០០០៛

១០៧-លោក សឿន សុគន្ធ និង ភរិយា......................... ១០០០០៛

១០៨-លោក តែម សុភាព និង ភរិយា..........................១០០០០៛

១០៩-លោក ឡៀប សុភឿន និង ភរិយា........................ ១០០០០៛

១១០-ពូ តូ និង ភរិយា.................................................. ១០០០០៛

១១១-ឃួន សីហា.......................................................... ៨០០០៛

១១២-ឧ.សិ សុខ សាមឿន ,ឧ.សិ តាំង សម្បត្តិ និងបុត្រ ១២៥ ដុល្លារ

១១៣-ឧ.សិ អ៊ុក សុវណ្ណារី និង ទាំងកូនចៅ.....................២០ ដុល្លារ

១១៤-លោកអាចារ្យ ប៉ែន ផាត និង គ្រួសារ.....................១០ ដុល្លារ

១១៥-ឧ.សិ ម៉ែន អុន និង កូនចៅ...............................១០០ ដុល្លារ

១១៦-ឧ.ស ត្រៃ ហ៊ល ,ឧ.សិ ហុក ណាំ.......................១០០ ដុល្លារ

www.elibraryofcambodia.org

១១៧-អ៊ឹម ច័ន្ទតារា.......................................... ១០ ដុល្លារ

១១៨- អ៊ឹម ច័ន្ទសិរីវុឌ្ឍ ...................................... ១០ ដុល្លារ

១១៩- ជូយ៉ា ដារីណា ថាវ ...................................... ១០ ដុល្លារ

១២០- ព្រីនជីន តៃ .......................................... ១០ ដុល្លារ

១២១- វ៉ាយអេន តៃ .......................................... ១០ ដុល្លារ

១២២- មេហ្គេន តៃ .......................................... ១០ ដុល្លារ

១២៣- អេរ្យិច តៃ .......................................... ១០ ដុល្លារ

១២៤- អេដវីដ តៃ .......................................... ១០ ដុល្លារ

3 006056 08200693 00605

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ ប៊ុន ភក្តី
ខែសីហា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ចៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

www.elibraryofcambodia.org